ក្រសួងអប់រំ យុវជន និងកីឡា

Ministry of Education, Youth and Sport

វិទ្យាស្ថានជាតិអប់រំ

National Institute of Education

# និក្ខេបបទ

# ទស្សនៈគ្រូបង្រៀនលើការអនុវត្ត សហគមន៍សិក្សាវិជ្ជាជីវៈនៅកម្រិតមធ្យមសិក្សា ក្នុងខេត្តកំពង់ចាម

# SECONDARY SCHOOL TEACHERS´PERCEPTIONS OF A PROFESSIONAL LEARNING COMMUNITY IN KAMPONG CHAM PROVINCE

ស៊ិន ភារ័ក្ស

SIN PHEAREAK

ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ការបណ្តុះបណ្តាល
ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៩

ឯកទេស៖ គ្រប់គ្រងអប់រំ

ឆ្នាំសិក្សា ២០២០-២០២២

ក្រសួងអប់រំ យុវជន និងកីឡា

Ministry of Education, Youth and Sport

វិទ្យាស្ថានជាតិអប់រំ

National Institute of Education

# និក្ខេបបទ

# ទស្សនៈគ្រូបង្រៀនលើការអនុវត្ត សហគមន៍សិក្សាវិជ្ជាជីវៈនៅកម្រិតមធ្យមសិក្សា ក្នុងខេត្តកំពង់ចាម

# SECONDARY SCHOOL TEACHERS′PERCEPTIONS OF A PROFESSIONAL LEARNING COMMUNITY IN KAMPONG CHAM PROVINCE


ស៊ិន ភារ័ក្ស

SIN PHEAREAK


ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ការបណ្តុះបណ្តាល

ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៩

ឯកទេស៖ គ្រប់គ្រងអប់រំ

ឆ្នាំសិក្សា ២០២០-២០២២

គ្រូណែនាំគោល៖ បណ្ឌិត អាន វ៉ុប្រាជ

គ្រូណែនាំរង៖ បណ្ឌិត នី រដ្ឋា

# សេចក្តីអះអាងរបស់បេក្ខជន

ខ្ញុំបាទសូមបញ្ជាក់ថា និក្ខេបបទស្រាវជ្រាវដែលមានចំណងជើងថា «**ទស្សនៈគ្រូបង្រៀនលើការអនុវត្តសហគមន៍សិក្សាវិជ្ជាជីវៈនៅកម្រិតមធ្យមសិក្សាក្នុងខេត្តកំពង់ចាម**» សម្រាប់បំពេញលក្ខខណ្ឌសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំនៅវិទ្យាស្ថានជាតិអប់រំ ពិតជាស្នាដៃរបស់ខ្ញុំបាទទាំងស្រុង។ ស្នាដៃនេះពុំទាន់បានប្រើប្រាស់ដើម្បីបំពេញលក្ខខណ្ឌសិក្សាសម្រាប់ការទទួលសញ្ញាបត្រនៅវិទ្យាស្ថាននេះ ឬសាកលវិទ្យាល័យណា ឬវិទ្យាស្ថានថ្នាក់ស្មើណាមួយនៅឡើយទេ។ ពុំមានសេចក្តីដកស្រង់ ឬខ្លឹមសារអ្វីមួយត្រូវបានប្រើប្រាស់ក្នុងអត្ថបទស្រាវជ្រាវនេះ ដោយគ្មានការអនុញ្ញាតពីអ្នកនិពន្ធ ឬចុះបញ្ជីឯកសារយោងឡើយ។ និក្ខេបបទស្រាវជ្រាវខាងលើនេះពិតជាត្រូវបានស្រាវជ្រាវ និងចងក្រងដោយខ្ញុំបាទពិតប្រាកដមែន។

ថ្ងៃអាទិត្យ ១៣កើត ខែកត្តិក ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០២២

**ហត្ថលេខា**

**ស៊ិន តារ័ក្ស**

# លិខិតបញ្ជាក់

**បណ្ឌិត អាន វ៉ូប្រាង** ជាគ្រូណែនាំគោល

**បណ្ឌិត នី រដ្ឋា** ជាគ្រូណែនាំរង

**សូមបញ្ជាក់ និងទទួលស្គាល់ថា**

លោក **ស៊ិន តារ័ក្ស** ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៩ ពិតជាបានសរសេរនិក្ខេបបទស្រាវជ្រាវស្តីពី «**ទស្សនៈគ្រូបង្រៀនលើការអនុវត្តសហគមន៍សិក្សាវិជ្ជាជីវៈនៅកម្រិតមធ្យមសិក្សាក្នុងខេត្តកំពង់ចាម**» ពិតប្រាកដមែន។

ថ្ងៃអាទិត្យ ១៣កើត ខែកត្តិក ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០២២



.......................................

**បណ្ឌិត អាន វ៉ូប្រាង**

អនុប្រធានដេប៉ាតឺម៉ង់

វិទ្យាស្ថានជាតិអប់រំ



.......................................

**បណ្ឌិត នី រដ្ឋា**

ប្រធានការិយាល័យសិក្សា

វិទ្យាស្ថានជាតិអប់រំ

# លិខិតឧទ្ទេសនាមគណៈកម្មការវាយតម្លៃការការពារនិក្ខេបបទ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**
**លេខ:..៣៧២៦.អយក.ហ៩ន**

**(ការសម្ងាត់)**

## លិខិតឧទ្ទេសនាម

យោង៖ ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៩ និងទី១០ ឆ្នាំសិក្សា២០២១-២០២២ ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២១។

បុគ្គលិកអប់រំ នៃក្រសួងអប់រំ យុវជន និងកីឡា ដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងជា **គណៈកម្មការការពារនិក្ខេបបទ** ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៩ ដែលនឹងប្រព្រឹត្តទៅពីថ្ងៃទី៥-៦ ខែវិច្ឆិកា ឆ្នាំ២០២២ នៅវិទ្យាស្ថានជាតិអប់រំ៖

| | | | |
|---|---|---|---|
| ១-លោកស្រី | ប៊ុន សុផានី | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២-លោក | ថៃ ហេង | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៣-លោកបណ្ឌិត | អាន វ៉ូប្រាវ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៤-លោកបណ្ឌិត | ឡាយ សុវិជ្ជា | នាយកដ្ឋានគោលនយោបាយ | សមាជិក |
| ៥-លោកបណ្ឌិត | សោន វណ្ណៈ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៦-លោកបណ្ឌិត | ឈន ថន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៧-លោកបណ្ឌិត | លី គឹមឡុង | សាកលវិទ្យាល័យភូមិន្ទភ្នំពេញ | សមាជិក |
| ៨-លោកបណ្ឌិត | ឈិញ នីដា | សាកលវិទ្យាល័យភូមិន្ទភ្នំពេញ | សមាជិក |
| ៩-លោកបណ្ឌិត | អ៊ុំ ចាន់ចំណាន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១០-លោកបណ្ឌិត | កាង ស៊ុងឆាង | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១១-លោក | ម៉ៅ សារឿន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១២-លោក | លឹម វ៉ាន់ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៣-លោក | ចាន់ វ៉ាដា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៤-លោកបណ្ឌិត | មឿន លិនណា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៥-លោកបណ្ឌិត | គួយ សុគាន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៦-លោកស្រីបណ្ឌិត | ឡឹយ សុគា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៧-លោក | ប៉ូ ប៊ុន្នួន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៨-លោកស្រី | នូ ចន្ទី | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៩-លោកបណ្ឌិត | សឿ សុផា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២០.លោក | ថាច់ សន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២១.លោក | ឡុច ចាន់ថន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២២.លោកស្រី | សេង សច្ចា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២៣.លោក | ចាន់ ធឿន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២៤.លោកស្រី | សុខ វណ្ណា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២៥.លោកស្រី | ឯម សុភាលក្ស្មី | វិទ្យាស្ថានជាតិអប់រំ | សមាជិក |

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ: www.moeys.gov.kh

លោក លោកស្រី ដូចមានរាយនាមខាងលើ ត្រូវអញ្ជើញមកវាយតម្លៃការការពារនិក្ខេបបទរបស់និស្សិតពីថ្ងៃទី៥-៦ ខែវិច្ឆិកា ឆ្នាំ២០២២ ចាប់ពីម៉ោង៧:៣០នាទីព្រឹកតទៅ នៅវិទ្យាស្ថានជាតិអប់រំ។

ថ្ងៃ ចន្ទ ៧កើត ខែកត្តិក ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែតុលា ឆ្នាំ២០២២

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

កន្លែងទទួល៖

- អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី "ដើម្បីជូនជ្រាបជាព័ត៌មាន"
- គ្រប់អង្គភាព ពាក់ព័ន្ធក្រោមឱវាទទីស្តីការក្រសួងអប់រំ យុវជន និងកីឡាដែលពាក់ព័ន្ធ "ដើម្បីជ្រាបជាព័ត៌មាន"
- សាមីខ្លួន "ដើម្បីអនុវត្ត"
- កាលប្បវត្តិ - ឯកសារ រដអ

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំបាទសូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ ក្រសួងអប់រំ យុវជន និងកីឡា និង វិទ្យាស្ថានជាតិអប់រំ ដែលបានរៀបចំឱ្យមានកម្មវិធីបណ្តុះបណ្តាលថ្នាក់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំនេះឡើង ជាឱកាសឱ្យរូបខ្ញុំបាទបានទទួលបានអាហារូបករណ៍សិក្សានៅទីនេះ។

ខ្ញុំបាទសូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះគណៈកម្មការវគ្គបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៩ និងលោកគ្រូ អ្នកគ្រូ ដែលបានឆ្លៀតពេលដ៏មមាញឹក ដើម្បីរៀបចំការបណ្តុះបណ្តាល និងបានផ្តល់នូវចំណេះដំនាញដ៏មានតម្លៃដល់រូបខ្ញុំបាទ។ ខ្ញុំបាទក៏សូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះលោកបណ្ឌិត **អាន វិរះប្រាជ** គ្រូណែនាំ និងលោកបណ្ឌិត **នី រដ្ឋា** គ្រូណែនាំរង ដែលបានជួយជ្រោមជ្រែង និងផ្តល់ការណែនាំល្អៗ នៅគ្រប់ជំហាននៃការសរសេរនិក្ខេបបទស្រាវជ្រាវនេះ រហូតដល់ការបញ្ចប់និក្ខេបបទនេះដោយជោគជ័យ។ ខ្ញុំបាទក៏មិនភ្លេចថ្លែងអំណរគុណផងដែរចំពោះមិត្តរួមជំនាន់ទី៩ ដែលបានចែករំលែកចំណេះដឹង និងបទពិសោធន៍ល្អៗ ប្រកបដោយភាតរភាពរវាងគ្នានិងគ្នា។

ខ្ញុំបាទសូមថ្លែងអំណរគុណផងដែរចំពោះលោកនាយក លោកនាយករងវិទ្យាល័យ ហ៊ុន សែន កំពង់ចាម និង វិទ្យាល័យ ហ៊ុន សែន ពាមជីកង ព្រមទាំងលោកគ្រូ អ្នកគ្រូ ដែលបានអនុញ្ញាត និងចូលរួមសហការក្នុងការបំពេញកម្រងសំណួរស្រាវជ្រាវ ដែលជាផ្នែកមួយដ៏សំខាន់នៃការសិក្សានេះ។

ការសម្រេចបានជោគជ័យនេះក៏មានចំណែករបស់អ្នកគ្រូ **វ៉ាន់ សុធាវី** ភរិយាខ្ញុំបាទផងដែរ។ សូមអរគុណជាអនេកចំពោះភរិយាខ្ញុំបាទ ដែលតែងតែជួយទាំងកម្លាំងកាយនិងចិត្តដល់រូបខ្ញុំបាទ និងតែងតែនៅក្បែររូបខ្ញុំបាទក្នុងគ្រាដ៏មមាញឹកនេះ។

ខ្ញុំបាទក៏សូមឧទ្ទិសស្នាដៃមួយនេះជូនចំពោះវិញ្ញាណក្ខន្ធលោកឪពុក **ស៊ិន សារិន** ដែលកាលនៅមានជីវិតលោកបានអប់រំ បង្ហាត់បង្រៀនខ្ញុំបាទឱ្យក្លាយជាមនុស្សល្អ និងយល់ពីតម្លៃនៃការសិក្សា។ ខ្ញុំបាទ

សូមគោរពដឹងគុណជាទីបំផុតចំពោះអ្នកម្តាយ **អ៊ឹម អ៊ិន** ដែលអ្នកម្តាយតែងតែប្រឹងប្រែងអស់ពីកម្លាំងកាយចិត្ត ចិញ្ចឹមបីបាច់ និងអប់រំរូបខ្ញុំបាទរហូតមានថ្ងៃនេះ។

ជាទីបញ្ចប់ ខ្ញុំបាទសូមគោរពជូនពរចំពោះឯកឧត្តម លោកជំទាវ លោក លោកស្រី លោកគ្រូ អ្នកគ្រូ និងមិត្តភក្តិរួមជំនាន់ទាំងអស់ សូមសមប្រកបតែនឹងពុទ្ធពរទាំងឡាយ៤ប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# មូលន័យសង្ខេប

សហគមន៍សិក្សាវិជ្ជាជីវៈត្រូវបានដាក់បញ្ចូលជាផ្នែកមួយនៃកម្មវិធីសាលារៀនជំនាន់ថ្មីក្នុងប្រទេសកម្ពុជា ដើម្បីជាការលើកកម្ពស់សកម្មភាពសហការរៀនសូត្រពីគ្នាទៅវិញទៅមករវាងបុគ្គលិកអប់រំ។ ការសិក្សាស្រាវជ្រាវនេះមានគោលបំណងសិក្សាពី (១) ទស្សនៈគ្រូបង្រៀនលើការអនុវត្តសហគមន៍សិក្សាវិជ្ជាជីវៈរបស់គ្រូបង្រៀននៅកម្រិតមធ្យមសិក្សាក្នុងខេត្តកំពង់ចាម និង (២) បញ្ហាប្រឈមដែលកើតមានក្នុងការអនុវត្តសហគមន៍សិក្សាវិជ្ជាជីវៈរបស់គ្រូបង្រៀននៅកម្រិតមធ្យមសិក្សាក្នុងខេត្តកំពង់ចាម។

ការសិក្សានេះត្រូវបានធ្វើឡើងតាមបែបបរិមាណវិស័យ។ ភាគសំណាកសម្រាប់ការស្រាវជ្រាវនេះ គឺ គ្រូបង្រៀនចំនួន ៦៦ នាក់ និងគណៈគ្រប់គ្រងចំនួន ០៦ នាក់ នៅសាលារៀនជំនាន់ថ្មីទាំងពីរក្នុងខេត្តកំពង់ចាម ដែលត្រូវបានជ្រើសរើសផ្អែកលើលក្ខណៈវិនិច្ឆ័យសមស្របសម្រាប់ប្រធានបទ (Judgement Sampling)។ ឧបករណ៍ដែលប្រើក្នុងការស្រាវជ្រាវនេះ គឺជាកម្រងសំណួរស្តីពីការអនុវត្ត និងបញ្ហាប្រឈមក្នុងការអនុវត្តសហគមន៍សិក្សាវិជ្ជាជីវៈដែលកសាងឡើងដោយផ្អែកលើ “សៀវភៅណែនាំស្តីពីការបង្កើតសហគមន៍សិក្សាវិជ្ជាជីវៈ Professional Learning Community (PLC) នៅតាមគ្រឹះស្ថានសិក្សាសាធារណៈ” របស់ក្រសួងអប់រំ យុវជន និងកីឡា។ ទិន្នន័យដែលទទួលបានពីការបំពេញកម្រងសំណួរត្រូវបានវិភាគតាមស្ថិតិបែបពណ៌នា ដោយប្រើប្រាស់កម្មវិធី IBM SPSS Statistics 26។

លទ្ធផលនៃការសិក្សាបង្ហាញថា ការអនុវត្តសហគមន៍សិក្សាវិជ្ជាជីវៈនៅកម្រិតមធ្យមសិក្សាក្នុងខេត្តកំពង់ចាមស្ថិតនៅកម្រិត “ល្អ” (មធ្យម = ៣.៩៨ គម្លាតស្តង់ដា = ០.៦៨)។ ចំណុចអនុវត្តដែលរួមមានរបៀបរបបអនុវត្តការងារ និងប្រព័ន្ធគាំទ្រសហគមន៍សិក្សាវិជ្ជាជីវៈ សុទ្ធតែអនុវត្តបានល្អ។ ទន្ទឹមនឹងការអនុវត្តបានល្អនេះ បញ្ហាប្រឈមតិចតួចចំនួន០២ ក៏ត្រូវបានរកឃើញ។ បញ្ហាប្រឈមទី១ គឺ បន្ទុកការងារ និងឧបសគ្គពេលវេលា (មធ្យម = ៣.៣៩ គម្លាតស្តង់ដា = ០.៧៥)។ បញ្ហាប្រឈមទី២ គឺ ការយល់ដឹងមិនបានច្បាស់ពីការអនុវត្តសហគមន៍សិក្សាវិជ្ជាជីវៈ (មធ្យម = ៣.៣៦ គម្លាតស្តង់ដា = ០.៨៥)។

# Abstract

Professional Learning Communities have been implemented in New Generation Schools in Cambodia for the purpose of promoting teachers and educators' collaboration culture. This study aimed (1) to explore secondary school teachers' perceptions of a teachers' professional learning community (PLC) in Kampong Cham province and (2) to identify challenges of implementing the teachers' professional learning community.

A quantitative research method was used in this study. 66 secondary school teachers and six school directors and vice-directors were purposively chosen using judgment sampling to complete the questionnaire, which was designed based on 'Guidelines for Creating a Professional Learning Community in Public Educational Institutions' by Ministry of Education, Youth, and Sport. The data gained from the survey was analyzed with IBM SPSS Statistics 26 using descriptive statistics analysis.

Findings showed that the implementation of the professional learning community in Kampong Cham province, perceived by secondary school teachers and board of directors, was good (Mean = 3.98; SD = 0.68). The teachers perceived that both the system of implementing PLC and the supporting system for PLC were well conducted. Meanwhile, two minor challenges were also identified in the study. The first challenge was heavy workload and time constraints (Mean = 3.39; SD = 0.75), and the second one was misconception of PLC (Mean = 3.36; SD = 0.85).

# មាតិកា

**សេចក្តីអះអាងរបស់បេក្ខជន** ........................................ i

**លិខិតបញ្ជាក់** ........................................ ii

**លិខិតឧទ្ទេសនាមគណៈកម្មការវាយតម្លៃការការពារនិក្ខេបបទ** ........................................ iii

**សេចក្តីថ្លែងអំណរគុណ** ........................................ v

**មូលន័យសង្ខេប** ........................................ vii

Abstract ........................................ viii

**ជំពូក១** ........................................ 1

**សេចក្តីផ្តើម** ........................................ 1

១.១- លំនាំបញ្ហា ........................................ 1

១.២- ចំណោទបញ្ហានៃការស្រាវជ្រាវ ........................................ 3

១.៣- គោលបំណងនៃការស្រាវជ្រាវ ........................................ 3

១.៤- សំណួរស្រាវជ្រាវ ........................................ 3

១.៥- ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ ........................................ 4

១.៥.១- វិសាលភាពនៃការស្រាវជ្រាវ ........................................ 4

១.៥.២- ដែនកំណត់នៃការស្រាវជ្រាវ ........................................ 4

១.៦- សារៈសំខាន់នៃការស្រាវជ្រាវ ........................................ 4

១.៧- រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ........................................ 5

**ជំពូក២** ........................................ 6

**ការរំលឹកទ្រឹស្តី** ........................................ 6

២.១- និយមន័យសហគមន៍សិក្សាវិជ្ជាជីវៈ ........................................ 6

២.២- បញ្ញត្តិនានាទាក់ទងនឹងសហគមន៍សិក្សាវិជ្ជាជីវៈ ........................................ 7

២.២.១- គោលគំនិតសំខាន់ៗចំនួន៣នៃសហគមន៍សិក្សាវិជ្ជាជីវៈ......7
២.២.២- វដ្តនៃការចោទសួរនៅក្នុងសហគមន៍សិក្សាវិជ្ជាជីវៈ......8
២.២.៣- សកម្មភាពសំខាន់ៗដែលអាចអនុវត្តបាន......9
២.៣- ទស្សនៈលើការអនុវត្តសហគមន៍សិក្សាវិជ្ជាជីវៈ......11
២.៣.១- ការសិក្សាជាក្រុម......11
២.៣.២- ការសង្កេតថ្នាក់......12
២.៣.៣- ភារកិច្ចរបស់សហគមន៍សិក្សាវិជ្ជាជីវៈ......13
២.៣.៤- អ្នកពាក់ព័ន្ធសំខាន់ៗដែលការគាំទ្រសហគមន៍សិក្សាវិជ្ជាជីវៈ និងប្រព័ន្ធលើកទឹកចិត្ត......14
២.៣.៥- ទស្សនៈលើការអនុវត្តសហគមន៍សិក្សាវិជ្ជាជីវៈ និងលទ្ធផលសិក្សារបស់សិស្ស......16
២.៤- បញ្ហាប្រឈមក្នុងការអនុវត្តសហគមន៍សិក្សាវិជ្ជាជីវៈ......17
**ជំពូក៣**......21
**វិធីសាស្ត្រនៃការស្រាវជ្រាវ**......21
៣.១- គម្រោងវិភាគ......21
៣.២- ការប្រមូលទិន្នន័យ......21
៣.៣- ឧបករណ៍ស្រាវជ្រាវ......22
៣.៣.១- កម្រិតចង្អុលបង្ហាញ......22
៣.៣.២- កម្រងសំណួរ......23
៣.៤- ប្រជាជន និងភាគសំណាក......24
៣.៤.១- ប្រជាជន......24
៣.៤.២- ភាគសំណាកដែលបានចូលរួមបំពេញកម្រងសំណួរ......24
៣.៥- ការវិភាគទិន្នន័យ......28
៣.៦- ភាពជឿជាក់នៃកម្រងសំណួរ......28
៣.៧- សុពលភាពនៃកម្រងសំណួរ......28

៣.៨- ក្រមសីលធម៌នៃការស្រាវជ្រាវ ........................................................................ 29
**ជំពូក៤** ........................................................................ 30
**លទ្ធផល និងការពិភាក្សា** ........................................................................ 30
៤.១- លទ្ធផល ........................................................................ 30
៤.១.១- ការវិភាគទិន្នន័យដែលបានមកពីកម្រងសំណួរស្តីពីទស្សនៈគ្រូបង្រៀនលើការអនុវត្តសហគមន៍សិក្សាវិជ្ជាជីវៈនៅកម្រិតមធ្យមសិក្សាក្នុងខេត្តកំពង់ចាម ........................................................................ 30
៤.១.២- ការវិភាគទិន្នន័យដែលបានមកពីកម្រងសំណួរស្តីពីទស្សនៈគ្រូបង្រៀនលើបញ្ហាប្រឈមក្នុងការអនុវត្តសហគមន៍សិក្សាវិជ្ជាជីវៈនៅកម្រិតមធ្យមសិក្សាក្នុងខេត្តកំពង់ចាម ........................................................................ 49
៤.២- ការពិភាក្សា ........................................................................ 61
៤.២.១- ការពិភាក្សាលើការអនុវត្តសហគមន៍សិក្សាវិជ្ជាជីវៈនៅកម្រិតមធ្យមសិក្សាក្នុងខេត្តកំពង់ចាម ........................................................................ 61
៤.២.២- ការពិភាក្សាពីបញ្ហាប្រឈមក្នុងការអនុវត្តសហគមន៍សិក្សាវិជ្ជាជីវៈនៅកម្រិតមធ្យមសិក្សាក្នុងខេត្តកំពង់ចាម ........................................................................ 66
**ជំពូក៥** ........................................................................ 68
**សេចក្តីសន្និដ្ឋាន និងសំណូមពរ** ........................................................................ 68
៥.១- សេចក្តីសន្និដ្ឋាន ........................................................................ 68
៥.២- សំណូមពរ ........................................................................ 70
**ឯកសារយោង** ........................................................................ 72
**ឧបសម្ព័ន្ធ** ........................................................................ 76

# បញ្ជីតារាង

តារាងទី ១៖ ទិន្នន័យចំនួនភាគសំណាកដែលបានបំពេញកម្រងសំណួរ ....................................25

តារាងទី ២៖ ទិន្នន័យព័ត៌មានទូទៅអំពីគណៈគ្រប់គ្រង.........................................................26

តារាងទី ៣៖ ទិន្នន័យព័ត៌មានទូទៅនៃចំនួន និងភាគរយសំណាកគ្រូបង្រៀន..............................26

តារាងទី ៤៖ ទិន្នន័យស្តីពីទស្សនៈគ្រូបង្រៀនលើការសិក្សាជាក្រុម...........................................30

តារាងទី ៥៖ ទិន្នន័យស្តីពីទស្សនៈគណៈគ្រប់គ្រងលើការសិក្សាជាក្រុម ....................................31

តារាងទី ៦៖ ទិន្នន័យស្តីពីទស្សនៈគ្រូបង្រៀនលើការសង្កេតថ្នាក់ និងប្រឹក្សា................................32

តារាងទី ៧៖ ទិន្នន័យស្តីពីទស្សនៈគណៈគ្រប់គ្រងលើការសង្កេតថ្នាក់ និងប្រឹក្សា .........................33

តារាងទី ៨៖ ទិន្នន័យស្តីពីទស្សនៈគ្រូបង្រៀនលើការបំពេញភារកិច្ចរបស់សហគមន៍សិក្សាវិជ្ជាជីវៈ ...34

តារាងទី ៩៖ ទិន្នន័យស្តីពីទស្សនៈគណៈគ្រប់គ្រងលើការបំពេញភារកិច្ចរបស់សហគមន៍សិក្សា
វិជ្ជាជីវៈ.........................................................................................................................37

តារាងទី ១០៖ ទិន្នន័យស្តីពីទស្សនៈគ្រូបង្រៀនលើអ្នកពាក់ព័ន្ធសំខាន់ៗដែលការគាំទ្រដល់សហគមន៍
សិក្សាវិជ្ជាជីវៈ.................................................................................................................39

តារាងទី ១១៖ ទិន្នន័យស្តីពីទស្សនៈគណៈគ្រប់គ្រងលើអ្នកពាក់ព័ន្ធសំខាន់ៗដែលការគាំទ្រដល់
សហគមន៍សិក្សាវិជ្ជាជីវៈ..................................................................................................... 41

តារាងទី ១២៖ ទិន្នន័យស្តីពីទស្សនៈរគ្រូបង្រៀនលើប្រព័ន្ធលើកទឹកចិត្តដល់សហគមន៍សិក្សាវិជ្ជាជីវៈ43

តារាងទី ១៣៖ ទិន្នន័យស្តីពីទស្សនៈគណៈគ្រប់គ្រងលើប្រព័ន្ធលើកទឹកចិត្តដល់សហគមន៍
សិក្សាវិជ្ជាជីវៈ.................................................................................................................45

តារាងទី ១៤៖ លទ្ធផលសង្ខេបស្តីពីទស្សនៈគ្រូបង្រៀនលើការអនុវត្តសហគមន៍សិក្សាវិជ្ជាជីវៈ ........46

តារាងទី ១៥៖ លទ្ធផលសង្ខេបស្តីពីទស្សនៈគណៈគ្រប់គ្រងលើការអនុវត្តសហគមន៍សិក្សាវិជ្ជាជីវៈ..47

តារាងទី១៦៖ ទិន្នន័យសង្ខេបស្តីពីទស្សនៈគ្រូបង្រៀន និងគណៈគ្រប់គ្រងលើការអនុវត្តសហគមន៍
សិក្សាវិជ្ជាជីវៈ.................................................................................................................48

តារាងទី ១៧៖ ទិន្នន័យស្តីពីទស្សនៈគ្រូបង្រៀនលើបន្ទុកការងារ និងឧបសគ្គពេលវេលា ................49

តារាងទី ១៨៖ ទិន្នន័យស្តីពីទស្សនៈគណៈគ្រប់គ្រងលើបន្ទុកការងារ និងឧបសគ្គពេលវេលា ..........50

តារាងទី ១៩៖ ទិន្នន័យស្តីពីទស្សនៈគ្រូបង្រៀនលើការយល់ដឹងមិនច្បាស់ពីការអនុវត្តសហគមន៍សិក្សាវិជ្ជាជីវៈ.......................................................................................... 51
តារាងទី ២០៖ ទិន្នន័យស្តីពីទស្សនៈគណៈគ្រប់គ្រងលើការយល់ដឹងមិនច្បាស់ពីការអនុវត្តសហគមន៍សិក្សាវិជ្ជាជីវៈ..........................................................................................52
តារាងទី ២១៖ ទិន្នន័យស្តីពីទស្សនៈគ្រូបង្រៀនលើកង្វះវប្បធម៌ពិភាក្សា ....................................52
តារាងទី ២២៖ ទិន្នន័យស្តីពីទស្សនៈគណៈគ្រប់គ្រងលើកង្វះវប្បធម៌ពិភាក្សា.............................53
តារាងទី ២៣៖ ទិន្នន័យស្តីពីទស្សនៈគ្រូបង្រៀនលើឥរិយាបថអសកម្មរបស់សមាជិកសហគមន៍......54
តារាងទី ២៤៖ ទិន្នន័យស្តីពីទស្សនៈគណៈគ្រប់គ្រងលើឥរិយាបថអសកម្មរបស់សមាជិកសហគមន៍ 55
តារាងទី ២៥៖ ទិន្នន័យស្តីពីទស្សនៈគ្រូបង្រៀនលើកង្វះទំនុកចិត្តលើគ្រូបង្រៀនដទៃ....................55
តារាងទី ២៦៖ ទិន្នន័យស្តីពីទស្សនៈគណៈគ្រប់គ្រងលើកង្វះទំនុកចិត្តលើគ្រូបង្រៀនដទៃ .............56
តារាងទី ២៧៖ លទ្ធផលសង្ខេបស្តីពីទស្សនៈគ្រូបង្រៀនលើបញ្ហាប្រឈមក្នុងការអនុវត្តសហគមន៍សិក្សាវិជ្ជាជីវៈ..........................................................................................56
តារាងទី ២៨៖ លទ្ធផលសង្ខេបស្តីពីទស្សនៈគណៈគ្រប់គ្រងលើបញ្ហាប្រឈមក្នុងការអនុវត្តសហគមន៍សិក្សាវិជ្ជាជីវៈ..........................................................................................57
តារាងទី ២៩៖ តារាងសង្ខេបទិន្នន័យស្តីពីទស្សនៈគ្រូបង្រៀន និងទស្សនៈគណៈគ្រប់គ្រងលើបញ្ហាប្រឈមក្នុងការអនុវត្តសហគមន៍សិក្សាវិជ្ជាជីវៈ ..........................................................58
តារាងទី ៣០៖ តារាងសង្ខេបទិន្នន័យស្តីពីបញ្ហាប្រឈមដោយពិនិត្យមើលតាមសាលានីមួយៗដោយឡែក..........................................................................................60

# ជំពូក១

# សេចក្តីផ្តើម

## ១.១- លំនាំបញ្ហា

រាជរដ្ឋាភិបាលកម្ពុជាអាណត្តិទី៦ បានកំណត់ចក្ខុវិស័យកម្ពុជាឆ្នាំ២០៣០-២០៥០ របស់ខ្លួនថា នៅឆ្នាំ២០៣០ កម្ពុជានឹងក្លាយជាប្រទេសដែលចំណូលមធ្យមកម្រិតខ្ពស់ និងនៅឆ្នាំ២០៥០ កម្ពុជានឹងក្លាយទៅជាប្រទេសដែលមានចំណូលខ្ពស់។ ដើម្បីឆ្លើយតបទៅនឹងចក្ខុវិស័យនេះ រាជរដ្ឋាភិបាលកម្ពុជា បានកំណត់យកការអភិវឌ្ឍធនធានមនុស្សជាមុំទី១នៃយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤របស់ខ្លួន (រាជរដ្ឋាភិបាលកម្ពុជា ២០២១)។ ក្រសួងអប់រំ យុវជន និងកីឡា មានតួនាទីធ្វើយ៉ាងណាផលិតឱ្យបាននូវធនធានមនុស្សដែលឆ្លើយតបទៅនឹងគោលដៅអភិវឌ្ឍន៍នេះ។ ដើម្បីគាំទ្រដល់ចក្ខុវិស័យកម្ពុជាឆ្នាំ ២០៣០-២០៥០ របស់រាជរដ្ឋាភិបាល ក្រសួងអប់រំ យុវជន និងកីឡា បានដាក់បញ្ចូលក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០២៣ នូវផែនទីបង្ហាញផ្លូវវិស័យអប់រំឆ្នាំ២០៣០ ដោយបានកំណត់យុទ្ធសាស្ត្រចម្បងៗមួយចំនួន ដែលរួមមានការយកចិត្តទុកដាក់ទៅលើប្រព័ន្ធអប់រំទាំងមូល សាលារៀន គ្រូបង្រៀន និងសិស្ស។ គោលដៅចម្បងនៃកិច្ចខិតខំប្រឹងប្រែងនេះ គឺ ធ្វើយ៉ាងណាឱ្យសម្រេចបាននូវលទ្ធផលការងារ និងលទ្ធផលសិក្សារបស់សិស្សល្អប្រសើរ។ ការសម្រេចបាននូវលទ្ធផលការងារ និងលទ្ធផលសិក្សារបស់សិស្សទាមទារឱ្យមានការគាំទ្រគ្នាទៅវិញទៅមកក្នុងចំណោមថ្នាក់ដឹកនាំសាលារៀន និងគ្រូបង្រៀន។ ជាក់ស្តែង នៅក្នុងក្របខណ្ឌការអភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈជាប្រចាំសម្រាប់គ្រូបង្រៀន និងនាយកសាលារៀន ក្រសួងអប់រំ យុវជន និងកីឡា បានកំណត់យកការបង្កើតឱ្យមានសហគមន៍សិក្សាវិជ្ជាជីវៈនៅតាមសាលារៀន ដើម្បីជួយឱ្យគ្រូបង្រៀន និងថ្នាក់ដឹកនាំសាលារៀន គាំទ្រគ្នាទៅវិញទៅមកក្នុងការលើកកម្ពស់ការអនុវត្តការដឹកនាំនិងគ្រប់គ្រង និងការបង្រៀន។

ការបង្កើតឱ្យមាន សហគមន៍សិក្សាវិជ្ជាជីវៈ គឺជាការឆ្លើយតបដ៏សមស្របសម្រាប់ការលើកកម្ពស់សកម្មភាពសហការរៀនសូត្រពីគ្នាទៅវិញទៅមករវាងបុគ្គលិកអប់រំ ក្នុងន័យធ្វើឱ្យលទ្ធផលសិក្សារបស់

សិស្សមានភាពប្រសើរឡើង (ហង់ជួន ណារ៉ុន ២០២០)។ សហគមន៍សិក្សាវិជ្ជាជីវៈ ផ្តោតទៅលើការរៀនជាជាងការបង្រៀន តាមរយៈការពិនិត្យលទ្ធផលសិក្សារបស់សិស្ស។ ការផ្លាស់ប្តូររបៀបបង្រៀន និងវាយតម្លៃការសិក្សារបស់សិស្សជារឿងចាំបាច់សម្រាប់ការអប់រំសម័យថ្មី។ ក្នុងន័យនេះ គ្រូបង្រៀនត្រូវផ្តោតលើសំណួរបី៖ ១- តើយើងចង់ឱ្យសិស្សចេះអ្វី? ២- តើយើងដឹងដោយរបៀបណាថាសិស្សទទួលបានចំណេះដឹងដែលបានបង្រៀន? និង ៣- តើយើងត្រូវឆ្លើយតបបែបណានៅពេលដែលសិស្សជួបការលំបាកក្នុងការរៀន? (DuFour, 2004)។ លក្ខណៈពិសេសផ្សេងទៀត គឺ សហគមន៍សិក្សាវិជ្ជាជីវៈ តំណាងឱ្យកិច្ចខិតខំប្រឹងប្រែងរួមគ្នាដើម្បីធ្វើឱ្យរីកចម្រើនដល់ការរៀនរបស់សិស្ស ជួយលើកកម្ពស់និងបន្តនិរន្តរភាពនៃការរៀនសូត្ររបស់បុគ្គលិកអប់រំ កសាងបានចំណេះដឹងតាមរយៈវិធីរិះរក និងវិភាគនិងប្រើប្រាស់ទិន្នន័យក្នុងការឆ្លុះបញ្ចាំងដើម្បីភាពរីកចម្រើន (Bolam et al., 2005)។ សហគមន៍សិក្សាវិជ្ជាជីវៈ គឺជាគំនិតផ្តួចផ្តើមក្នុងកំណែទម្រង់ ជាគំរូនៃការអភិវឌ្ឍរបស់បុគ្គលិកអប់រំ ជាយុទ្ធសាស្ត្រកសាងសមត្ថភាពសាលារៀន ដែលប្រែក្លាយសាលារៀនទៅជាសហគមន៍ដែលមានវិសាលភាពទៅលើថ្នាក់រៀន វិធីសាស្ត្របង្រៀន និងកម្មវិធីសិក្សា ក្នុងការធ្វើឱ្យមានវឌ្ឍនភាពដល់ការរៀនរបស់សិស្ស និងការបង្រៀនរបស់គ្រូ (Mullen, 2009)។ ជាងនេះទៅទៀត សហគមន៍សិក្សាវិជ្ជាជីវៈ ក៏ជំរុញនូវភាពជាអ្នកដឹកនាំរបស់គ្រូបង្រៀន និងការសហការរវាងបុគ្គលិកអប់រំនានាផងដែរ។

ជារួម គេឃើញថា សហគមន៍សិក្សាវិជ្ជាជីវៈ មានសារៈសំខាន់ណាស់ក្នុងការកែទម្រង់និងអភិវឌ្ឍវិស័យអប់រំ ដែលជាការឆ្លើយតបនឹងការអភិវឌ្ឍធនធានមនុស្សប្រកបដោយចំណេះដឹង ជំនាញ និងភាពបត់បែន ដែលនឹងចូលរួមក្នុងការការអភិវឌ្ឍសង្គមនិងសេដ្ឋកិច្ច។ ការបង្កើតនិងដាក់ចេញឱ្យអនុវត្តនូវសហគមន៍សិក្សាវិជ្ជាជីវៈនឹងជាធាតុដ៏សំខាន់សម្រាប់ការរៀនសូត្ររបស់សិស្សានុសិស្សនិងការបង្រៀនរបស់គ្រូ។

## ១.២- ចំណោទបញ្ហានៃការស្រាវជ្រាវ

ការបង្កើតឱ្យមានសហគមន៍សិក្សាវិជ្ជាជីវៈ គឺជាកិច្ចខិតខំប្រឹងប្រែងរបស់ក្រសួងអប់រំ យុវជន និងកីឡា ក្នុងកំណែទម្រង់ស៊ីជម្រៅ ដើម្បីកសាងបាននូវមូលធនមនុស្សសម្រាប់ការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ចក្នុងយុគសម័យឧស្សាហកម្ម៤.០នេះ។ ក្រសួងមានគោលបំណងលើកកម្ពស់ការយល់ដឹងស្តីពីការសហការ ការចែករំលែក ការវិភាគ ការស្រាវជ្រាវប្រតិបត្តិ និងការឆ្លុះបញ្ចាំងទៅលើការរៀននិងបង្រៀន ដើម្បីប្រែក្លាយការងារបង្រៀនទៅជាអាជីព និងធ្វើឱ្យសមត្ថភាពវិជ្ជាជីវៈគ្រូបង្រៀនមានកម្រិតខ្ពស់ដែលអាចទទួលបានការគោរពគាំទ្រពីសង្គម (ក្រសួងអប់រំ យុវជន និងកីឡា ២០២១)។ យ៉ាងណាមិញ គេសង្កេតឃើញថា បញ្ញត្តិសហគមន៍សិក្សាវិជ្ជាជីវៈ ទើបតែត្រូវបានលើកយកមកបង្ហាញថ្មីៗនេះក្នុងប្រទេសកម្ពុជា បើទោះបីជាសហគមន៍សិក្សាវិជ្ជាជីវៈនេះត្រូវបានចាប់អារម្មណ៍ និងអនុវត្តនៅតាមប្រទេសជាច្រើននៅលើពិភពលោកក្តី។ ដូច្នេះ ការស្រាវជ្រាវនេះនឹងសិក្សាអំពីទស្សនៈគ្រូបង្រៀនលើការអនុវត្តសហគមន៍សិក្សាវិជ្ជាជីវៈ និងបញ្ហាប្រឈមដែលកើតមានក្នុងពេលអនុវត្ត។

## ១.៣- គោលបំណងនៃការស្រាវជ្រាវ

ការស្រាវជ្រាវនេះមានគោលបំណង៖

១- សិក្សាអំពីទស្សនៈគ្រូបង្រៀនលើការអនុវត្តសហគមន៍សិក្សាវិជ្ជាជីវៈរបស់គ្រូបង្រៀននៅកម្រិតមធ្យមសិក្សាក្នុងខេត្តកំពង់ចាម។

២- សិក្សាអំពីបញ្ហាប្រឈមដែលកើតមានក្នុងការអនុវត្តសហគមន៍សិក្សាវិជ្ជាជីវៈរបស់គ្រូបង្រៀននៅកម្រិតមធ្យមសិក្សាក្នុងខេត្តកំពង់ចាម។

## ១.៤- សំណួរស្រាវជ្រាវ

ជាការឆ្លើយតបទៅនឹងគោលបំណងស្រាវជ្រាវខាងលើ អ្នកស្រាវជ្រាវបានកំណត់នូវសំណួរស្រាវជ្រាវដូចខាងក្រោម៖

១-   តើគ្រូបង្រៀនមានទស្សនៈបែបណាលើការអនុវត្តសហគមន៍សិក្សាវិជ្ជាជីវៈរបស់គ្រូបង្រៀននៅកម្រិតមធ្យមសិក្សាក្នុងខេត្តកំពង់ចាម?

២-   តើមានបញ្ហាប្រឈមអ្វីខ្លះចំពោះការអនុវត្តសហគមន៍សិក្សាវិជ្ជាជីវៈរបស់គ្រូបង្រៀននៅកម្រិតមធ្យមសិក្សាក្នុងខេត្តកំពង់ចាម?

## ១.៥- ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ

### ១.៥.១- វិសាលភាពនៃការស្រាវជ្រាវ

អ្នកស្រាវជ្រាវនឹងធ្វើការសិក្សាអំពី "ទស្សនៈគ្រូបង្រៀនលើការអនុវត្តសហគមន៍សិក្សាវិជ្ជាជីវៈនៅកម្រិតមធ្យមសិក្សាក្នុងខេត្តកំពង់ចាម"។ (ករណីសិក្សា ៖ សាលារៀនជំនាន់ថ្មីនៃវិទ្យាល័យចំនួន០២ក្នុងខេត្តកំពង់ចាម)។

### ១.៥.២- ដែនកំណត់នៃការស្រាវជ្រាវ

អ្នកស្រាវជ្រាវនឹងធ្វើការស្រាវជ្រាវទៅលើទស្សនៈរបស់គ្រូបង្រៀនកម្រិតមធ្យមសិក្សានៅសាលាជំនាន់ថ្មីនៃវិទ្យាល័យចំនួន០២ក្នុងខេត្តកំពង់ចាម។ មួយ គឺ វិទ្យាល័យ ហ៊ុន សែន ពាមជីកង ស្ថិតក្នុងស្រុកកងមាស និងមួយទៀត គឺ វិទ្យាល័យ ហ៊ុន សែន កំពង់ចាម ស្ថិតក្នុងទីរួមខេត្តកំពង់ចាម។

## ១.៦- សារៈសំខាន់នៃការស្រាវជ្រាវ

ការសិក្សាលើប្រធានបទ "ទស្សនៈគ្រូបង្រៀនលើការអនុវត្តសហគមន៍សិក្សាវិជ្ជាជីវៈនៅកម្រិតមធ្យមសិក្សាក្នុងខេត្តកំពង់ចាម" ផ្តល់នូវប្រយោជន៍មួយចំនួនលើទិដ្ឋភាពនៃការអនុវត្តសហគមន៍សិក្សាវិជ្ជាជីវៈ។ ទីមួយ វានឹងបង្ហាញអំពីទស្សនៈផ្ទាល់របស់គ្រូបង្រៀនកម្រិតមធ្យមសិក្សាក្នុងខេត្តកំពង់ចាមលើការអនុវត្តសហគមន៍សិក្សាវិជ្ជាជីវៈក្នុងកម្រិតមួយជាក់លាក់។ លើសពីនេះទៅទៀត តាមរយៈការសិក្សានេះ គេក៏អាចលើកជាសូចនាករសម្រាប់វាស់វែង និងបង្កើនប្រសិទ្ធភាពនៃការអនុវត្តការងារនៅកម្រិតសាលាផ្ទាល់តែម្តង។ បន្ថែមពីលើការសិក្សាពីទស្សនៈលើការអនុវត្ត ការសិក្សានេះក៏ឆ្លុះបញ្ចាំងឱ្យឃើញពីបញ្ហាប្រឈមជាក់ស្តែង ដែលគណៈគ្រប់គ្រងសាលារៀន និងគ្រូបង្រៀនអាចយកជាធាតុចូលសម្រាប់ជា

ការឆ្លើយតបសមស្រប ដើម្បីលើកកម្ពស់សហគមន៍សិក្សាវិជ្ជាជីវៈនៅសាលារបស់ខ្លួន ។ គ្រូបង្រៀនក៏អាច សិក្សាស្វែងយល់ពីចំណុចដែលជាសំណូមពរសម្រាប់ការអភិវឌ្ឍខ្លួន និងធ្វើឱ្យប្រសើរឡើងនូវសមត្ថភាព វិជ្ជាជីវៈរបស់ខ្លួន ដើម្បីលើកកម្ពស់លទ្ធផលសិក្សារបស់សិស្ស។

## ១.៧- រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

និក្ខេបបទនេះចែកចេញជា៥ជំពូកដូចខាងក្រោម៖

- **ជំពូក១៖** បង្ហាញពីសេចក្តីផ្តើមដែលមាន៧ចំណុច គឺ ១- លំនាំបញ្ហា ២- ចំណោទបញ្ហា ៣- គោលបំណងនៃការស្រាវជ្រាវ ៤- សំណួរស្រាវជ្រាវ ៥- ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ ៦- សារៈសំខាន់នៃការស្រាវជ្រាវ និង៧- រចនាសម្ព័ន្ធនៃការស្រាវជ្រាវ។
- **ជំពូក២៖** ជាផ្នែករំលឹកទ្រឹស្តីដែលលើកយកឯកសារពាក់ព័ន្ធនានាមកធ្វើការពិភាក្សា ដើម្បីគាំទ្រវត្ថុបំណងនៃប្រធានបទស្រាវជ្រាវ។
- **ជំពូក៣៖** ជាផ្នែកវិធីសាស្ត្រស្រាវជ្រាវ ដែលនឹងបង្ហាញពីគម្រោងវិភាគ ការប្រមូលទិន្នន័យ ឧបករណ៍ស្រាវជ្រាវ ការជ្រើសរើសភាគសំណាក និងការវិភាគទិន្នន័យ។
- **ជំពូក៤៖** ជាផ្នែក លទ្ធផល និងការពិភាក្សា ដែលនឹងពិនិត្យ បកស្រាយលម្អិតទៅលើទិន្នន័យដែលបានសិក្សា ដើម្បីរកឱ្យឃើញពីចំណុចខ្វះខាតដែលត្រូវកែលម្អ។
- **ជំពូក៥៖** ជាផ្នែកសន្និដ្ឋាន និងសំណូមពរ ដែលនឹងលើកជាគំនិតសម្រាប់ការសិក្សាបន្ថែមនាពេលអនាគត។

# ជំពូក២

# ការរំលឹកទ្រឹស្តី

នៅក្នុងជំពូកនេះ អត្ថបទនានាដែលជាប់ពាក់ព័ន្ធនឹងប្រធានបទ និងដែលទើបនឹងត្រូវបានសិក្សាស្រាវជ្រាវ ត្រូវបានលើកយកមកបង្ហាញ វិភាគ និងធ្វើសំយោគ។ ការបង្ហាញនៅក្នុងជំពូកនេះរួមមាននិយមន័យនៃសហគមន៍សិក្សាវិជ្ជាជីវៈ បញ្ញត្តិទូទៅនៃសហគមន៍សិក្សាវិជ្ជាជីវៈ និងសកម្មភាពសំខាន់ៗដែលត្រូវធ្វើក្នុងការអនុវត្តសហគមន៍សិក្សាវិជ្ជាជីវៈ។ ទន្ទឹមនឹងនេះដែរ ការសិក្សាស្រាវជ្រាវជាច្រើនស្តីអំពីការអនុវត្តសហគមន៍សិក្សាវិជ្ជាជីវៈ និងបញ្ហាប្រឈមក្នុងការអនុវត្តក៏ត្រូវបានយកមកវិភាគ ដើម្បីស្វែងរកចំណុចបំពេញបន្ថែមទៅលើទ្រឹស្តីដែលមានស្រាប់។

## ២.១- និយមន័យសហគមន៍សិក្សាវិជ្ជាជីវៈ

យោងតាមប្រភពផ្សេងៗ និយមន័យនៃសហគមន៍សិក្សាវិជ្ជាជីវៈត្រូវបានផ្តល់ឱ្យមានភាពផ្សេងៗគ្នា។ DuFour (2004) លើកឡើងថា សហគមន៍សិក្សាវិជ្ជាជីវៈ គឺជាការរួបរួមគ្នារបស់បុគ្គលទាំងឡាយដែលចាប់អារម្មណ៍លើការអប់រំ ដែលអាចជា ក្រុមគ្រូបង្រៀន គណៈកម្មការសាលារៀន ការិយាល័យអប់រំ ក្រសួងអប់រំ ឬអង្គការនានាជាដើម។ និយមន័យមួយទៀត គឺ សហគមន៍សិក្សាវិជ្ជាជីវៈ គឺ ក្រុមគ្រូបង្រៀនដែលចែករំលែក និងជជែកដេញដោលស៊ីជម្រៅទៅលើការអនុវត្តការងារប្រចាំថ្ងៃរបស់ពួកគេ ប្រកបដោយការឆ្លុះបញ្ចាំង ការសហការ បរិយាបន្ន ការផ្តោតលើការរៀន និងការលើកកម្ពស់ការរីកចម្រើន (Stoll & Louis, 2007)។ ក្រសួងអប់រំ យុវជន និងកីឡា (២០២១) បានឱ្យនិយមន័យសហគមន៍សិក្សាវិជ្ជាជីវៈថាជាក្រុមគ្រូបង្រៀន គ្រូឧទ្ទេស និងនាយកសាលា ដែលប្តេជ្ញាធ្វើការងារ រៀនសូត្ររួមគ្នា រៀនសូត្រពីគ្នាទៅវិញទៅមក ក្នុងដំណើរការស្រាវជ្រាវប្រតិបត្តិ ការសិក្សាស្រាវជ្រាវមេរៀន និងស្វ័យឆ្លុះបញ្ចាំងទៅលើការប្រតិបត្តិ ដើម្បីធ្វើឱ្យប្រសើរដល់ទឹកចិត្តក្នុងការបំពេញការងារ លទ្ធផលការងារ និងលទ្ធផលសិក្សារបស់សិស្សដែលពួកគេកំពុងបង្រៀន។

ដូច្នេះ និយមន័យរួមមួយអាចកំណត់បានថា សហគមន៍សិក្សាវិជ្ជាជីវៈ គឺជាការប្រជុំពិភាក្សា ដែលធ្វើជាប្រចាំរវាងតួអង្គអប់រំ ដើម្បីរិះរកមធ្យោបាយធ្វើឱ្យមានការរីកចម្រើនដល់លទ្ធផលការងារ និង ការសិក្សារបស់សិស្ស។

## ២.២- បញ្ញត្តិនានាទាក់ទងនឹងសហគមន៍សិក្សាវិជ្ជាជីវៈ

ការអនុវត្តសហគមន៍សិក្សាវិជ្ជាជីវៈពាក់ព័ន្ធនឹងបញ្ញត្តិមួយចំនួនដែលកំណត់មកមានជាអាទិ៍ គោលការណ៍សំខាន់ៗ៣ វដ្តនៃការចោទសួរ និងសកម្មភាពសំខាន់ដែលអាចអនុវត្តបាន។ ខាងក្រោមនេះ ជាការលើកយកមកបង្ហាញនូវខ្លឹមសារសង្ខេបនៃបញ្ញត្តិខាងលើ។

### ២.២.១- គោលគំនិតសំខាន់ៗចំនួន៣នៃសហគមន៍សិក្សាវិជ្ជាជីវៈ

DuFour (2004) បានលើកឡើងថា ដើម្បីបង្កើតឱ្យបាននូវសហគមន៍សិក្សាវិជ្ជាជីវៈ គេត្រូវផ្តោត លើការរៀនរបស់សិស្ស ធ្វើការសហការ និងយកចិត្តទុកដាក់លើលទ្ធផលសិក្សារបស់សិស្ស។ ក្រសួងអប់រំ យុវជន និងកីឡា (២០២១) បានកំណត់គោលការណ៍ចំនួន៣សម្រាប់ការបង្កើត និងការប្រព្រឹត្តទៅនៃ សហគមន៍សិក្សាវិជ្ជាជីវៈ។ គោលការណ៍ទាំង៣ រួមមាន ១- វប្បធម៌សហការ ២- ការផ្តោតលើលទ្ធផល សិក្សារបស់សិស្ស និង ៣- ការពិភាក្សាឆ្លុះបញ្ចាំង។

**វប្បធម៌សហការ**

អ្នកអប់រំដែលបង្កើតសហគមន៍សិក្សាវិជ្ជាជីវៈទទួលស្គាល់ថា ពួកគេត្រូវតែបង្កើតរចនាសម្ព័ន្ធមួយ ដែលអាចឱ្យពួកគេធ្វើការជាមួយគ្នា ដើម្បីសម្រេចបានគោលបំណងរួមមួយ គឺ ការធ្វើឱ្យប្រសើរឡើងនូវ លទ្ធផលសិក្សារបស់សិស្ស (DuFour, 2004)។ ក្នុងនេះដែរ គ្រូបង្រៀនត្រូវបានផ្តល់ឱកាស អំណាច និង សេរីភាពក្នុងការធ្វើការសហការសិក្សា និងធ្វើផែនការ ព្រមទាំងពិភាក្សាដេញដោលអំពីទស្សនៈ និងការ អនុវត្តការងាររបស់ខ្លួន (ក្រសួងអប់រំ យុវជន និងកីឡា ២០២១)។ ទន្ទឹមនឹងនេះ ការសហការទាមទារឱ្យ មានវប្បធម៌បែបវិជ្ជមាន គោលបំណងរួមគ្នា ការបើកចិត្តទូលាយ ពេលវេលា និងការទទួលស្គាល់ការ អភិវឌ្ឍវិជ្ជាជីវៈ (Henderson, 2018)។

### ការផ្តោតលើលទ្ធផលសិក្សារបស់សិស្ស

សហគមន៍សិក្សាវិជ្ជាជីវៈវាយតម្លៃប្រសិទ្ធភាពនៃការអនុវត្តតាមរយៈលទ្ធផលសិក្សារបស់សិស្ស។ ក្នុងន័យនេះ ក្រុមគ្រូបង្រៀនធ្វើការសហការ ពិភាក្សាធ្វើតេស្តពេញមួយឆ្នាំសិក្សា។ ការធ្វើបែបនេះអាចឱ្យគ្រូបង្រៀនមើលឃើញពីលទ្ធផលសិក្សារបស់សិស្សខ្លួនទៅលើបំណិននានា ដោយប្រៀបធៀបនឹងសិស្សដទៃ (DuFour, 2004)។

### ការពិភាក្សាឆ្លុះបញ្ចាំង

យោងតាម DuFour (2004) បេសកកម្មនៃការអប់រំផ្លូវការ គឺ មិនមែនធានាឱ្យបានថាសិស្សត្រូវបានបង្រៀននោះទេ តែត្រូវធានាថាពួកគេបានរៀន។ នេះមានន័យថា ការរៀនត្រូវការការផ្តោតការយកចិត្តទុកដាក់។ ក្នុងការពិភាក្សា គ្រូបង្រៀនត្រូវផ្តោតលើសំណួរសំខាន់ៗ៣ គឺ ១- តើយើងចង់ឱ្យសិស្សរៀនអ្វី? ២- តើយើងធ្វើយ៉ាងណាទើបដឹងថាសិស្សបានរៀនចេះនូវអ្វីដែលយើងចង់ឱ្យពួកគាត់រៀន និងអ្វីដែលជាបញ្ហាប្រឈមក្នុងការរៀនសូត្ររបស់ពួកគាត់? និង ៣- តើយើងនឹងធ្វើអ្វីវិញ ប្រសិនបើសិស្សមិនបានរៀនចេះនូវអ្វីដែលយើងចង់ឱ្យពួកគាត់រៀននោះ? (ក្រសួងអប់រំ យុវជន និងកីឡា ២០២១)។

## ២.២.២- វដ្តនៃការចោទសួរនៅក្នុងសហគមន៍សិក្សាវិជ្ជាជីវៈ

ចំណុចផ្តោតនៅតាមសាលារៀនសព្វថ្ងៃ គឺ លទ្ធផលសិក្សារបស់សិស្ស។ ដើម្បីសម្រេចបានលទ្ធផលសិក្សាល្អប្រសើររបស់សិស្ស គ្រូបង្រៀន និងថ្នាក់ដឹកនាំសាលារៀនត្រូវផ្តោតការយកចិត្តទុកដាក់លើការរិះរកពីប្រសិទ្ធភាពការអនុវត្តការងាររបស់ខ្លួន។ ការរិះរកមធ្យោបាយនេះផ្តើមចេញពីការចោទសួរ ដែលមានជំហានច្បាស់លាស់មួយ ដែលធានាបាននូវការកសាងបានចំណេះដឹងរួមគ្នាមួយលើទិន្នន័យលទ្ធផលសិក្សារបស់សិស្ស និងជួយឆ្លុះបញ្ចាំងអំពីការអនុវត្តការបង្រៀនកន្លងមក ព្រមទាំងរកឃើញវិធីសាស្ត្រថ្មីសម្រាប់លើកកម្ពស់លទ្ធផលសិក្សារបស់សិស្ស (Carpenter, 2015)។ ជំហានទី១ គឺ ការកំណត់បញ្ហា។ គ្រូបង្រៀនត្រូវពិនិត្យទិន្នន័យទាក់ទងទៅនឹងលទ្ធផលសិក្សារបស់សិស្ស ដើម្បីលើកយកមកពិភាក្សាក្នុងចំណោមគ្រូដទៃទៀត។ ជំហានទី២ គឺ ការវិភាគបញ្ហា។ ការវិភាគបញ្ហាធ្វើឡើងដោយការសហការគ្នារវាង

គ្រូបង្រៀន ដើម្បីរកឱ្យឃើញពីមូលហេតុនៃបញ្ហានោះ។ ជំហានទី៣ គឺ ការធ្វើផែនការ។ ការធ្វើផែនការ គឺជាការលើកឡើងពីសកម្មភាពដែលត្រូវបន្តធ្វើ បន្ទាប់ពីបានរកឃើញពីមូលហេតុនៃបញ្ហា។ ជំហានទី៤ គឺ ការអនុវត្តផែនការ។ បន្ទាប់ពីបានកំណត់នូវសកម្មភាពដែលត្រូវធ្វើរួចហើយ គ្រូបង្រៀនត្រូវយកសកម្មភាពនោះទៅអនុវត្តនៅក្នុងថ្នាក់រៀនរបស់ខ្លួន។ ជំហានទី៥ គឺ ការធ្វើវាយតម្លៃ។ ការវាយតម្លៃត្រូវធ្វើឡើង ដើម្បីដឹងពីប្រសិទ្ធភាពនៃការអនុវត្តសកម្មភាពដែលបានកំណត់។




វដ្តនៃការចោទសួរ (ក្រសួងអប់រំ យុវជន និងកីឡា ២០២១)

### ២.២.៣- សកម្មភាពសំខាន់ៗដែលអាចអនុវត្តបាន

សៀវភៅណែនាំស្តីពីការបង្កើតសហគមន៍សិក្សាវិជ្ជាជីវៈនៅតាមគ្រឹះស្ថានសិក្សាសាធារណៈបានកំណត់យកសកម្មភាពសំខាន់ៗ៣ដែលអាចអនុវត្តបាននៅក្នុងសហគមន៍សិក្សាវិជ្ជាជីវៈ។ សកម្មភាពទាំង ៣ រួមមាន ការស្រាវជ្រាវប្រតិបត្តិ ការសិក្សាស្រាវជ្រាវមេរៀន និងស្វ័យឆ្លុះបញ្ចាំងលើការប្រតិបត្តិ (ក្រសួងអប់រំ យុវជន និងកីឡា ២០២១)។

ការស្រាវជ្រាវប្រតិបត្តិធ្វើឡើងក្នុងគោលបំណងឆ្លើយតបទៅនឹងបញ្ហាជាក់ស្តែងនៅនឹងកន្លែងដោយផ្អែកលើភស្តុតាងដែលបានមកពីការស្រាវជ្រាវ ។ ការសិក្សាប្រតិបត្តិធ្វើឡើងជា៤ដំណាក់កាល គឺ ១- ការកំណត់បញ្ហា ២- ការកសាង និងការអនុវត្តផែនការ ៣- ការប្រមូល និងវិភាគទិន្នន័យ និង ៤- ការប្រើប្រាស់ និងចែករំលែកលទ្ធផល។ បន្ទាប់ពីកំណត់បញ្ហា អ្នកសិក្សាស្រាវជ្រាវចាប់ផ្តើមរៀបចំផែនការដោយកំណត់នូវអ្វីដែលត្រូវធ្វើ មនុស្សដែលត្រូវចូលរួម វេលាដែលត្រូវចាប់ផ្តើម និងទីកន្លែងដែលត្រូវជួប

សម្ភាសន៍ជាដើម។ ជំហានបន្ទាប់ គេត្រូវចុះប្រមូល និងវិភាគទិន្នន័យ តាមរយៈការសម្ភាសន៍ជាបុគ្គល ឬក្រុម។ ទិន្នន័យដែលប្រមូលបាន និងវិភាគរួច ត្រូវយកទៅផ្សព្វផ្សាយចែករំលែក និងអនុវត្តនៅក្នុងថ្នាក់រៀន (ក្រសួងអប់រំ យុវជន និងកីឡា ២០២០)។

ក្រៅអំពីការស្រាវជ្រាវប្រតិបត្តិ ការសិក្សាស្រាវជ្រាវមេរៀនក៏ជាសកម្មភាពចម្បងមួយក្នុងចំណោមសកម្មភាពទាំង៣ដែលអាចអនុវត្តនៅក្នុងសហគមន៍សិក្សាវិជ្ជាជីវៈផងដែរ។ ការសិក្សាស្រាវជ្រាវមេរៀន គឺជាកិច្ចការក្រុមដែលគ្រូបង្រៀនសហការគ្នាពិនិត្យ និងវិភាគទៅលើកិច្ចតែងការបង្រៀន និងជួយផ្តល់ជាវិធីសាស្ត្រ និងការផលិតសម្ភារៈបង្រៀនជាដើម។ ក្នុង១វដ្តនៃការសិក្សាស្រាវជ្រាវមេរៀនមាន ៤ ដំណាក់កាល។ ដំណាក់កាលទី១ គឺ ការរៀបចំមេរៀន។ នៅដំណាក់កាលនេះ គ្រូបង្រៀនត្រូវពិភាក្សា និងធ្វើការចាត់តាំងគ្រូណាម្នាក់ឱ្យត្រៀមឡើងបង្រៀន។ បន្ទាប់ពីទទួលបានការចាត់តាំង គ្រូបង្រៀនរូបនោះត្រូវធ្វើការសិក្សាលើខ្លឹមសារមេរៀន និងរៀបចំកិច្ចតែងការបង្រៀន។ បន្ទាប់ពីធ្វើកិច្ចតែងការរួច ក្រុមទាំងមូលត្រូវធ្វើការសហការពិនិត្យមើលកិច្ចតែងការបង្រៀននោះ។ ចុងក្រោយ ត្រូវផ្តល់មតិកែលម្អ។ ដំណាក់កាលទី២ គឺ ការអនុវត្តការបង្រៀន និងការសង្កេត។ នៅដំណាក់កាលនេះ ក្រុមគ្រូបង្រៀនត្រូវមានឧបករណ៍កត់ត្រានៅពេលគ្រូដែលបានចាត់តាំងឡើងបង្រៀន។ ការចុះសង្កេតនេះផ្តោតលើវិធីបង្រៀនរបស់គ្រូ និងរបៀបរៀនរបស់សិស្ស។ ដំណាក់កាលទី៣ គឺ ការពិភាក្សាលើការបង្រៀន និងរៀន។ នៅដំណាក់កាលនេះ សមាជិកក្រុមទាំងអស់ត្រូវធ្វើការពិភាក្សារិះរកចំណុចដែលត្រូវដកពិសោធន៍ និងចំណុចដែលត្រូវកែលម្អការបង្រៀន។ ដំណាក់កាលចុងក្រោយ គឺ ធ្វើសកម្មភាពកែលម្អបន្ត។ នៅដំណាក់កាលនេះ សមាជិកក្រុមទាំងអស់ជួយជំរុញឱ្យមានការកែលម្អជាបន្ត និងបន្តចាត់តាំងអ្នកដទៃទៀតឱ្យឡើងបង្រៀន ដើម្បីបន្តសិក្សារៀនសូត្រ និងដកពិសោធន៍ពីគ្នាបន្តទៅទៀត (ក្រសួងអប់រំ យុវជន និងកីឡា ២០២១)។

សកម្មភាពសំខាន់ចុងក្រោយ គឺ ស្វ័យឆ្លុះបញ្ចាំងលើការប្រតិបត្តិ។ ស្វ័យឆ្លុះបញ្ចាំង ស្តែងតាមរយៈការពិនិត្យមើលការអនុវត្តការបង្រៀនប្រចាំថ្ងៃផ្ទាល់ខ្លួន និងមានការយល់ដឹងដោយខ្លួនឯង ព្រមទាំងមានការវាយតម្លៃល្អិតល្អន់ទៅលើការអនុវត្តការបង្រៀនរបស់ខ្លួន។ តាមរយៈស្វ័យឆ្លុះបញ្ចាំងលើការប្រតិបត្តិ

គ្រូបង្រៀនអាចរៀនសូត្រពីបទពិសោធន៍ដើម្បីទទួលបានការយល់ដឹងស៊ីជម្រៅទៅលើខ្លួនឯង និងបង្កើតឱ្យមានវប្បធម៌រៀនសូត្រពេញមួយជីវិត (Finlay, 2008)។ ស្វ័យឆ្លុះបញ្ចាំងលើការប្រតិបត្តិត្រូវប្រព្រឹត្តទៅតាមដំណាក់កាលសំខាន់ៗចំនួន៤ គឺ ១- បង្រៀន ២- វាស់ស្ទង់លទ្ធផល ឬសមត្ថភាពបង្រៀនរបស់ខ្លួន ៣- ពិចារណាវិធីថ្មីៗដែលអាចធ្វើឱ្យការសិក្សារបស់សិស្សមានការរីកចម្រើន និង ៤- សាកល្បងអនុវត្តគំនិតថ្មីៗដែលទទួលបានពីអ្នកដទៃឬខ្លួនឯង និងចុងក្រោយធ្វើវាម្តងទៀត (ក្រសួងអប់រំ យុវជន និងកីឡា ២០២១)។

សកម្មភាពសំខាន់ៗចំនួន ៣ ដែលអាចអនុវត្តនៅក្នុងសហគមន៍សិក្សាវិជ្ជាជីវៈដែលត្រូវបានលើកយកមកបង្ហាញខាងលើសុទ្ធសឹងតែបានលើកកម្ពស់វប្បធម៌សហការរវាងគ្រូបង្រៀន និងថ្នាក់ដឹកនាំសាលារៀន។ គោលដៅរួមនៃសកម្មភាពទាំងឡាយខាងលើ គឺ ការជួយជំរុញឱ្យមានការគាំទ្រគ្នាទៅវិញទៅមករវាងគ្រូបង្រៀននិងគ្រូបង្រៀន និងរវាងគ្រូបង្រៀននិងថ្នាក់ដឹកនាំសាលារៀន ដើម្បីធ្វើឱ្យលទ្ធផលសិក្សារបស់សិស្សមានភាពប្រសើរឡើង។ សាលារៀនដែលមានការសហការល្អរវាងក្រុមគ្រូបង្រៀនសម្រេចបាននូវលទ្ធផលការងារល្អប្រសើរ (Ronfeldt et al., 2015)។

## ២.៣- ទស្សនៈលើការអនុវត្តសហគមន៍សិក្សាវិជ្ជាជីវៈ

### ២.៣.១- ការសិក្សាជាក្រុម

ការសិក្សាជាក្រុម ត្រូវបានចាត់ទុកជារបៀបរបបអនុវត្តការងារមួយក្នុងសហគមន៍សិក្សាវិជ្ជាជីវៈ ដែលមានគោលបំណងកំណត់ឱ្យបាននូវផែនការ និងពេលវេលាជាក់លាក់មួយសម្រាប់ការជួបប្រជុំគ្នារបស់គ្រូបង្រៀន។ ការសិក្សាជាក្រុមជួយឱ្យគ្រូបង្រៀនអាចពិភាក្សា និងផ្តល់នូវចំណេះដឹងឱ្យគ្នាទៅវិញទៅមក និងជាលទ្ធផល ការអនុវត្តការងារ និងការសិក្សារបស់សិស្សមានភាពប្រសើរឡើង។ គ្រូបង្រៀនពីរ ឬច្រើននាក់អាចធ្វើការសិក្សាជាមួយគ្នា ដើម្បីឆ្លុះបញ្ចាំងលើការអនុវត្តការងាររបស់ខ្លួន។ វាជាឱកាសដែលគ្រូបង្រៀនអាចសិក្សាស្វែងយល់ពីគ្នាទៅវិញទៅមក និងអាចទទួលបានបទពិសោធន៍ល្អៗ ដែលជួយឱ្យពួកគេអាចឆ្លើយតបបានល្អចំពោះការសិក្សារបស់សិស្ស (Donegan et al., 2000)។ ជាមួយគ្នានេះផងដែរ

ការជួបពិភាក្សាគ្នារបស់ក្រុមគ្រូបង្រៀនបង្កើតបាននូវការយល់គ្នាទៅវិញទៅមក និងបង្កើនការសហការកាន់តែជិតស្និទ្ធ។ ជាការជាក់ស្តែង ការសិក្សាពីគ្នាទៅវិញទៅមករបស់គ្រូ គឺជាមធ្យោបាយមួយដែលជួយបង្កើនទំនុកចិត្ត និងភាពជិតស្និទ្ធដែលជួយដល់ការអភិវឌ្ឍវិជ្ជាជីវៈផងដែរ (Pollara, 2012)។ Gutierez & Kim (2018) បានរកឃើញថា វាជាការចាំបាច់ដែលគ្រូបង្រៀនត្រូវសិក្សាស្វែងយល់ពីបទពិសោធន៍ដោយមានការជួយសហការពីសំណាក់អ្នករួមការងារ ដើម្បីធានាបាននូវភាពរីកចម្រើននៃលទ្ធផលសិក្សាប្រកបដោយគុណភាព។ គាត់បានបន្ថែមទៀតថា ការបង្កើតឱ្យមានសហគមន៍សិក្សាវិជ្ជាជីវៈតាមសាលានឹងជួយឱ្យគ្រូបង្រៀនសិក្សាពីបទពិសោធន៍ក្នុងការអនុវត្តការងារ ព្រោះវាជាមូលដ្ឋានគ្រឹះសម្រាប់ការឆ្លុះបញ្ចាំង និងអនុវត្តការងារបន្តទៅទៀត (Gutierez & Kim, 2018)។

សម្រាប់គ្រូបង្រៀនដែលទើបចេញថ្មី ការសិក្សាជាក្រុមនឹងជួយឱ្យពួកគេអាចរៀនសូត្របានច្រើន និងអាចជំរុញឱ្យការអនុវត្តការងាររបស់ពួកគេមានភាពល្អប្រសើរជាលំដាប់។ ការដកស្រង់បទពិសោធន៍ និងការចែករំលែកបទពិសោធន៍អាចធ្វើទៅបានតាមរយៈការសន្ទនាគ្នាប្រកបដោយទំនុកចិត្ត។ ជាក់ស្តែង ការសិក្សាស្រាវជ្រាវធ្វើឡើងដោយ Rhodes បានបង្ហាញថា ការសិក្សាជាក្រុមសម្រាប់គ្រូទើបចេញថ្មី គឺជាមធ្យោបាយដ៏មានប្រសិទ្ធភាពក្នុងការជួយគាំទ្រពួកគេ។ គាត់បានបន្ថែមផងដែរថា ដើម្បីឱ្យពួកគេអាចប្រើប្រាស់ការសិក្សាជាក្រុមក្នុងការអភិវឌ្ឍនិងឆ្លុះបញ្ចាំងការអនុវត្តការងាររបស់ពួកគេ ពួកគេចាំបាច់ត្រូវការការសន្ទនាផ្លូវការ និងការសិក្សាជាមួយអ្នកមានជំនាញស្របនឹងពួកគេ (Rhodes, 2017)។

## ២.៣.២- ការសង្កេតថ្នាក់

ការសង្កេតថ្នាក់ គឺជាសកម្មភាពមួយក្នុងចំណោមសកម្មភាពដទៃទៀតដែលជួយប្រមូលព័ត៌មានសម្រាប់ឆ្លុះបញ្ចាំង និងកំណត់នូវវិធីសាស្ត្របង្រៀនឱ្យត្រូវនឹងស្ថានភាពជាក់ស្តែងរបស់ថ្នាក់នីមួយៗ។ ជាពិសេស គ្រូដែលទើបចេញថ្មី ឬថ្នាក់ដែលទទួលបានលទ្ធផលសិក្សាទាបនឹងត្រូវទទួលបានការចុះធ្វើការសង្កេត។ ការសង្កេតថ្នាក់នីមួយៗមានផែនការ និងការកត់ត្រាព័ត៌មានច្បាស់លាស់ ដើម្បីឱ្យគេអាចប្រើប្រាស់វាសម្រាប់ឆ្លុះបញ្ចាំងការសង្កេតលើកក្រោយ។ ការសិក្សាមួយរបស់ Vincent នៅឆ្នាំ២០១៨

បានបង្ហាញថា ការសង្កេតថ្នាក់ គឺជាមធ្យោបាយដ៏មានប្រសិទ្ធភាពដែលមានអត្ថប្រយោជន៍ចំពោះអ្នកសង្កេតផង និងចំពោះអ្នកដែលត្រូវបានគេសង្កេតផងដែរ ដោយវាជួយលើកកម្ពស់ការអភិវឌ្ឍវិជ្ជាជីវៈ។ គាត់បានលើកឡើងផងដែរពីការសង្កត់ធ្ងន់របស់អ្នកចូលរួម ដែលបានសំណូមពរឱ្យមានការប្រើប្រាស់ការសង្កេតថ្នាក់ជាការភិវឌ្ឍវិជ្ជាជីវៈ និងផ្តល់ពេលវេលាឱ្យបានគ្រប់គ្រាន់សម្រាប់ការចូលរួមសកម្មភាពសង្កេតថ្នាក់ (Vincent, 2018)។ ការសិក្សាមួយផ្សេងទៀតបានបង្ហាញថា ការសង្កេតថ្នាក់បាននាំមកនូវទំនាក់ទំនងរវាងគ្រូនិងគ្រូ ធ្វើឱ្យការបង្រៀនមានការរីកចម្រើន និងធ្វើឱ្យការចូលរួមរៀនសូត្រកាន់តែប្រសើរឡើង។ បន្ថែមពីនេះទៅទៀត ការសង្កេតថ្នាក់គួរតែធ្វើឡើងជាពិសេសចំពោះគ្រូដែលទើបចេញថ្មី ហើយពាក់ព័ន្ធនឹងការជ្រើសរើសដៃគូសង្កេតគឺត្រូវធ្វើឡើងដោយខ្លួនឯង និងធ្វើឡើងដោយការស្ម័គ្រចិត្ត ដើម្បីកសាងបានការជឿជាក់គ្នាទៅវិញទៅមក និងការសហការរវាងអ្នកចូលរួម (Carroll & O'Loughlin, 2014)។

## ២.៣.៣- ភារកិច្ចរបស់សហគមន៍សិក្សាវិជ្ជាជីវៈ

ភារកិច្ចរបស់សហគមន៍សិក្សាវិជ្ជាជីវៈតម្រូវឱ្យសមាជិកសហគមន៍ចូលរួមអនុវត្តឱ្យបានសកម្មទៅលើចំណុចនានាដែលមានជាអាទិ៍ ការសិក្សាជាក្រុម ការសិក្សាស្រាវជ្រាវមេរៀន ការសង្កេតថ្នាក់រៀន ការប្រឹក្សាចែករំលែកបទពិសោធន៍ និងការឆ្លុះបញ្ចាំងនិងវាយតម្លៃលទ្ធផលសិក្សារបស់សិស្សជាដើម។

ការចូលរួមបំពេញភារកិច្ចបានល្អនៅក្នុងសហគមន៍សិក្សាវិជ្ជាជីវៈនឹងមានផលជះវិជ្ជមានចំពោះអង្គភាពទាំងមូល។ Toole & Louis (2002) បានលើកឡើងថា ការចូលរួមបំពេញភារកិច្ចសហគមន៍សិក្សាវិជ្ជាជីវៈជួយដល់ជីវិតការងារគ្រូបង្រៀន។ វានឹងជួយបង្កើតឱ្យមានបរិស្ថានការងារដែលមានការគាំទ្រ និងបង្កើតបានគន្លងអាជីពដែលទាក់ទាញ និងរក្សាទុកគ្រូបង្រៀន។ លើសពីនេះ វាក៏ជួយដល់ការរៀនសូត្ររបស់គ្រូបង្រៀនផងដែរ។ ការចូលរួមបំពេញភារកិច្ចសហគមន៍សិក្សាវិជ្ជាជីវៈនឹងធ្វើឱ្យការអនុវត្តការងារជាប្រចាំរបស់គ្រូមានការរីកចម្រើនជាប្រចាំ។ ជាពិសេសទៅទៀតនោះ ការចូលរួមបំពេញភារកិច្ច

សហគមន៍សិក្សាវិជ្ជាជីវៈបង្កើតបាននូវវប្បធម៌សាលារៀនដែលមានឥទ្ធិពលដល់ការកំណត់ទុកមុន និងការផ្លាស់ប្តូរនៅសាលារៀន។

**២.៣.៤- អ្នកពាក់ព័ន្ធសំខាន់ៗដែលការគាំទ្រសហគមន៍សិក្សាវិជ្ជាជីវៈ និងប្រព័ន្ធលើកទឹកចិត្ត**

ទន្ទឹមនឹងសកម្មភាពនានាខាងលើ សហគមន៍សិក្សាវិជ្ជាជីវៈក៏ត្រូវការជាចាំបាច់នូវប្រព័ន្ធគាំទ្រមួយច្បាស់លាស់ ដើម្បីធានាបាននូវការអនុវត្តប្រកបដោយប្រសិទ្ធភាព និងនិរន្តរភាព។ អង្គភាពពាក់ព័ន្ធនានាដូចជា អង្គភាពថ្នាក់ក្រសួង មន្ទីរ និងការិយាល័យអប់រំ យុវជន និងកីឡា គ្រឹះស្ថានបណ្តុះបណ្តាលគ្រូ នាយកសាលារៀន និងគ្រូបង្រៀន ត្រូវបានដាក់បញ្ចូលទៅក្នុងសមាសភាពដែលគាំទ្រដល់ការបង្កើត និងអនុវត្តសហគមន៍សិក្សាវិជ្ជាជីវៈនៅតាមសាលារៀន (ក្រសួងអប់រំ យុវជន និងកីឡា ២០២១)។

ការសិក្សានានាក៏បានធ្វើឡើង ដើម្បីស្វែងយល់ស៊ីជម្រៅទៅលើការគាំទ្រសហគមន៍សិក្សាវិជ្ជាជីវៈពីសំណាក់ភាគីពាក់ព័ន្ធនានាផងដែរ។ នៅឆ្នាំ២០១៩ Saad បានធ្វើការសិក្សាអំពីការអនុវត្តសហគមន៍សិក្សាវិជ្ជាជីវៈនៅប្រទេសម៉ាឡេស៊ី និងបានរកឃើញថា ការគាំទ្រពីសំណាក់សាលារៀនផ្ទាល់ចំពោះគ្រូជារឿងចាំបាច់។ ការសិក្សាបានលើកឡើងថា ផែនការយុទ្ធសាស្ត្ររបស់សាលារៀនជាកត្តាសំខាន់ដែលជួយជំរុញការអនុវត្តសកម្មភាពសិក្សាជាក្រុមក្នុងសហគមន៍សិក្សាវិជ្ជាជីវៈ។ ការសិក្សាក៏បានបញ្ជាក់ផងដែរអំពីភាពជាអ្នកដឹកនាំរបស់គ្រូបង្រៀនមានសារៈសំខាន់ក្នុងការអនុវត្តសហគមន៍សិក្សាវិជ្ជាជីវៈនៅតាមសាលារៀន (Saad, 2019)។ បន្ថែមពីលើនេះ ការសិក្សាមួយធ្វើឡើងដោយ Gray & Summers នៅឆ្នាំ២០១៥ បានរកឃើញថា ប្រពៃណីតាមតំបន់ និងច្បាប់ទម្លាប់របស់សាលាមានឥទ្ធិពលលើការអនុវត្តសហគមន៍សិក្សាវិជ្ជាជីវៈ។ ការរីកចម្រើននៃការអនុវត្តសហគមន៍សិក្សាវិជ្ជាជីវៈអាស្រ័យលើការរៀបចំបានល្អប្រសើរនូវរចនាសម្ព័ន្ធសាលារៀន ទំនុកចិត្តលើគណៈគ្រប់គ្រង ទំនុកចិត្តរវាងគ្រូបង្រៀន និងការសម្រេចបានលទ្ធផលរួមគ្នា (Gray & Summers, 2015)។ ដូច្នេះ ភាពជាអ្នកដឹកនាំនៅតាមសាលារៀនមានសារៈសំខាន់ចំពោះការអនុវត្តសហគមន៍សិក្សាវិជ្ជាជីវៈ ហើយវប្បធម៌និងបរិបទសង្គមជាមូលដ្ឋានគ្រឹះដែលមានឥទ្ធិពលលើសហគមន៍សិក្សាវិជ្ជាជីវៈផងដែរ (Hairon & Dimmock, 2012)។

ការគាំទ្រមួយផ្សេងទៀត គឺ ការចូលរួមផ្ទាល់ពីសំណាក់គ្រូបង្រៀន។ តាមរយៈការយល់ដឹងពីសារៈសំខាន់នៃភាពជាអ្នកដឹកនាំ គ្រូបង្រៀនចាប់ផ្តើមមានអារម្មណ៍ថាមានតម្លៃដោយសារតែសមត្ថភាពវិជ្ជាជីវៈត្រូវបានទទួលស្គាល់ និងនាំឱ្យវប្បធម៌នៃការសហការចែករំលែក និងគាំទ្រកើតមានឡើង។ នៅឆ្នាំ ២០១១ Kaminski បានធ្វើការសិក្សាលើការរៀបចំ ការអនុវត្ត និងការធ្វើតេស្តលើការអនុវត្តសហគមន៍សិក្សាវិជ្ជាជីវៈ។ ការសិក្សាបានផ្តោតសំខាន់ទៅលើការផ្តល់សិទ្ធិអំណាចដល់បុគ្គលិក ការផ្តល់ឱ្យបុគ្គលិកបានធ្វើការឆ្លុះបញ្ចាំង ការសហការ និងភាពជាអ្នករួមការងារក្នុងបរិស្ថានអប់រំ (Kaminski, 2011)។ Eyanagho (2019) បានរកឃើញផងដែរថា ឱកាសរបស់គ្រូបង្រៀនក្នុងការឆ្លុះបញ្ចាំងពីចំណេះដឹងដែលពួកគេទទួលបានពីការប្រជុំសហគមន៍សិក្សាវិជ្ជាជីវៈ មានឥទ្ធិពលលើការអនុវត្តការបង្រៀន និងមានផលជះលើការសិក្សារបស់សិស្ស (Eyanagho, 2019)។ ហើយដើម្បីឱ្យសហគមន៍សិក្សាវិជ្ជាជីវៈអាចមាននិរន្តរ-ភាពទៅបាន វប្បធម៌សាលារៀនត្រូវត្រឡប់ទៅផ្តោតការយកចិត្តទុកដាក់លើការសហការ និងផ្តោតលើការសិក្សា និងភាពជាអ្នកដឹកនាំដែលមានការចែករំលែក និងការគាំទ្រ ដោយប្រើប្រាស់ទិន្នន័យស្រាវជ្រាវក្នុងការប្រព្រឹត្តទៅនៃការបង្រៀន (Hefner, 2011)។ ការផ្តល់ឱ្យបែបនេះនឹងជាឱកាសសម្រាប់គ្រូបង្រៀនក្នុងការកសាងបាននូវទំនាក់ទំនងល្អ ភាពជិតស្និទ្ធ ទំនុកចិត្ត និងការកសាងបាននូវរចនាសម្ព័ន្ធក្រុម និងភាពជាអ្នកដឹកនាំ (Held, 2017)។ ការសិក្សាស្រាវជ្រាវមួយផ្សេងទៀតធ្វើឡើងដោយ Somprach et al. (2007) នៅសាលាមួយចំនួននៅប្រទេសថៃបានបង្ហាញថា នាយកសាលា និងគ្រូបង្រៀននៅទីនោះបានចូលរួមយ៉ាងសកម្មក្នុងសហគមន៍សិក្សាវិជ្ជាជីវៈ។ ការសិក្សាក៏បានបង្ហាញដែរថា ការចូលរួមយ៉ាងសកម្មក្នុងសហគមន៍សិក្សាវិជ្ជាជីវៈពីសំណាក់គ្រូបង្រៀនកើតឡើងដោយសារតែចំណេះដឹងអំពីភាពជាអ្នកដឹកនាំរបស់នាយកសាលា ដែលជួយនាំផ្លូវឱ្យពួកគាត់ឱ្យអាចជំរុញទឹកចិត្តគ្រូបង្រៀន និងជាលទ្ធផល ការសិក្សារបស់សិស្សមានភាពរីកចម្រើន (Somprach et al., 2017)។

បន្ថែមពីលើនេះទៅទៀត ការលើកទឹកចិត្តក្នុងសហគមន៍សិក្សាវិជ្ជាជីវៈជាកត្តាចាំបាច់ក្នុងការជំរុញការចូលរួមរបស់សមាជិកសហគមន៍ក្នុងការអនុវត្តសហគមន៍សិក្សាវិជ្ជាជីវៈឱ្យកាន់តែប្រសើរខ្លាំងឡើង។

ការលើកទឹកចិត្តអាចធ្វើឡើងតាមរយៈការផ្តល់ឱកាសដល់សមាជិកសហគមន៍ចូលរួមក្នុងកម្មវិធីអភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈ ការផ្តល់ពេលវេលាគ្រប់គ្រាន់ ការផ្តល់ជំនួយបច្ចេកវិទ្យា ឬការផ្តល់ជារង្វាន់ជាដើម។ ក្រៅអំពីការលើកទឹកចិត្តបែបនេះ ការបង្កឱ្យមានភាពពេញចិត្ត ការចែករំលែក និងការយល់គ្នាទៅវិញទៅមកក្នុងសហគមន៍ក៏ត្រូវបានចាត់ទុកថាជាការលើកទឹកចិត្តផងដែរ (Beemt et al., 2018)។

## ២.៣.៥- ទស្សនៈលើការអនុវត្តសហគមន៍សិក្សាវិជ្ជាជីវៈ និងលទ្ធផលសិក្សារបស់សិស្ស

គុណភាពនៃការអប់រំត្រូវពឹងផ្អែកជាចាំបាច់លើគុណភាពនៃការបង្រៀន និងអាចឆ្លុះបញ្ចាំងបានតាមរយៈលទ្ធផលសិក្សារបស់សិស្ស។ ការកំណត់យកលទ្ធផលសិក្សារបស់សិស្សជារឿងចម្បង គឺជាអ្វីដែលសហគមន៍សិក្សាវិជ្ជាជីវៈផ្តោតការយកចិត្តទុដាក់។ ហេតុនេះ ក្នុងការអនុវត្តសហគមន៍សិក្សាវិជ្ជាជីវៈ លទ្ធផលសិក្សារបស់សិស្សត្រូវបានកំណត់យកជាចំណុចស្នូលនៃកិច្ចការងាររបស់គ្រូបង្រៀន។ ការសិក្សាជាច្រើនបានបង្ហាញឱ្យឃើញពីទស្សនៈរបស់គ្រូបង្រៀនលើការអនុវត្តសហគមន៍សិក្សាវិជ្ជាជីវៈ ក្នុងបរិបទនានា។ លទ្ធផលនៃការសិក្សាមួយបានបង្ហាញថា សហគមន៍សិក្សាវិជ្ជាជីវៈមានផលជះវិជ្ជមានទៅលើប្រសិទ្ធភាពរបស់គ្រូបង្រៀនក្នុងការជួយឱ្យសិស្សអាចទទួលបានលទ្ធផលសិក្សាល្អនៅគ្រប់កម្រិតសិក្សា ជាពិសេស នៅកម្រិតបឋមសិក្សា (Bailey, 2016)។ East (2015) បានធ្វើការសិក្សាមួយអំពីការអនុវត្តសហគមន៍សិក្សាវិជ្ជាជីវៈ នៅសាលារៀននៅ West Virginia។ គាត់បានរកឃើញថា ការអនុវត្តសហគមន៍សិក្សាវិជ្ជាជីវៈស្ថិតនៅកម្រិតមួយល្អ និងជួយឱ្យការសិក្សារបស់សិស្សមានការរីកចម្រើន (East, 2015)។ Voelkel Jr & Chrispeels (2017) ក៏បានសិក្សា និងរកឃើញថា ការអនុវត្តសហគមន៍សិក្សាវិជ្ជាជីវៈ បានកាន់តែល្អ ទំនុកចិត្តរបស់គ្រូបង្រៀនក៏កាន់តែកើនឡើង ដែលជាធាតុយ៉ាងសំខាន់ជួយជំរុញឱ្យលទ្ធផលសិក្សារបស់សិស្សមានភាពប្រសើរឡើង (Voelkel Jr & Chrispeels, 2017)។

## ២.៤- បញ្ហាប្រឈមក្នុងការអនុវត្តសហគមន៍សិក្សាវិជ្ជាជីវៈ

យោងតាមការសិក្សាស្រាវជ្រាវនានា បញ្ហាប្រឈមមួយចំនួនបានកើតមានឡើងក្នុងពេលអនុវត្តសហគមន៍សិក្សាវិជ្ជាជីវៈ។ បញ្ហាប្រឈមទាំងនោះរួមមាន បន្ទុកការងារនិងឧបសគ្គពេលវេលា ការយល់ដឹងមិនបានច្បាស់ពីសហគមន៍សិក្សាវិជ្ជាជីវៈ កង្វះខាតវប្បធម៌ពិភាក្សា កង្វះវប្បធម៌សហការ និងកង្វះទំនុកចិត្ត ជាដើម។

បញ្ហាប្រឈមទី១ គឺ បន្ទុកការងារនិងឧបសគ្គពេលវេលា។ បន្ទុកការងារនិងឧបសគ្គពេលវេលាធ្វើឱ្យការអនុវត្តសហគមន៍សិក្សាវិជ្ជាជីវៈមិនអាចសម្រេចបានលទ្ធផលល្អប្រសើរ។ ការចំណាយពេលក្នុងការប្រជុំសហគមន៍សិក្សាវិជ្ជាជីវៈប៉ះពាល់ដល់ពេលវេលាបំពេញការងារស្នូលដែលមានចំនួនច្រើន។ នៅឆ្នាំ ២០១៧ Hairon & Tan បានធ្វើការសិក្សាពីការអនុវត្តសហគមន៍សិក្សាវិជ្ជាជីវៈ នៅប្រទេសសឹង្ហបុរី។ លទ្ធផលបានបង្ហាញថា ឧបសគ្គរាំងស្ទាំងចម្បងសម្រាប់ការប្តេជ្ញាចិត្តអនុវត្តសហគមន៍សិក្សាវិជ្ជាជីវៈ គឺបន្ទុកការងារធ្ងន់ធ្ងរ។ បន្ទុកការងារនេះកើតចេញពីតម្រូវការកើនឡើងដែលដាក់ចេញដោយអ្នកពាក់ព័ន្ធរួមមានដូចជា អ្នកកសាងគោលនយោបាយ អាណាព្យាបាល និងថ្នាក់លើ (Hairon & Tan, 2017)។ ការសិក្សារបស់ Tayag (2020) រកឃើញផងដែរថា ជំនួសឱ្យការចូលរួមប្រជុំ គ្រូបង្រៀនជ្រើសរើសយកការប្រើពេលវេលានេះសម្រាប់បំពេញការងារមួយចំនួនដូចជា ការប្រឹក្សាយោបល់ដល់សិស្ស ការរៀបចំសម្ភារៈបង្រៀន និងការវាយតម្លៃលទ្ធផលសិក្សារបស់សិស្សជាដើម។ គ្រូបង្រៀនមិនអាចចូលរួមក្នុងការប្រជុំឱ្យបានពេញលេញ ដោយសារតែហេតុផលកិច្ចការរដ្ឋបាលច្រើនដែលត្រូវបំពេញ និងដោយហេតុផលថា នាយកសាលាបានជំរុញឱ្យការប្រជុំមានលក្ខណៈសង្ខេបខ្លី (Tayag, 2020)។ ការសិក្សានៅវិទ្យាល័យមួយនៅប្រទេសម៉ាឡេស៊ីក៏បានរកឃើញបញ្ហាប្រឈមដែលជាបន្ទុកការងារផងដែរ។ ការស្រាវជ្រាវនោះបានបង្ហាញថា គ្រូបង្រៀនមិនត្រឹមតែមានការងារបង្រៀនដែលត្រូវធ្វើនោះទេ តែនៅមានកិច្ចការរដ្ឋបាលជាច្រើនទៀតដែលត្រូវបំពេញ។ ដូច្នេះ ពួកគាត់មានការលំបាកក្នុងការស្វែងរកពេលវេលាមកជួបប្រជុំសហគមន៍ណាស់ (Chua et al., 2020)។

បញ្ហាប្រឈមទី២ គឺ ការយល់ដឹងមិនបានច្បាស់ពីសហគមន៍សិក្សាវិជ្ជាជីវៈ។ ការយល់ខុសចំពោះការអនុវត្តសហគមន៍សិក្សាវិជ្ជាជីវៈជាបញ្ហាចោទក្នុងចំណោមគណៈគ្រប់គ្រងសាលា និងគ្រូបង្រៀន។ ហេតុផលចម្បងចំពោះការយល់ដឹងមិនច្បាស់នេះកើតចេញកង្វះខាតឯកសារពិស្តារស្តីពីនីតិវិធីណែនាំអំពីការអនុវត្តសហគមន៍សិក្សាវិជ្ជាជីវៈ ដោយមិនមានឯកសារជាដុំកំភួនណាមួយដែលរៀបរាប់ពិស្តារពីតួនាទីនៃសហគមន៍សិក្សាវិជ្ជាជីវៈ ឬពីរបៀបអនុវត្តសហគមន៍សិក្សាវិជ្ជាជីវៈជាលក្ខណៈពិស្តារនៅឡើយទេ។ ក្នុងហេតុផលនេះ ប្រសិនបើគេនិយាយពីការចងក្រងឯកសារស្តីពីការអនុវត្តសហគមន៍វិជ្ជាជីវៈនៅតំបន់ក្រៅពីអឺរ៉ុប អាម៉េរិក រឹងរឹតតែមានការខ្វះខាត (Hairon & Tan, 2017)។ ជាឧទាហរណ៍ជាក់ស្តែង ការយល់ខុសចំពោះការអនុវត្តសហគមន៍សិក្សាវិជ្ជាជីវៈ គឺ ការយល់ឃើញខុសចំពោះការប្រជុំសហគមន៍សិក្សាវិជ្ជាជីវៈ។ ក្នុងហេតុផលនេះ ការសិក្សារបស់ Chau et al. (2020) បានរកឃើញថា នាយកសាលាមួយចំនួនមើលឃើញការប្រជុំសហគមន៍សិក្សាវិជ្ជាជីវៈថាជាការប្រជុំមួយដោយគ្រាន់ផ្តោតទៅលើការកំណត់ពីអ្វីដែលត្រូវបង្រៀន ពីអ្វីដែលមាននៅក្នុងកម្មវិធីសិក្សា និងពីកិច្ចការដែលនឹងដាក់ឱ្យសិស្សធ្វើតែប៉ុណ្ណោះ។ រីឯនាយកសាលាមួយចំនួនទៀតយល់ថាការប្រជុំសហគមន៍សិក្សាវិជ្ជាជីវៈជាការឱ្យសិស្សចូលរួមក្នុងសកម្មភាពថ្នាក់រៀន ដូចជា ការធ្វើ Gallery Walk ក្នុងថ្នាក់រៀន ជាដើមទៅវិញ។

បញ្ហាប្រឈមទី៣ គឺ កង្វះវប្បធម៌ពិភាក្សាគ្នា។ ជាការពិត ការអនុវត្តការងារកន្លងមក គ្រូបង្រៀនភាគច្រើនចូលចិត្តធ្វើការតែឯង និងព្យាយាមលាក់បាំងការលំបាករបស់ខ្លួន ក្នុងន័យរក្សាមុខមាត់។ ដូច្នេះ ការពិភាក្សាបែបបើកទូលាយ គឺជារឿងថ្មីដែលពិបាកក្នុងការសម្របខ្លួនទទួលយកភ្លាមៗ។ ឧទាហរណ៍ជាក់ស្តែង ការសិក្សាស្រាវជ្រាវបង្ហាញថា នៅក្នុងសាលាមួយចំនួន សហគមន៍សិក្សាវិជ្ជាជីវៈជួបប្រទះនូវការជំទាស់ពីសំណាក់គ្រូបង្រៀនដែលមិនបានស្គាល់របៀបធ្វើការ ឬដែលមានការសង្ស័យចំពោះការធ្វើការជាក្រុម (Harris & Jones, 2010)។ ជាងនេះទៅទៀត ការសិក្សាមួយនៅប្រទេសកូរ៉េខាងត្បូងក៏បានបង្ហាញពីកង្វះទំនុកចិត្តលើការពិភាក្សា។ គ្រូបង្រៀនមានអារម្មណ៍ថាខ្លួនហាក់មិនទទួលបានអ្វីសោះពីការ

ចូលរួមក្នុងការពិភាក្សានោះ។ នេះជាមូលហេតុមួយដែលនាំឱ្យគេមើលឃើញការពិភាក្សាថាមិនសូវជាជួយដល់ការអនុវត្តការងារបង្រៀននោះទេ (Park & So, 2014)។

បញ្ហាប្រឈមទី៤ គឺ ឥរិយាបថអសកម្មរបស់គ្រូបង្រៀន។ គ្រូបង្រៀនភាគច្រើនមានអារម្មណ៍ថាខ្លួនធ្វើបានត្រឹមត្រូវក្នុងការអនុវត្តការងាររបស់ខ្លួន និងមានការស្ទាក់ស្ទើរក្នុងការសួរយោបល់ពីអ្នកដទៃ។ Chua et al. បានគូសបញ្ជាក់ថា រឿងបែបនេះច្រើនតែកើតឡើងក្នុងចំណោមគ្រូបង្រៀនដែលមានបទពិសោធន៍យូរឆ្នាំ និងដែលមិនមានបំណងសួរនាំយោបល់ពីអ្នកដទៃ។ ការសិក្សារបស់គាត់ធ្វើឡើងនៅសាលារៀនដែលមានគ្រូបង្រៀនជាជនជាតិចិនភាគច្រើន។ ដូច្នេះ វប្បធម៌ថែរក្សាមុខមាត់អាចជាកត្តារាំងស្ទះដល់ការបើកចិត្តឱ្យទូលាយក្នុងការសួរនាំយោបល់ពីអ្នកដទៃ។ ការសិក្សាមួយផ្សេងទៀតធ្វើឡើងដោយ Park & So នៅឆ្នាំ២០១៤ ក៏បានរកឃើញបញ្ហាប្រឈមស្រដៀងគ្នានេះដែរ ដែលពួកគាត់បានហៅថាជា ឧបសគ្គចិត្តវិទ្យា។ ក្នុងន័យនេះ Park & So សំដៅដល់បញ្ហាដែលពាក់ព័ន្ធដល់ហានិភ័យផ្ទាល់ខ្លួន។ នៅក្នុងប្រទេសកូរ៉េ ការបើកចំហកិច្ចការថ្នាក់រៀនទៅកាន់គ្រូបង្រៀនដទៃជារឿងថ្មីនៅឡើយ។ ស្រដៀងគ្នាទៅនឹងគ្រូជនជាតិចិននៅសាលាដែល Chua et al. បានសិក្សាដែរ គ្រូបង្រៀនជនជាតិកូរ៉េមានការភ័យខ្លាចចំពោះការបង្ហាញបញ្ហាថ្នាក់រៀនរបស់ខ្លួនទៅកាន់គ្រូបង្រៀនដទៃ និងការទទួលយកការវាយតម្លៃពីគ្រូបង្រៀនដទៃ។

បញ្ហាប្រឈមទី៥ គឺ កង្វះទំនុកចិត្តលើគ្រូបង្រៀនដទៃ។ ដើម្បីអនុវត្តសហគមន៍សិក្សាវិជ្ជាជីវៈបានជោគជ័យ គេត្រូវការកសាងទំនុកចិត្តក្នុងចំណោមគ្រូបង្រៀន ព្រមទាំងភាគីពាក់ព័ន្ធទាំងឡាយ។ កង្វះទំនុកចិត្តបណ្ដាលឱ្យមានឧបសគ្គចំពោះការពិភាក្សាបើកទូលាយលើបញ្ហាការអនុវត្តការងារ និងការសិក្សារបស់សិស្ស។ ឧទាហរណ៍ជាក់ស្ដែង ការសិក្សាស្រាវជ្រាវមួយបានបង្ហាញថា គ្រូបង្រៀនមានការស្ទាក់ស្ទើរក្នុងការចែករំលែកអ្វីដែលគាត់មាន និងអ្វីដែលបានអនុវត្តទៅកាន់គ្រូដទៃ បន្ទាប់ពីត្រូវបានទទួលការរិះគន់ នៅពេលដែលគាត់បង្ហាញនៅលើកដំបូង (Tayag, 2020)។

ជំពូកនេះបានលើកឡើងពីបញ្ញត្តិសំខាន់ៗនៃសហគមន៍សិក្សាវិជ្ជាជីវៈ ការអនុវត្ត និងបញ្ហាប្រឈមដែលមានកន្លងមក។ យ៉ាងណាមិញ ទាំងអស់នេះសុទ្ធសឹងតែធ្វើឡើងក្នុងបរិបទនៅប្រទេសនានាក្រៅអំពីប្រទេសកម្ពុជា។ ដូច្នេះ ការសិក្សាអំពីសហគមន៍សិក្សាវិជ្ជាជីវៈក្នុងបរិបទប្រទេសកម្ពុជា គឺជាការចាំបាច់សម្រាប់ការអនុវត្តប្រកបដោយប្រសិទ្ធភាពនៅតាមសាលារៀនក្នុងប្រទេស។ ការសិក្សាបន្ថែមធ្វើឡើងក្នុងគោលបំណងស្វែងយល់ពីការអនុវត្តចំបរិបទ ព្រោះការអនុវត្តសហគមន៍សិក្សាវិជ្ជាជីវៈទាមទារឱ្យមានការពិនិត្យកែលម្អជាប្រចាំ ដូចដែល Stewart (2017) បានធ្វើការសិក្សាលើទស្សនៈគ្រូបង្រៀន និងរកឃើញថា កាអនុវត្តសហគមន៍សិក្សាវិជ្ជាជីវៈមានអត្ថប្រយោជន៍ តែត្រូវការការកែលម្អទៅលើភាពពាក់ព័ន្ធបំណងប្រាថ្នា និងការធ្វើផែនការអនុវត្ត (Stewart, 2017)។

# ជំពូក៣

# វិធីសាស្ត្រនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវស្តីពី **"ទស្សនៈគ្រូបង្រៀនលើការអនុវត្តសហគមន៍សិក្សាវិជ្ជាជីវៈនៅកម្រិតមធ្យមសិក្សាក្នុងខេត្តកំពង់ចាម"** មានគោលបំណងសិក្សាពីការអនុវត្ត និងបញ្ហាប្រឈមក្នុងការអនុវត្តសហគមន៍សិក្សាវិជ្ជាជីវៈនៅកម្រិតមធ្យមសិក្សា នៅសាលារៀនជំនាន់ថ្មីក្នុងខេត្តកំពង់ចាម (វិទ្យាល័យ ហ៊ុន សែន កំពង់ចាម និងវិទ្យាល័យ ហ៊ុន សែន ពាមជីកង)។ វិធីសាស្ត្រនៃការស្រាវជ្រាវធ្វើឡើងតាមបែបបរិមាណវិស័យ។

## ៣.១- គម្រោងវិភាគ

អ្នកស្រាវជ្រាវប្រើប្រាស់កម្រងសំណួរដែលកសាងឡើងដោយផ្អែកលើ "សៀវភៅណែនាំស្តីពីការបង្កើតសហគមន៍សិក្សាវិជ្ជាជីវៈនៅតាមគ្រឹះស្ថានសិក្សាសាធារណៈ" សម្រាប់គ្រូបង្រៀន និងសម្រាប់គណៈគ្រប់គ្រង ដើម្បីឆ្លើយតបសំណួរស្រាវជ្រាវទាំងពីរនៃប្រធានបទ។ អនុលោមតាមផែនការនៃការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ដែលមានរយៈពេលកំណត់ជាក់លាក់ អ្នកស្រាវជ្រាវអាចបញ្ចប់ការសរសេរនិក្ខេបបទ និងឡើងការពារកិច្ចការស្រាវជ្រាវនៅចន្លោះថ្ងៃទី០៥-០៦ ខែវិច្ឆិកា ឆ្នាំ២០២២ តាមការគ្រោងទុក។ ការចុះប្រមូលទិន្នន័យធ្វើឡើងនៅសាលារៀនជំនាន់ថ្មីចំនួនពីរក្នុងខេត្តកំពង់ចាម។ ក្រុមគោលដៅដែលបំពេញកម្រងសំណួរ ជាគ្រូបង្រៀនមធ្យមសិក្សា និងគណៈគ្រប់គ្រងនៃសាលាទាំងពីរ។

## ៣.២- ការប្រមូលទិន្នន័យ

បន្ទាប់ពីទទួលបានលិខិតឧទ្ទេសនាមពីក្រសួងអប់រំ យុវជន និងកីឡា លេខ ២៣៤១ អយក.វជអ ចុះថ្ងៃសុក្រ ១៣រោច ខែចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២២ ស្តីពីការចុះប្រមូលទិន្នន័យដើម្បីសរសេរនិក្ខេបបទបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៩ អ្នកស្រាវជ្រាវបានឆ្លងយោបល់ពីសំណាក់គ្រូណែនាំគោល និងគ្រូណែនាំរង និងបានរៀបចំកម្រងសំណួរ ដើម្បីចុះប្រមូលទិន្នន័យ។ បន្ទាប់ពីបានការឯកភាពពីសំណាក់គ្រូណែនាំគោល និង

គ្រូណែនាំរងរួចមក អ្នកស្រាវជ្រាវបានយកលិខិតឧទ្ទេសនាមនេះភ្ជាប់ជាមួយដោយលិខិតស្នើសុំចុះប្រមូលទិន្នន័យទៅជូនលោកប្រធានមន្ទីរអប់រំ យុជន និងកីឡាខេត្តកំពង់ចាម ដើម្បីពិនិត្យ និងអនុញ្ញាតឱ្យអ្នកស្រាវជ្រាវបានចុះប្រមូលទិន្នន័យ។ បន្ទាប់មក អ្នកស្រាវជ្រាវបានចុះទៅជួបនាយកសាលានីមួយៗ ដើម្បីជូនលិខិតឧទ្ទេសនាម និងលិខិតស្នើសុំចុះប្រមូលទិន្នន័យ និងបានស្នើសុំជួបក្រុមគោលដៅបំពេញកម្រងសំណួរដែលជាគ្រូបង្រៀន ដើម្បីផ្ដល់កម្រងសំណួរ ព្រមទាំងជម្រាបអំពីពេលវេលាដែលត្រូវសុំប្រមូលកម្រងសំណួរមកវិញ។

ការចុះប្រមូលទិន្នន័យប្រើប្រាស់ពេលវេលា២៥ថ្ងៃ គឺ ចាប់ពីថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០២២ រហូតដល់ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០២២។

## ៣.៣- ឧបករណ៍ស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវស្ដីពី **“ទស្សនៈគ្រូបង្រៀនលើការអនុវត្តសហគមន៍សិក្សាវិជ្ជាជីវៈនៅកម្រិតមធ្យមសិក្សា ក្នុងខេត្តកំពង់ចាម**” ប្រើប្រាស់កម្រងសំណួរក្នុងការប្រមូលទិន្នន័យតាមបែបបរិមាណវិស័យពីគ្រូបង្រៀន និងគណៈគ្រប់គ្រង។

កម្រងសំណួរត្រូវបានកសាងឡើងដោយអ្នកស្រាវជ្រាវ ដោយផ្អែកលើ “សៀវភៅណែនាំស្ដីពីការបង្កើតសហគមន៍សិក្សាវិជ្ជាជីវៈនៅតាមគ្រឹះស្ថានសិក្សាសាធារណៈ” របស់ក្រសួងអប់រំ យុវជន និងកីឡា ដែលចេញផ្សាយនៅឆ្នាំ២០២១។ កម្រងសំណួរត្រូវបានដាក់ជូនគ្រូណែនាំគោល និងគ្រូណែនាំរង ពិនិត្យ និងសម្រេចឱ្យប្រើប្រាស់ក្នុងការប្រមូលទិន្នន័យ។

### ៣.៣.១- កម្រិតចង្អុលបង្ហាញ

កម្រិតចង្អុលបង្ហាញនៃការសិក្សាស្រាវជ្រាវប្រធានបទខាងលើមានចំនួន ៥ កម្រិត ដែលប្រើប្រាស់តាមបែប Likert Scale។ តួលេខ១ដល់៥ត្រូវបានប្រើប្រាស់ដើម្បីវាស់វែងសូចនាករវាយតម្លៃកម្រិតនៃការអនុវត្តសហគមន៍វិជ្ជាជីវៈរបស់គ្រូបង្រៀននៅសាលារៀនជំនាន់ថ្មី។ កម្រិតចង្អុលបង្ហាញនេះរាប់ពីទាបទៅខ្ពស់៖

កម្រិត ១ = មិនយល់ស្របទាល់តែសោះ

កម្រិត ២ = មិនយល់ស្រប

កម្រិត ៣ = ពុំមានយោបល់

កម្រិត ៤ = យល់ស្រប

កម្រិត ៥ = យល់ស្របខ្លាំង

រូបមន្តខាងក្រោមត្រូវបានប្រើប្រាស់ ដើម្បីបកស្រាយការគណនាពិន្ទុមធ្យមភាគនៃសូចនាករនីមួយៗ៖

$$\frac{\text{ពិន្ទុខ្ពស់បំផុត} - \text{ពិន្ទុទាបបំផុត}}{\text{ចំនួនកម្រិតចង្អុលបង្ហាញ}} = \frac{5-1}{5} = 0.80$$

១.០០ ដល់ ១.៨០ មានន័យថា ខ្សោយណាស់

១.៨១ ដល់ ២.៦០ មានន័យថា ខ្សោយ

២.៦១ ដល់ ៣.៤០ មានន័យថា មធ្យម

៣.៤១ ដល់ ៤.២០ មានន័យថា ល្អ

៤.២១ ដល់ ៥.០០ មានន័យថា ល្អណាស់

### ៣.៣.២- កម្រងសំណួរ

អ្នកស្រាវជ្រាវប្រើប្រាស់កម្រងសំណួរសម្រាប់គ្រូបង្រៀន ដើម្បីសិក្សាពីទស្សនៈលើការអនុវត្តសហគមន៍សិក្សាវិជ្ជាជីវៈនៅកម្រិតមធ្យមសិក្សានៅសាលារៀនជំនាន់ថ្មីក្នុងខេត្តកំពង់ចាម។ កម្រងសំណួរនេះចែកចេញជា៣ផ្នែក។

ផ្នែកទី១ គឺជាព័ត៌មានប្រជាសាស្ត្រ ដែលសួរអំពីតួនាទី ភេទ អាយុ មុខវិជ្ជាឯកទេស កម្រិតថ្នាក់បង្រៀន ទីកន្លែងការងារ កម្រិតវប្បធម៌ និងបទពិសោធន៍ការងារ។

ផ្នែកទី២ គឺជាសំណួរទាក់ទងនឹងការអនុវត្តសហគមន៍សិក្សាវិជ្ជាជីវៈ ដែលបែងចែកបន្តជា០២ ចំណុចទៀត គឺ ១- របៀបរបបអនុវត្តការងារ (មាន ៣១ សូចនាករ) និង ២- ប្រព័ន្ធគាំទ្រសហគន៍សិក្សាវិជ្ជាជីវៈ (មាន ៣១ សូចនាករ)។

ផ្នែកទី៣ គឺជាសំណួរទាក់ទងនឹងបញ្ហាប្រឈមក្នុងការអនុវត្តសហគមន៍សិក្សាវិជ្ជាជីវៈ ដែលមាន ១៧សូចនាករ។

## ៣.៤- ប្រជាជន និងភាគសំណាក

### ៣.៤.១- ប្រជាជន

ដោយសារសហគមន៍សិក្សាវិជ្ជាជីវៈទើបតែត្រូវបានណែនាំថ្មីៗនៅក្នុងប្រទេសកម្ពុជា សាលារៀនជំនាន់ថ្មីជាកន្លែងដែលបញ្ញត្តិនៃសហគមន៍សិក្សាវិជ្ជាជីវៈ និងការអនុវត្តនៃសហគមន៍សិក្សាវិជ្ជាជីវៈត្រូវបានពិភាក្សា និងដាក់ឱ្យអនុវត្ត។ អ្នកស្រាវជ្រាវបានកំណត់យកសាលារៀនជំនាន់ថ្មីនៅក្នុងខេត្តកំពង់ចាមជាករណីសិក្សា។ អ្នកស្រាវជ្រាវបានកំណត់យកសាលារៀនចំនួនពីរក្នុងខេត្តកំពង់ចាម ដែលបច្ចុប្បន្នកំពុងដំណើរការកម្មវិធីសាលារៀនជំនាន់ថ្មីមកធ្វើជាសាលារៀនគោលដៅ។ ទីមួយ គឺ វិទ្យាល័យ ហ៊ុន សែន កំពង់ចាម នៅទីរួមខេត្តកំពង់ចាម ដែលមានគណៈគ្រប់គ្រង ០២ នាក់ ក្នុងនោះស្រីមានចំនួន ០១ នាក់ និងគ្រូបង្រៀនចំនួន ៣៧ នាក់ ក្នុងនោះស្រីមានចំនួន ២០ នាក់។ ទីពីរ គឺ វិទ្យាល័យ ហ៊ុន សែន ពាមជីកង នៅក្នុងស្រុកកងមាស ដែលមានគណៈគ្រប់គ្រង ០៤ នាក់ ក្នុងនោះស្រីមានចំនួន ០០ នាក់ និងគ្រូបង្រៀនចំនួន ៦៤ នាក់ ក្នុងនោះស្រីមានចំនួន ២៩ នាក់។

### ៣.៤.២- ភាគសំណាកដែលបានចូលរួមបំពេញកម្រងសំណួរ

អ្នកស្រាវជ្រាវបានធ្វើការជ្រើសរើសសំណាកផ្អែកលើលក្ខណៈវិនិច្ឆ័យ (Judgement Sampling) គឺដោយសារតែសំណាកដែលត្រូវបានជ្រើសរើសមានលក្ខណៈវិនិច្ឆ័យគ្រប់គ្រាន់ដែលអាចឆ្លើយតបនឹងប្រធានបទ និងអាចផ្តល់ឱ្យនូវព័ត៌មានសមស្របបំផុតទាក់ទងនឹងប្រធានបទ។ ដោយសារតែវាជាករណីសិក្សា ការជ្រើសរើសសំណាកផ្អែកលើលក្ខណៈវិនិច្ឆ័យធ្វើឡើងដោយកំណត់អត្តសញ្ញាណអ្នកចូលរួមដែល

មានលក្ខណៈវិនិច្ឆ័យគ្រប់គ្រាន់សមស្របទៅនឹងប្រធានបទ (Mills & Gay, 2019) ។ ដូច្នេះហើយ ទើបបានជាគ្រូបង្រៀននៃសាលារៀនជំនាន់ថ្មីទាំងពីរខាងលើត្រូវបានជ្រើសរើសឱ្យចូលរួមបំពេញកម្រងសំណួរក្នុងការសិក្សាស្រាវជ្រាវនេះ។ ក្នុងនោះដែរ ដើម្បីផ្ទៀងផ្ទាត់ទស្សនៈគ្រូបង្រៀនលើការអនុវត្ត និងបញ្ហាប្រឈមចំពោះការអនុវត្តសហគមន៍សិក្សាវិជ្ជាជីវៈ អ្នកស្រាវជ្រាវបានស្នើសុំគណៈគ្រប់គ្រងនៃសាលាគោលដៅ ដើម្បីបំពេញកម្រងសំណួរសម្រាប់គណៈគ្រប់គ្រងផងដែរ។

ក្នុងការកំណត់ចំនួនភាគសំណាកនៃការស្រាវជ្រាវ អ្នកស្រាវជ្រាវពិបាកក្នុងការប្រើប្រាស់វិធីសាស្ត្រកំណត់បែបស្ថិតិ (Statistical Approach) ដោយយោងលើមូលហេតុថា ប្រធានបទនៃការសិក្សាស្រាវជ្រាវធ្វើឡើងពាក់ព័ន្ធនឹងទីកន្លែងដែលមានចំនួនសំណាកតិច។ ដូច្នេះ ចំនួនភាគសំណាកត្រូវពឹងផ្អែកលើការស្ទង់មតិខ្នាតតូចដោយប្រើប្រាស់ការជ្រើសរើសសំណាកមិនមែនចៃដន្យ (Pragmatic Approach) (Denscombe, 2017)។ ចំនួនភាគសំណាកដែលបានចូលរួមបំពេញកម្រងសំណួរមានចំនួន ៧២ នាក់ ដែលក្នុងនោះមាន ០៦ នាក់ ជាគណៈគ្រប់គ្រង រីឯ ៦៦ នាក់ផ្សេងទៀត គឺជាគ្រូបង្រៀន១១មុខវិជ្ជាឯក-ទេស។ Denscombe (2017) បានលើកឡើងថា នេះជាចំនួនសមស្របសម្រាប់ការវិភាគតាមបែបស្ថិតិ។

**តារាងទី ១៖ ទិន្នន័យចំនួនភាគសំណាកដែលបានបំពេញកម្រងសំណួរ**

| ល.រ. | សាលារៀនជំនាន់ថ្មី | ចំនួនសំណាក | | សរុប |
|---|---|---|---|---|
| | | គណៈគ្រប់គ្រង | គ្រូបង្រៀន | |
| ១ | វិ. ហ៊ុន សែន កំពង់ចាម | ០២ | ២០ | ២២ |
| ២ | វិ. ហ៊ុន សែន ពាមជីកង | ០៤ | ៤៦ | ៥០ |
| **សរុបរួម** | | **០៦** | **៦៦** | **៧២** |

## តារាងទី ២៖ ទិន្នន័យព័ត៌មានទូទៅអំពីគណៈគ្រប់គ្រង

| ល.រ. | បរិយាយ | | សាលារៀន | | សរុបរួម | |
|---|---|---|---|---|---|---|
| | | | វិ. ហស កំពង់ចាម | វិ. ហស ពាមជីកង | ចំនួន | ភាគរយ |
| ១ | ភេទ | ប្រុស | ០១ | ០៤ | ០៥ | ៨៣.៣០ |
| | | ស្រី | ០១ | ០០ | ០១ | ១៦.៧០ |
| | | **សរុប** | **០២** | **០៤** | **០៦** | **១០០** |
| ២ | អាយុ | លើសពី៤០ឆ្នាំ | ០២ | ០៤ | ០៦ | ១០០ |
| ៣ | កម្រិតវប្បធម៌ | បរិញ្ញាបត្រ | ០២ | ០៣ | ០៥ | ៨៣.៣០ |
| | | បរិញ្ញាបត្រជាន់ខ្ពស់ | ០០ | ០១ | ០១ | ១៦.៧០ |
| | | **សរុប** | **០២** | **០៤** | **០៦** | **១០០** |
| ៤ | បទពិសោធន៍ការងារ | លើសពី១៥ឆ្នាំ | ០២ | ០៤ | ០៦ | ១០០ |

## តារាងទី ៣៖ ទិន្នន័យព័ត៌មានទូទៅនៃចំនួន និងភាគរយសំណាកគ្រូបង្រៀន

| ល.រ. | បរិយាយ | | ចំនួន | ភាគរយ |
|---|---|---|---|---|
| ១ | ភេទ | ប្រុស | ៣០ | ៤៥.៥០ |
| | | ស្រី | ៣៦ | ៥៤.៥០ |
| | | **សរុប** | **៦៦** | **១០០** |
| ២ | បទពិសោធន៍ការងារ | ១-៥ឆ្នាំ | ២៥ | ៣៧.៩០ |
| | | ៦-១០ឆ្នាំ | ២០ | ៣០.៣០ |
| | | ១១-១៥ឆ្នាំ | ០៨ | ១២.១០ |
| | | លើសពី១៥ឆ្នាំ | ១៣ | ១៩.៧០ |
| | | **សរុប** | **៦៦** | **១០០** |

| | | | | |
|---|---|---|---|---|
| ៣ | មុខវិជ្ជាឯកទេស | ភាសាខ្មែរ | ០៩ | ១៣.៦០ |
| | | ភាសាអង់គ្លេស | ១០ | ១៥.២០ |
| | | គណិតវិទ្យា | ១០ | ១៥.២០ |
| | | រូបវិទ្យា | ០៨ | ១២.១០ |
| | | គីមីវិទ្យា | ០៨ | ១២.១០ |
| | | ជីវវិទ្យា | ០៧ | ១០.៦០ |
| | | ផែនដីវិទ្យា | ០២ | ៣.០០ |
| | | ប្រវត្តិវិទ្យា | ០៥ | ៧.៦០ |
| | | ភូមិវិទ្យា | ០២ | ៣.០០ |
| | | សីលធម៌-ពលរដ្ឋវិជ្ជា | ០១ | ១.៥០ |
| | | បច្ចេកវិទ្យាព័ត៌មានវិទ្យា | ០៤ | ៦.១០ |
| | | **សរុប** | **៦៦** | **១០០** |
| ៤ | កម្រិតថ្នាក់ | ៧ | ០៨ | ១២.១០ |
| | | ៨ | ១០ | ១៥.២០ |
| | | ៩ | ០៩ | ១៣.៦០ |
| | | ១០ | ១៧ | ២៥.៨០ |
| | | ១១ | ១៦ | ២៤.២០ |
| | | ១២ | ០៦ | ៩.១០ |
| | | **សរុប** | **៦៦** | **១០០** |
| ៥ | កម្រិតវប្បធម៌ | ចប់ថ្នាក់ទី១២ | ០២ | ៣.០០ |
| | | បរិញ្ញាបត្រ | ៥៥ | ៨៣.៣០ |
| | | បរិញ្ញាបត្រជាន់ខ្ពស់ | ០៩ | ១៣.៦០ |
| | | **សរុប** | **៦៦** | **១០០** |
| ៦ | អាយុ(ឆ្នាំ) | ២០-២៥ | ១៤ | ២១.២០ |
| | | ២៦-៣០ | ២០ | ៣០.៣០ |
| | | ៣១-៣៥ | ១៣ | ១៩.៧០ |
| | | ៣៦-៤០ | ១០ | ១៥.២០ |
| | | លើសពី៤០ | ៩ | ១៣.៦០ |
| | | **សរុប** | **៦៦** | **១០០** |

## ៣.៥- ការវិភាគទិន្នន័យ

ទិន្នន័យដែលបានពីកម្រងសំណួរត្រូវបានរៀបចំបញ្ចូលទៅក្នុងកម្មវិធី SPSS ដើម្បីប្រើប្រាស់ស្ថិតិបែបពណ៌នា (មធ្យម គម្លាតគំរូ) ក្នុងការធ្វើការវិភាគទៅលើកម្រិតនៃការអនុវត្តសហគមន៍សិក្សាវិជ្ជាជីវៈ និងវិភាគពីបញ្ហាប្រឈមក្នុងការអនុវត្តសហគមន៍សិក្សាវិជ្ជាជីវៈនៅសាលាទាំងពីរ។

## ៣.៦- ភាពជឿជាក់នៃកម្រងសំណួរ

អ្នកស្រាវជ្រាវបានធ្វើតេស្តសាកល្បងកម្រងសំណួរ និងបានធ្វើការវិភាគក្នុងកម្មវិធី SPSS 26 ដើម្បីតេស្តលើសង្គតិភាពនៃកម្រងសំណួរ។ ការធ្វើតេស្តដើម្បីរកឱ្យឃើញពីកម្រិតដែលសំណួរនីមួយៗពាក់ព័ន្ធទៅនឹងប្រធានបទជាការសំខាន់ ជាពិសេសសម្រាប់អ្នកស្រាវជ្រាវដែលទើបតែចាប់ផ្ដើមការស្រាវជ្រាវជាលើកដំបូង (Salkind, 1997)។ តាមរយៈការគណនា ឃើញថា Cronbach’s alpha ស្មើនឹង ០.៧១២ ដែលជាកម្រិតមួយល្អ។ អ្នកស្រាវជ្រាវបានដាក់លទ្ធផលនេះជូនគ្រូណែនាំ និងគ្រូណែនាំរង ដើម្បីពិនិត្យ និងឯកភាព។ បន្ទាប់ពីទទួលបានការពិនិត្យ និងឯកភាព អ្នកស្រាវជ្រាវប្រើប្រាស់កម្រងសំណួរនេះ ដើម្បីប្រមូលទិន្នន័យ។

## ៣.៧- សុពលភាពនៃកម្រងសំណួរ

សុពលភាពនៃកម្រងសំណួរសំដៅដល់កម្រិតឬទំហំមួយដែលការសិក្សាស្រាវជ្រាវចង់វាស់វែង ឬពន្យល់។ សំណួរទាំងឡាយក្នុងកម្រងសំណួរត្រូវតែតំណាងឱ្យខ្លឹមសារដែលបានកំណត់សម្រាប់ប្រធានបទនៃការសិក្សាស្រាវជ្រាវ (Ary et al., 2018)។ ក្នុងការសិក្សានេះ អ្នកស្រាវជ្រាវបានប្រើប្រាស់ “សៀវភៅណែនាំស្ដីពីការបង្កើតសហគមន៍សិក្សាវិជ្ជាជីវៈតាមគ្រឹះស្ថានសិក្សាសាធារណៈ” ដែលចេញដោយក្រសួងអប់រំ យុវជន និងកីឡា ជាឯកសារគោលក្នុងការកសាងកម្រងសំណួរ ដើម្បីប្រមូលទិន្នន័យ។ អ្នកស្រាវជ្រាវបានជ្រើសរើសសំណាកចេញពីគ្រូបង្រៀនកម្រិតមធ្យមសិក្សានៅសាលារៀនជំនាន់ថ្មីដែលមានការអនុវត្តសហគមន៍សិក្សាវិជ្ជាជីវៈ។ ការជ្រើសរើសសំណាកនេះនឹងជួយបង្កើនកម្រិតសុពលភាពនៃកម្រងសំណួរផងដែរ ដោយចម្លើយតបទៅកាន់កម្រងសំណួរពីសំណាក់អ្នកដែលបានអនុវត្តសហគមន៍

សិក្សាវិជ្ជាជីវៈមានភាពច្បាស់លាស់។ បន្ថែមពីលើនេះ អ្នកស្រាវជ្រាវបានរក្សាអនាមិកភាពជូនអ្នកចូលរួមបំពេញកម្រងសំណួរ ព្រោះអនាមិកភាពក្នុងការបំពេញកម្រងសំណួរក៏នឹងធ្វើឱ្យចម្លើយតបដែលទទួលបានពីអ្នកចូលរួមមានភាពសុក្រិតកាន់តែខ្លាំង។

## ៣.៨- ក្រមសីលធម៌នៃការស្រាវជ្រាវ

ក្នុងការប្រមូលទិន្នន័យ អ្នកស្រាវជ្រាវបានជូនលិខិតឧទ្ទេសនាមដល់សាលាគោលដៅ និងបានបង្ហាញពីគោលបំណងនៃការស្រាវជ្រាវជូនដល់គណៈគ្រប់គ្រងសាលាផងដែរ។ អ្នកស្រាវជ្រាវក៏បានចុះប្រមូលទិន្នន័យ ដោយរក្សានូវអនាមិកភាពនៃអ្នកចូលរួម។ ជាក់ស្តែង កម្រងសំណួរត្រូវបានចែកជូនអ្នកចូលរួម និងទុកពេលគ្រប់គ្រាន់ឱ្យពួកគាត់បំពេញ។ នៅក្នុងកម្រងសំណួរទៀតសោតមិនមានការបំពេញឈ្មោះឡើយ ដោយរក្សាការសម្ងាត់ជូនអ្នកបំពេញ និងក្នុងគោលបំណងធ្វើឱ្យទទួលបានចម្លើយពិតជាក់ស្តែង ដូចដែល Salkind (1997) បានលើកឡើងថា អ្នកស្រាវជ្រាវត្រូវរក្សាឱ្យបាននូវឯកជនភាពរបស់អ្នកចូលរួម ដោយធ្វើយ៉ាងណាមិនឱ្យគេអាចស្គាល់អត្តសញ្ញាណអ្នកចូលរួមឡើយ។

# ជំពូក៤

# លទ្ធផល និងការពិភាក្សា

នៅក្នុងជំពូកនេះ អ្នកស្រាវជ្រាវបង្ហាញពីលទ្ធផលដែលទទួលបានពីការវិភាគលើកម្រងសំណួរ ដើម្បីឆ្លើយតបទៅនឹងសំណួរស្រាវជ្រាវ។ ការបង្ហាញនេះនឹងផ្តោតលើចំណុចសំខាន់ៗនៃកម្រងសំណួរ ដែលពាក់ព័ន្ធទៅនឹងការអនុវត្តសហគមន៍សិក្សាវិជ្ជាជីវៈនៅកម្រិតមធ្យមសិក្សាក្នុងខេត្តកំពង់ចាម។ លើសពីនេះ ការបង្ហាញលទ្ធផល និងការពិភាក្សាក៏នឹងលើកយកបញ្ហាប្រឈមនៃការអនុវត្តមកជជែកផងដែរ។

## ៤.១- លទ្ធផល

### ៤.១.១- ការវិភាគទិន្នន័យដែលបានមកពីកម្រងសំណួរស្តីពីទស្សនៈគ្រូបង្រៀនលើការអនុវត្តសហគមន៍សិក្សាវិជ្ជាជីវៈនៅកម្រិតមធ្យមសិក្សាក្នុងខេត្តកំពង់ចាម

**ក- ការសិក្សាជាក្រុម**

**តារាងទី ៤៖ ទិន្នន័យស្តីពីទស្សនៈគ្រូបង្រៀនលើការសិក្សាជាក្រុម**

| ល.រ. | បរិយាយ | មធ្យម | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|---|
| ១ | សមាជិកនៃសហគមន៍សិក្សាវិជ្ជាជីវៈជួបជុំគ្នារៀងរាល់សប្តាហ៍។ | ៣.៨៩ | ០.៨៣ | ល្អ |
| ២ | សហគមន៍ទាំងមូលជួបជុំគ្នាធ្វើឡើងតាមរយៈការប្រជុំផ្ទាល់។ | ៤.០១ | ០.៧១ | ល្អ |
| ៣ | សហគមន៍ទាំងមូលជួបជុំគ្នាធ្វើឡើង តាមប្រព័ន្ធអេឡិចត្រូនិច ដូចជា ZOOM ឬ Google Meet ជាដើម។ | ៣.២៧ | ០.៩៨ | មធ្យម |
| ៤ | រាល់ការប្រជុំមានរបាយការណ៍ ឬកំណត់ហេតុដើម្បីរក្សាទុកជាឯកសារ ឬភស្តុតាងក្នុងអង្គភាព។ | ៤.៣៨ | ០.៦៧ | ល្អណាស់ |
| ៥ | សមាជិកម្នាក់ៗចងក្រងខ្លឹមសារ និងរក្សាទុកក្នុងកម្រងស្នាដៃវិជ្ជាជីវៈរបស់ខ្លួន។ | ៤.០០ | ០.៧០ | ល្អ |

| | | | |
|---|---|---|---|
| **សរុប** | **៣.៩១** | **០.៧៨** | **ល្អ** |

តារាងខាងលើបង្ហាញថា ទស្សនៈរបស់គ្រូបង្រៀនចំពោះការធ្វើការងារក្រុមរបស់សហគមន៍សិក្សាវិជ្ជាជីវៈស្ថិតនៅក្នុងកម្រិត "ល្អ" (មធ្យម=៣.៩១ គម្លាតស្តង់ដា=០.៧៨) ។ សូចនាករភាគច្រើនទទួលបានលទ្ធផល "ល្អ" ទោះបីជា ការប្រជុំដែលធ្វើឡើងតាមប្រព័ន្ធអេឡិចត្រូនិកស្ថិតនៅកម្រិត "មធ្យម" ក្តី (មធ្យម=៣.២៧ គម្លាតស្តង់ដា=០.៧៨)។ ដោយឡែកសូចនាករដែលទទួលបានកម្រិត "ល្អណាស់" គឺសូចនាករស្តីពីការប្រជុំដែលតែងតែមានរបាយការណ៍ ឬកំណត់ហេតុច្បាស់លាស់ (មធ្យម = ៤.៣៨ គម្លាតស្តង់ដា=០.៦៧)។ តាមរយៈលទ្ធផលខាងលើ ឃើញថាគ្រូបង្រៀនមានការសហការគ្នាធ្វើការបានល្អ (ជារួម មធ្យម=៣.៩១ គម្លាតស្តង់ដា=០.៧៨) ដោយបានធ្វើការប្រជុំទៀងទាត់ ហើយរៀងរាល់ការប្រជុំនីមួយៗមានកំណត់ហេតុឬរបាយការណ៍ច្បាស់លាស់ និងបានចងក្រងឯកសារទាំងនោះនៅក្នុងកម្រងស្នាដៃវិជ្ជាជីវៈផងដែរ។

**តារាងទី ៥៖ ទិន្នន័យស្តីពីទស្សនៈគណៈគ្រប់គ្រងលើការសិក្សាជាក្រុម**

| ល.រ. | បរិយាយ | មធ្យម | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|---|
| ១ | សមាជិកនៃសហគមន៍សិក្សាវិជ្ជាជីវៈជួបជុំគ្នារៀងរាល់សប្តាហ៍។ | ៤.៦៧ | ០.៥២ | ល្អណាស់ |
| ២ | សហគមន៍ទាំងមូលជួបជុំគ្នាធ្វើឡើងតាមរយៈការប្រជុំផ្ទាល់។ | ៤.៦៧ | ០.៥២ | ល្អណាស់ |
| ៣ | សហគមន៍ទាំងមូលជួបជុំគ្នាធ្វើឡើងតាមប្រព័ន្ធអេឡិចត្រូនិច ដូចជា ZOOM ឬ Google Meet ជាដើម។ | ៣.៥០ | ០.៥៥ | ល្អ |
| ៤ | រាល់ការប្រជុំមានរបាយការណ៍ ឬកំណត់ហេតុដើម្បីរក្សាទុកជាឯកសារ ឬភស្តុតាងក្នុងអង្គភាព។ | ៤.៦៧ | ០.៥២ | ល្អណាស់ |
| ៥ | សមាជិកម្នាក់ៗចងក្រងខ្លឹមសារ និងរក្សាទុកក្នុងកម្រងស្នាដៃវិជ្ជាជីវៈរបស់ខ្លួន។ | ៤.៦៧ | ០.៥២ | ល្អណាស់ |
| | **សរុប** | **៤.៤៤** | **០.៥៣** | **ល្អណាស់** |

តារាងខាងលើបង្ហាញពីទស្សនៈគណៈគ្រប់គ្រងចំពោះការធ្វើការសិក្សាជាក្រុមរបស់សហគមន៍សិក្សាវិជ្ជាជីវៈ។ ទស្សនៈគណៈគ្រប់គ្រងចំពោះការធ្វើការងារក្រុមរបស់សហគមន៍សិក្សាវិជ្ជាជីវៈទទួលបានកម្រិត "ល្អណាស់" (មធ្យម = ៤.៤៤ គម្លាតស្តង់ដា = ០.៥៣)។ សូចនាករភាគច្រើនទទួលបានលទ្ធផល "ល្អណាស់"។ លទ្ធផលខាងលើបង្ហាញថា ការយល់ឃើញរបស់គណៈគ្រប់គ្រងចំពោះការធ្វើការងារក្រុមរបស់សហគមន៍សិក្សាវិជ្ជាជីវៈទទួលបានលទ្ធផលខ្ពស់ជាងការយល់ឃើញរបស់គ្រូបង្រៀន ដែលទស្សនៈរបស់គណៈគ្រប់គ្រងមាន មធ្យម = ៤.៤៤ និងគម្លាតស្តង់ដា = ០.៥៣ រីឯ ទស្សនៈរបស់គ្រូបង្រៀនមាន មធ្យម = ៣.៩១ និងគម្លាតស្តង់ដា = ០.៧៨។ ជារួម ទាំងគណៈគ្រប់គ្រងនិងគ្រូបង្រៀនមានទស្សនៈវិជ្ជមានចំពោះការបំពេញការងារក្រុមរបស់សហគមន៍សិក្សាវិជ្ជាជីវៈ។

**ខ- ការសង្កេតថ្នាក់ និងប្រឹក្សា**

**តារាងទី ៦៖ ទិន្នន័យស្តីពីទស្សនៈគ្រូបង្រៀនលើការសង្កេតថ្នាក់ និងប្រឹក្សា**

| ល.រ. | បរិយាយ | មធ្យម | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|---|
| ១ | ប្រធានក្រុមសហគមន៍សិក្សាវិជ្ជាជីវៈសហការជាមួយនាយករងទទួលបន្ទុកបច្ចេកទេស ដើម្បីផ្តល់ដំបូន្មានលើការបង្រៀននិងរៀន។ | ៤.១២ | ០.៦២ | ល្អ |
| ២ | ប្រធានក្រុមសហគមន៍សិក្សាវិជ្ជាជីវៈសហការជាមួយនាយករងទទួលបន្ទុកបច្ចេកទេស គាំទ្រដល់គ្រូបង្រៀនធ្វើការអភិវឌ្ឍវិជ្ជាជីវៈ និងធានាប្រសិទ្ធភាពនៃការបង្រៀននិងរៀន។ | ៤.១១ | ០.៥៦ | ល្អ |
| ៣ | សមាជិកសហគមន៍មានឧបករណ៍សង្កេតច្បាស់លាស់ក្នុងការចុះសង្កេតថ្នាក់ ដោយផ្អែកលើកាលវិភាគបង្រៀនជាក់ស្តែង។ | ៤.០២ | ០.៧១ | ល្អ |
| ៤ | សមាជិកសហគមន៍មានផែនការច្បាស់លាស់ក្នុងការចុះសង្កេតថ្នាក់ ដោយផ្អែកលើកាលវិភាគបង្រៀនជាក់ស្តែង។ | ៤.០២ | ០.៦៧ | ល្អ |
| ៥ | ព័ត៌មានដែលទទួលបានពីការសង្កេតថ្នាក់ត្រូវបានប្រើ | ៤.១២ | ០.៦៥ | ល្អ |

| | | | | |
|---|---|---|---|---|
| | សម្រាប់ការឆ្លុះបញ្ចាំងការសង្កេតលើកក្រោយៗទៀត។ | | | |
| ៦ | ព័ត៌មានដែលទទួលបានពីការសង្កេតថ្នាក់ត្រូវបានដាក់ចូលក្នុងរបៀបវារៈប្រជុំក្នុងខែនីមួយៗ។ | ៣.៥៥ | ០.៩០ | ល្អ |
| ៧ | សមាជិកសហគមន៍ម្នាក់ៗចូលសង្កេតការបង្រៀនរបស់គ្រូដែលមានបច្ចេកទេសខ្ពស់ក្នុងសាលា ដើម្បីរៀនសូត្រ និងច្នៃប្រឌិតវិធីសាស្ត្រឱ្យសមស្របតាមមេរៀននីមួយៗ និងលទ្ធភាពជាក់ស្តែងនៃថ្នាក់នីមួយៗ។ | ៣.៧១ | ០.៨០ | ល្អ |
| ៨ | ព្រឹត្តិបត្តិសង្កេតថ្នាក់ទទួលបានការឯកភាពពីគ្រូបង្រៀនដែលត្រូវបានអង្កេត ត្រូវបានរក្សាទុក ដើម្បីជាភស្តុតាងក្នុងកម្រងស្នាដៃវិជ្ជាជីវៈ (Teacher Portfolio)។ | ៣.៩៥ | ០.៦២ | ល្អ |
| **សរុប** | | **៣.៩៥** | **០.៦៩** | ល្អ |

តារាងខាងលើបង្ហាញថា ទស្សនៈគ្រូបង្រៀនលើការសង្កេតថ្នាក់ និងប្រឹក្សារបស់សហគមន៍សិក្សាវិជ្ជាជីវៈស្ថិតនៅកម្រិត “ល្អ” (មធ្យម = ៣.៩៥ គម្លាតស្តង់ដា = ០.៦៩)។ គ្រប់សូចនាករទាំងអស់ទទួលបានលទ្ធផល “ល្អ” ដូចគ្នា។ លទ្ធផលនេះបង្ហាញថា ប្រធានក្រុមសហគមន៍និងនាយករងទទួលបន្ទុកបច្ចេកទេសបានធ្វើការសហការគ្នាល្អក្នុងការគាំទ្រដល់ការប្រឹក្សាយោបល់ និងការចុះអង្កេតថ្នាក់។ ចំពោះការចុះអង្កេតថ្នាក់ ឃើញថាមានឧបករណ៍អង្កេតច្បាស់លាស់ ហើយរាល់ព័ត៌មានដែលទទួលបានត្រូវបានយកទៅដាក់ជារបៀបវារៈនៃការប្រជុំប្រចាំខែ និងត្រូវបានរក្សាទុកក្នុងកម្រងស្នាដៃវិជ្ជាជីវៈ។

**តារាងទី ៧៖ ទិន្នន័យស្តីពីទស្សនៈគណៈគ្រប់គ្រងលើការសង្កេតថ្នាក់ និងប្រឹក្សា**

| ល.រ. | បរិយាយ | មធ្យម | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|---|
| ១ | ប្រធានក្រុមសហគមន៍សិក្សាវិជ្ជាជីវៈសហការជាមួយនាយករងទទួលបន្ទុកបច្ចេកទេស ដើម្បីផ្តល់ដំបូន្មានលើការបង្រៀននិងរៀន។ | ៤.៣៣ | ០.៨២ | ល្អណាស់ |
| ២ | ប្រធានក្រុមសហគមន៍សិក្សាវិជ្ជាជីវៈសហការជាមួយនាយករងទទួលបន្ទុកបច្ចេកទេស គាំទ្រដល់គ្រូបង្រៀនធ្វើការអភិវឌ្ឍវិជ្ជាជីវៈ និងធានាប្រសិទ្ធភាពនៃការបង្រៀននិងរៀន។ | ៤.០០ | ០.៦៣ | ល្អ |

| | | | | |
|---|---|---|---|---|
| ៣ | សមាជិកសហគមន៍មានឧបករណ៍សង្កេតច្បាស់លាស់ក្នុងការចុះសង្កេតថ្នាក់ ដោយផ្អែកលើកាលវិភាគបង្រៀនជាក់ស្តែង។ | ៤.១២ | ០.៧៥ | ល្អ |
| ៤ | សមាជិកសហគមន៍មានផែនការច្បាស់លាស់ក្នុងការចុះសង្កេតថ្នាក់ ដោយផ្អែកលើកាលវិភាគបង្រៀនជាក់ស្តែង។ | ៤.៣៣ | ០.៨២ | ល្អណាស់ |
| ៥ | ព័ត៌មានដែលទទួលបានពីការសង្កេតថ្នាក់ត្រូវបានប្រើសម្រាប់ការឆ្លុះបញ្ចាំងការសង្កេតលើកក្រោយៗទៀត។ | ៤.៣៣ | ០.៨២ | ល្អណាស់ |
| ៦ | ព័ត៌មានដែលទទួលបានពីការសង្កេតថ្នាក់ត្រូវបានដាក់ចូលក្នុងរបៀបវារៈប្រជុំក្នុងខែនីមួយៗ។ | ៤.៣៣ | ០.៨២ | ល្អណាស់ |
| ៧ | សមាជិកសហគមន៍ម្នាក់ៗចូលសង្កេតការបង្រៀនរបស់គ្រូដែលមានបច្ចេកទេសខ្ពស់ក្នុងសាលា ដើម្បីរៀនសូត្រ និងច្នៃប្រឌិតវិធីសាស្ត្រឱ្យសមស្របតាមមេរៀននីមួយៗ និងលទ្ធភាពជាក់ស្តែងនៃថ្នាក់នីមួយៗ។ | ៣.៥០ | ១.០៥ | ល្អ |
| ៨ | ព្រឹត្តិបត្តិសង្កេតថ្នាក់ទទួលបានការឯកភាពពីគ្រូបង្រៀនដែលត្រូវបានអង្កេតត្រូវបានរក្សាទុក ដើម្បីជាភស្តុតាងក្នុងកម្រងស្នាដៃវិជ្ជាជីវៈ។ | ៤.៣៣ | ០.៥២ | ល្អណាស់ |
| **សរុប** | | **៤.១៦** | **០.៧៨** | ល្អ |

តារាងខាងលើបង្ហាញពីទស្សនៈគណៈគ្រប់គ្រងលើការសង្កេតថ្នាក់ និងប្រឹក្សារបស់សហគមន៍សិក្សាវិជ្ជាជីវៈ។ ជារួម ទស្សនៈគណៈគ្រប់គ្រងស្ថិតនៅកម្រិត "ល្អ" (មធ្យម = ៤.១៦ គម្លាតស្តង់ដា = ០.៧៨)។ តាមរយៈលទ្ធផលខាងលើ គណៈគ្រប់គ្រង និងគ្រូបង្រៀនមានទស្សនៈស្របគ្នាថា ការសង្កេតថ្នាក់ និងប្រឹក្សារបស់សហគមន៍សិក្សាវិជ្ជាជីវៈស្ថិតនៅកម្រិត "ល្អ"។

### គ- ភារកិច្ចរបស់សហគមន៍សិក្សាវិជ្ជាជីវៈ

**តារាងទី ៨៖ ទិន្នន័យស្តីពីទស្សនៈគ្រូបង្រៀនលើការបំពេញភារកិច្ចរបស់សហគមន៍សិក្សាវិជ្ជាជីវៈ**

| ល.រ. | បរិយាយ | មធ្យម | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|---|

| | | | | |
|---|---|---|---|---|
| ១ | សមាជិកសហគមន៍ធ្វើការសិក្សាស្រាវជ្រាវទាក់ទងការបង្រៀន និងរៀន។ | ៤.១៧ | ០.៤៥ | ល្អ |
| ២ | សមាជិកសហគមន៍បានអនុវត្តការសិក្សាស្រាវជ្រាវមេរៀន ដើម្បីចាប់យកនូវទេពកោសល្យទៅអនុវត្តក្នុងការងារបង្រៀន និងរៀនឱ្យមានការឯកភាពគ្នា។ | ៤.០៦ | ០.៥២ | ល្អ |
| ៣ | សមាជិកសហគមន៍បានធ្វើថ្នាក់និទស្សន៍ ដើម្បីចាប់យកនូវទេពកោសល្យទៅអនុវត្តក្នុងការងារបង្រៀន និងរៀនឱ្យមានការឯកភាពគ្នា។ | ៣.៧៧ | ០.៧២ | ល្អ |
| ៤ | សមាជិកសហគមន៍ត្រូវបានចាត់តាំងឱ្យចូលស្ដាប់ការបង្រៀន ដើម្បីច្នៃប្រឌិតវិធីសាស្ត្រឱ្យសមស្របតាមមេរៀននីមួយៗ និងតាមលទ្ធភាពជាក់ស្ដែងនៃថ្នាក់នីមួយៗ។ | ៣.៨០ | ០.៨៣ | ល្អ |
| ៥ | សមាជិកសហគមន៍ផ្លាស់ប្ដូរយោបល់ និងដកបទពិសោធន៍ ដើម្បីច្នៃប្រឌិតវិធីសាស្ត្រឱ្យសមស្របតាមមេរៀននីមួយៗ និងតាមលទ្ធភាពជាក់ស្ដែងនៃថ្នាក់នីមួយៗ។ | ៤.០៥ | ០.៦៤ | ល្អ |
| ៦ | សហគមន៍ទាំងមូលចងក្រងឯកសារវិធីសាស្ត្របង្រៀន និងយុទ្ធសាស្ត្រថ្មីៗសម្រាប់ការបង្រៀន និងរៀនឱ្យមានប្រសិទ្ធភាព។ | ៤.០២ | ០.៦៤ | ល្អ |
| ៧ | សហគមន៍ទាំងមូលចែករំលែកបទពិសោធការងារស្រាវជ្រាវការបង្រៀន និងរៀនដល់សមាជិកសហគមន៍។ | ៤.១៨ | ០.៥៥ | ល្អ |
| ៨ | សហគមន៍ទាំងមូលចែករំលែកបទពិសោធប្រសិទ្ធភាពនៃការបង្រៀន និងរៀនដល់សមាជិកសហគមន៍។ | ៤.០៩ | ០.៤៥ | ល្អ |
| ៩ | សមាជិកសហគមន៍ធ្វើបទបង្ហាញចំណេះដឹងដែលខ្លួនទទួលបានតាមរយៈការចូលរួមវគ្គបំប៉ន ឬសិក្ខាសាលា។ | ៤.០០ | ០.៦៨ | ល្អ |
| ១០ | សហគមន៍បានដឹកនាំថតជាវីដេអូនៃការបង្រៀនដែលប្រើវិធីបង្រៀនថ្មីៗ និងបានធ្វើការចែករំលែក | ៣.៦៧ | ០.៨១ | ល្អ |

| | | | | |
|---|---|---|---|---|
| | ទៅសាលាដទៃ។ | | | |
| ១១ | សហគមន៍បានដឹកនាំថតជាវីដេអូនៃការបង្រៀន ដែលប្រើវិធីបង្រៀនថ្មីៗ និងបានចែករំលែកតាមបណ្តាញសង្គម។ | ៣.៦២ | ០.៨០ | ល្អ |
| ១២ | សហគមន៍ជួយសមាជិករបស់ខ្លួនរៀបចំការអភិវឌ្ឍវិជ្ជាជីវៈប្រចាំឆ្នាំ ដើម្បីសម្រេចបាននូវស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន។ | ៣.៩១ | ០.៦៥ | ល្អ |
| ១៣ | សហគមន៍តាមដានការអនុវត្តការអភិវឌ្ឍវិជ្ជាជីវៈប្រចាំឆ្នាំ របស់សមាជិកដើម្បីសម្រេចបាននូវស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន។ | ៣.៨៨ | ០.៦២ | ល្អ |
| ១៤ | សហគមន៍មានកម្មវិធីបំប៉ន និងលើកកម្ពស់កម្រិតវប្បធម៌ បច្ចេកទេសដល់សមាជិករបស់ខ្លួន។ | ៣.៩១ | ០.៧៦ | ល្អ |
| ១៥ | សហគមន៍ជួយសមាជិករបស់ខ្លួនក្នុងការអនុវត្តផែនការបង្រៀនទៅតាមកាលកំណត់ ឱ្យបានឯកភាពគ្នាទាំងវិធីសាស្ត្រទាំងខ្លឹមសារ។ | ៤.០២ | ០.៦២ | ល្អ |
| ១៦ | សហគមន៍ធ្វើការវិភាគលើលទ្ធផលសិក្សារបស់សិស្ស។ | ៤.០៩ | ០.៧០ | ល្អ |
| ១៧ | សហគមន៍រិះរកវិធីកែលម្អគុណភាពបង្រៀន និងរៀន។ | ៤.២៣ | ០.៥៥ | ល្អណាស់ |
| ១៨ | សហគមន៍កំណត់មុខសញ្ញាសិស្សរៀនយឺត និងជួយបង្រៀនបំប៉នឱ្យបានទាន់ពេលវេលា។ | ៤.០០ | ០.៧៦ | ល្អ |
| | **សរុប** | **៣.៩៧** | **០.៦៥** | **ល្អ** |

តារាងខាងលើបង្ហាញថា ទស្សនៈគ្រូបង្រៀនលើភារកិច្ចរបស់សហគមន៍សិក្សាវិជ្ជាជីវៈស្ថិតនៅកម្រិត “ល្អ” (មធ្យម = ៣.៩៧ គម្លាតស្តង់ដា = ០.៦៥)។ សូចនាករភាគច្រើនបំផុតទទួលបានលទ្ធផល “ល្អ”។ លទ្ធផលនេះបង្ហាញថា ការយល់ដឹងរបស់សហគមន៍សិក្សាវិជ្ជាជីវៈពីភារកិច្ចរបស់ខ្លួនមានភាពល្អ ដែលជារួមពួកគេយល់ដឹងអំពីសារៈសំខាន់នៃការសិក្សាស្រាវជ្រាវ ការអភិវឌ្ឍសមត្ថភាព ការចែករំលែកបទពិសោធន៍ និងការលើកកម្ពស់លទ្ធផលសិក្សារបស់សិស្ស។

**តារាងទី ៩៖ ទិន្នន័យស្តីពីទស្សនៈគណៈគ្រប់គ្រងលើការបំពេញភារកិច្ចរបស់សហគមន៍សិក្សាវិជ្ជាជីវៈ**

| ល.រ. | បរិយាយ | មធ្យម | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|---|
| ១ | សមាជិកសហគមន៍ធ្វើការសិក្សាស្រាវជ្រាវទាក់ទងការបង្រៀន និងរៀន។ | ៤.៨៣ | ០.៤០ | ល្អណាស់ |
| ២ | សមាជិកសហគមន៍បានអនុវត្តការសិក្សាស្រាវជ្រាវមេរៀន ដើម្បីចាប់យកនូវទេពកោសល្យទៅអនុវត្តក្នុងការងារបង្រៀន និងរៀនឱ្យមានការឯកភាពគ្នា។ | ៤.៦៧ | ០.៥២ | ល្អណាស់ |
| ៣ | សមាជិកសហគមន៍បានធ្វើថ្នាក់និទស្សន៍ ដើម្បីចាប់យកនូវទេពកោសល្យទៅអនុវត្តក្នុងការងារបង្រៀន និងរៀនឱ្យមានការឯកភាពគ្នា។ | ៣.៣៣ | ០.៨៧ | មធ្យម |
| ៤ | សមាជិកសហគមន៍ត្រូវបានចាត់តាំងឱ្យចូលស្តាប់ការបង្រៀន ដើម្បីច្នៃប្រឌិតវិធីសាស្ត្រឱ្យសមស្របតាមមេរៀននីមួយៗ និងតាមលទ្ធភាពជាក់ស្តែងនៃថ្នាក់នីមួយៗ។ | ៣.៣៣ | ០.៨៧ | មធ្យម |
| ៥ | សមាជិកសហគមន៍ផ្លាស់ប្តូរយោបល់ និងដកបទពិសោធន៍ ដើម្បីច្នៃប្រឌិតវិធីសាស្ត្រឱ្យសមស្របតាមមេរៀននីមួយៗ និងតាមលទ្ធភាពជាក់ស្តែងនៃថ្នាក់នីមួយៗ។ | ៤.១៧ | ០.៤១ | ល្អ |
| ៦ | សហគមន៍ទាំងមូលចងក្រងឯកសារវិធីសាស្ត្របង្រៀន និងយុទ្ធសាស្ត្រថ្មីៗសម្រាប់ការបង្រៀន និងរៀនឱ្យមានប្រសិទ្ធភាព។ | ៤.០០ | ០.៨៩ | ល្អ |
| ៧ | សហគមន៍ទាំងមូលចែករំលែកបទពិសោធការងារស្រាវជ្រាវការបង្រៀន និងរៀនដល់សមាជិកសហគមន៍។ | ៤.១៧ | ០.៤១ | ល្អ |
| ៨ | សហគមន៍ទាំងមូលចែករំលែកបទពិសោធប្រសិទ្ធភាពនៃការបង្រៀន និងរៀនដល់សមាជិកសហគមន៍។ | ៤.១៧ | ០.៤១ | ល្អ |
| ៩ | សមាជិកសហគមន៍ធ្វើបទបង្ហាញចំណេះដឹងដែលខ្លួនទទួលបានតាមរយៈការចូលរួមវគ្គបំប៉ន ឬសិក្ខា | ៤.០០ | ០.៦៣ | ល្អ |

| | | | | |
|---|---|---|---|---|
| | សាលា។ | | | |
| ១០ | សហគមន៍បានដឹកនាំថតជាវីដេអូនៃការបង្រៀនដែលប្រើវិធីបង្រៀនថ្មីៗ និងបានធ្វើការចែករំលែកទៅសាលាដទៃ។ | ៣.៥០ | ០.៨៤ | ល្អ |
| ១១ | សហគមន៍បានដឹកនាំថតជាវីដេអូនៃការបង្រៀនដែលប្រើវិធីបង្រៀនថ្មីៗ និងបានចែករំលែកតាមបណ្ដាញសង្គម។ | ៣.៨៣ | ០.៤១ | ល្អ |
| ១២ | សហគមន៍ជួយសមាជិករបស់ខ្លួនរៀបចំការអភិវឌ្ឍវិជ្ជាជីវៈប្រចាំឆ្នាំ ដើម្បីសម្រេចបាននូវស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន។ | ៣.៦៧ | ០.៥២ | ល្អ |
| ១៣ | សហគមន៍តាមដានការអនុវត្តការអភិវឌ្ឍវិជ្ជាជីវៈប្រចាំឆ្នាំ របស់សមាជិកដើម្បីសម្រេចបាននូវស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន។ | ៤.០០ | ០.៨៩ | ល្អ |
| ១៤ | សហគមន៍មានកម្មវិធីបំប៉ន និងលើកកម្ពស់កម្រិតវប្បធម៌ បច្ចេកទេសដល់សមាជិករបស់ខ្លួន។ | ៣.០០ | ០.៦៣ | មធ្យម |
| ១៥ | សហគមន៍ជួយសមាជិករបស់ខ្លួនក្នុងការអនុវត្តផែនការបង្រៀនទៅតាមកាលកំណត់ ឱ្យបានឯកភាពគ្នាទាំងវិធីសាស្រ្តទាំងខ្លឹមសារ។ | ៤.០០ | ០.៨៩ | ល្អ |
| ១៦ | សហគមន៍ធ្វើការវិភាគលើលទ្ធផលសិក្សារបស់សិស្ស។ | ៤.៥០ | ០.៥៥ | ល្អណាស់ |
| ១៧ | សហគមន៍រិះរកវិធីកែលម្អគុណភាពបង្រៀន និងរៀន។ | ៤.៥០ | ០.៥៥ | ល្អណាស់ |
| ១៨ | សហគមន៍កំណត់មុខសញ្ញាសិស្សរៀនយឺត និងជួយបង្រៀនបំប៉នឱ្យបានទាន់ពេលវេលា។ | ៤.៥០ | ០.៥៥ | ល្អណាស់ |
| | **សរុប** | **៤.០១** | **០.៦២** | **ល្អ** |

តារាងខាងលើបង្ហាញពីទស្សនៈគណៈគ្រប់គ្រងលើភារកិច្ចរបស់សហគមន៍សិក្សាវិជ្ជាជីវៈ។ ជារួមទស្សនៈគណៈគ្រប់គ្រងស្ថិតនៅកម្រិត “ល្អ” (មធ្យម = ៤.០១ គម្លាតស្តង់ដា = ០.៦២) ដែលស្របគ្នាទៅនឹងទស្សនៈគ្រូបង្រៀនដែរ។ តាមរយៈលទ្ធផលខាងលើ ឃើញថា គណៈគ្រប់គ្រង និងគ្រូបង្រៀនសុទ្ធតែយល់ឃើញវិជ្ជមានដូចគ្នាអំពីការយល់ដឹងរបស់សហគមន៍សិក្សាវិជ្ជាជីវៈពីភារកិច្ចរបស់ខ្លួនក្នុងការ

សិក្សាស្រាវជ្រាវ ការអភិវឌ្ឍសមត្ថភាព ការចែករំលែកបទពិសោធន៍ និងការលើកកម្ពស់លទ្ធផលសិក្សារបស់សិស្ស។

**ឃ- អ្នកពាក់ព័ន្ធសំខាន់ៗដែលគាំទ្រសហគមន៍សិក្សាវិជ្ជាជីវៈ**

**តារាងទី ១០៖ ទិន្នន័យស្តីពីទស្សនៈគ្រូបង្រៀនលើអ្នកពាក់ព័ន្ធសំខាន់ៗដែលការគាំទ្រដល់សហគមន៍សិក្សាវិជ្ជាជីវៈ**

| ល.រ. | បរិយាយ | មធ្យម | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|---|
| ១ | មន្ទីរអប់រំ យុវជន និងកីឡាខេត្ត ជានាចក្ខុវិស័យរួមរបស់ក្រសួង ដើម្បីឱ្យការអនុវត្តតាមសាលារៀនមានគំនិតរួមដូចគ្នា។ | ៣.៨៨ | ០.៨១ | ល្អ |
| ២ | មន្ទីរអប់រំ យុវជន និងកីឡាខេត្ត ផ្តល់ការតម្រង់ទិសដល់សហគមន៍សិក្សាវិជ្ជាជីវៈគ្រប់លំដាប់ថ្នាក់ ឱ្យយល់ដឹងពីការអនុវត្ត និងតួនាទីរបស់សហគមន៍សិក្សាវិជ្ជាជីវៈ។ | ៣.៨០ | ០.៨០ | ល្អ |
| ៣ | មន្ទីរអប់រំ យុវជន និងកីឡាខេត្ត ផ្តល់ជំនួយផ្នែកធនធានមនុស្សដល់សហគមន៍សិក្សាវិជ្ជាជីវៈ។ | ៣.៧៦ | ០.៩០ | ល្អ |
| ៤ | មន្ទីរអប់រំ យុវជន និងកីឡាខេត្ត ផ្តល់ជំនួយផ្នែកសម្ភារៈដល់សហគមន៍សិក្សាវិជ្ជាជីវៈ។ | ៣.៧៤ | ០.៩៣ | ល្អ |
| ៥ | មន្ទីរអប់រំ យុវជន និងកីឡាខេត្ត បានបែងចែកក្រុមទទួលបន្ទុកច្បាស់លាស់ ដើម្បីចូលរួមពិនិត្យការអនុវត្តសហគមន៍សិក្សាវិជ្ជាជីវៈ។ | ៣.៦៤ | ០.៨៩ | ល្អ |
| ៦ | ការិយាល័យអប់រំ យុវជន និងកីឡា ស្រុក/ក្រុង ជានាចក្ខុវិស័យរួមរបស់ក្រសួង ដើម្បីឱ្យការអនុវត្តតាមសាលារៀនមានគំនិតរួមដូចគ្នា។ | ៣.៧៧ | ០.៨២ | ល្អ |
| ៧ | ការិយាល័យអប់រំ យុវជន និងកីឡា ស្រុក/ក្រុង ផ្តល់ការតម្រង់ទិសដល់សហគមន៍សិក្សាវិជ្ជាជីវៈគ្រប់លំដាប់ថ្នាក់ ឱ្យយល់ដឹងពីការអនុវត្ត និងតួនាទីរបស់សហគមន៍សិក្សាវិជ្ជាជីវៈ។ | ៣.៧០ | ០.៨៦ | ល្អ |

| | | | | |
|---|---|---|---|---|
| ៨ | ការិយាល័យអប់រំ យុវជន និងកីឡា ស្រុក/ក្រុង ផ្តល់ជំនួយផ្នែកធនធានមនុស្សដល់សហគមន៍សិក្សាវិជ្ជាជីវៈ។ | ៣.៦៨ | ០.៩១ | ល្អ |
| ៩ | ការិយាល័យអប់រំ យុវជន និងកីឡាស្រុក/ក្រុង ផ្តល់ជំនួយផ្នែកសម្ភារៈដល់សហគមន៍សិក្សាវិជ្ជាជីវៈ។ | ៣.៦៥ | ០.៨៩ | ល្អ |
| ១០ | ការិយាល័យអប់រំ យុវជន និងកីឡា ស្រុក/ក្រុង បានបែងចែកក្រុមទទួលបន្ទុកច្បាស់លាស់ ដើម្បីចូលរួមពិនិត្យការអនុវត្តសហគមន៍សិក្សាវិជ្ជាជីវៈ។ | ៣.៦១ | ០.៨៧ | ល្អ |
| ១១ | គណៈគ្រប់គ្រងសាលាពន្យល់គ្រូបង្រៀនអំពីសារៈសំខាន់នៃសហគមន៍សិក្សាវិជ្ជាជីវៈ។ | ៤.១២ | ០.៦២ | ល្អ |
| ១២ | គណៈគ្រប់គ្រងសាលាចូលរួមក្នុងដំណើរការបង្កើតសហគមន៍សិក្សាវិជ្ជាជីវៈសម្រាប់គ្រូបង្រៀន។ | ៤.១៧ | ០.៦០ | ល្អ |
| ១៣ | គណៈគ្រប់គ្រងសាលាបានបែងចែកធនធានសមស្របសម្រាប់សហគមន៍សិក្សាវិជ្ជាជីវៈ។ | ៤.១៧ | ០.៥៧ | ល្អ |
| ១៤ | គណៈគ្រប់គ្រងសាលាបានបែងចែកពេលវេលាសមស្របសម្រាប់សហគមន៍សិក្សាវិជ្ជាជីវៈ។ | ៤.២០ | ០.៥៩ | ល្អ |
| ១៥ | គណៈគ្រប់គ្រងសាលាដឹកនាំបង្កើតផែនការសិក្សាវិជ្ជាជីវៈ | ៤.០៦ | ០.៦៥ | ល្អ |
| ១៦ | គណៈគ្រប់គ្រងសាលាដឹកនាំបង្កើតកម្រងស្នាដៃវិជ្ជាជីវៈសម្រាប់អង្គភាព។ | ៤.០៣ | ០.៦៦ | ល្អ |
| ១៧ | គណៈគ្រប់គ្រងសាលាដឹកនាំបង្កើតកម្រងស្នាដៃវិជ្ជាជីវៈសម្រាប់គ្រូម្នាក់ៗ។ | ៣.៩៥ | ០.៧៣ | ល្អ |
| ១៨ | គណៈគ្រប់គ្រងសាលារៀបចំទីកន្លែងសម្រាប់គ្រូស្វ័យសិក្សាក្នុងសាលារៀន។ | ៣.៩៤ | ០.៨៤ | ល្អ |
| | **សរុប** | **៣.៨៨** | **០.៧៧** | **ល្អ** |

តារាងខាងលើបង្ហាញថា ទស្សនៈគ្រូបង្រៀនលើអ្នកពាក់ព័ន្ធសំខាន់ៗដែលការគាំទ្រដល់សហគមន៍សិក្សាវិជ្ជាជីវៈស្ថិតនៅកម្រិត “ល្អ” (មធ្យម = ៣.៨៨ គម្លាតស្តង់ដា = ០.៧៧)។ សូចនាករទាំងអស់ទទួលបានលទ្ធផល “ល្អ”។ លទ្ធផលនេះបង្ហាញថា សហគមន៍សិក្សាវិជ្ជាជីវៈបានទទួលការគាំទ្រពីសំណាក់ភាគីពាក់ព័ន្ធនានា ដែលមានជាអាទិ៍មន្ទីរ និងការិយល័យអប់រំ យុវជន និងកីឡា និងគណៈគ្រប់គ្រងសាលា លើការជួយគាំទ្រផ្នែកសម្ភារៈ និងបច្ចេកទេស ។ លទ្ធផលបានបង្ហាញថា គណៈគ្រប់គ្រង

សាលាដែលធ្វើការផ្ទាល់ជាមួយសហគមន៍សិក្សាវិជ្ជាជីវៈ បានពន្យល់ណែនាំពីសារៈសំខាន់នៃសហគមន៍សិក្សាវិជ្ជាជីវៈ (មធ្យម = ៤.១២ គម្លាតស្តង់ដា = ០.៦២)។ លើសពីនេះ ទស្សនៈគ្រូបង្រៀនលើការចូលរួមបង្កើតសហគមន៍សិក្សាវិជ្ជាជីវៈពីសំណាក់គណៈគ្រប់គ្រងសាលា ការបែងចែកធនធានសមស្របសម្រាប់សហគមន៍សិក្សាវិជ្ជាជីវៈ ការបែងចែកពេលវេលាសមស្របសម្រាប់សហគមន៍សិក្សាវិជ្ជាជីវៈ ការដឹកនាំបង្កើតផែនការសិក្សាវិជ្ជាជីវៈ និងការដឹកនាំបង្កើតកម្រងស្នាដៃវិជ្ជាជីវៈសម្រាប់អង្គភាព ក៏ទទួលបានលទ្ធផល "ល្អ" ដែលទទួលបានការយល់ស្របក្នុងតម្លៃមធ្យមរៀងគ្នា៖ ៤.១៧ , ៤.១៧ , ៤.២០ , ៤.០៦ , ៤.០៣ និងគម្លាតស្តង់ដារៀងគ្នា៖ ០.៦០ , ០.៥៧ , ០.៥៩ , ០.៦៥ , ០.៦៦។

**តារាងទី ១១៖ ទិន្នន័យស្តីពីទស្សនៈគណៈគ្រប់គ្រងលើអ្នកពាក់ព័ន្ធសំខាន់ៗដែលការគាំទ្រដល់សហគមន៍សិក្សាវិជ្ជាជីវៈ**

| ល.រ. | បរិយាយ | មធ្យម | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|---|
| ១ | មន្ទីរអប់រំ យុវជន និងកីឡាខេត្ត ជានាចក្នុវិស័យរួមរបស់ក្រសួង ដើម្បីឱ្យការអនុវត្តតាមសាលារៀនមានគំនិតរួមដូចគ្នា។ | ៤.០០ | ០.៦៣ | ល្អ |
| ២ | មន្ទីរអប់រំ យុវជន និងកីឡាខេត្ត ផ្តល់ការតម្រង់ទិសដល់សហគមន៍សិក្សាវិជ្ជាជីវៈគ្រប់លំដាប់ថ្នាក់ឱ្យយល់ដឹងពីការអនុវត្ត និងតួនាទីរបស់សហគមន៍សិក្សាវិជ្ជាជីវៈ។ | ៣.៥០ | ០.៨៤ | ល្អ |
| ៣ | មន្ទីរអប់រំ យុវជន និងកីឡាខេត្ត ផ្តល់ជំនួយផ្នែកធនធានមនុស្សដល់សហគមន៍សិក្សាវិជ្ជាជីវៈ។ | ៣.១៧ | ០.៤១ | ល្អ |
| ៤ | មន្ទីរអប់រំ យុវជន និងកីឡាខេត្ត ផ្តល់ជំនួយផ្នែកសម្ភារៈដល់សហគមន៍សិក្សាវិជ្ជាជីវៈ។ | ៣.១៧ | ០.៤១ | ល្អ |
| ៥ | មន្ទីរអប់រំ យុវជន និងកីឡាខេត្ត បានបែងចែកក្រុមទទួលបន្ទុកច្បាស់លាស់ ដើម្បីចូលរួមពិនិត្យការអនុវត្តសហគមន៍សិក្សាវិជ្ជាជីវៈ។ | ៣.១៧ | ០.៤១ | ល្អ |
| ៦ | ការិយាល័យអប់រំ យុវជន និងកីឡា ស្រុក/ក្រុង | ៣.៥០ | ០.៨៤ | ល្អ |

| | | | | |
|---|---|---|---|---|
| | ជានាចក្ខុវិស័យរួមរបស់ក្រសួង ដើម្បីឱ្យការអនុវត្តតាមសាលារៀនមានគំនិតរួមដូចគ្នា។ | | | |
| ៧ | ការិយាល័យអប់រំ យុវជន និងកីឡា ស្រុក/ក្រុង ផ្តល់ការតម្រង់ទិសដល់សហគមន៍សិក្សាវិជ្ជាជីវៈគ្រប់លំដាប់ថ្នាក់ ឱ្យយល់ដឹងពីការអនុវត្ត និងតួនាទីរបស់សហគមន៍សិក្សាវិជ្ជាជីវៈ។ | ៣.៣៣ | ០.៥២ | ល្អ |
| ៨ | ការិយាល័យអប់រំ យុវជន និងកីឡា ស្រុក/ក្រុង ផ្តល់ជំនួយផ្នែកធនធានមនុស្សដល់សហគមន៍សិក្សាវិជ្ជាជីវៈ។ | ៣.១៧ | ០.៤១ | ល្អ |
| ៩ | ការិយាល័យអប់រំ យុវជន និងកីឡាស្រុក/ក្រុង ផ្តល់ជំនួយផ្នែកសម្ភារៈដល់សហគមន៍សិក្សាវិជ្ជាជីវៈ។ | ៣.១៧ | ០.៤១ | ល្អ |
| ១០ | ការិយាល័យអប់រំ យុវជន និងកីឡា ស្រុក/ក្រុង បានបែងចែកក្រុមទទួលបន្ទុកច្បាស់លាស់ ដើម្បីចូលរួមពិនិត្យការអនុវត្តសហគមន៍សិក្សាវិជ្ជាជីវៈ។ | ៣.៣៣ | ០.៨២ | ល្អ |
| ១១ | គណៈគ្រប់គ្រងសាលាពន្យល់គ្រូបង្រៀនអំពីសារៈសំខាន់នៃសហគមន៍សិក្សាវិជ្ជាជីវៈ។ | ៤.៨៣ | ០.៤១ | ល្អ |
| ១២ | គណៈគ្រប់គ្រងសាលាចូលរួមក្នុងដំណើរការបង្កើតសហគមន៍សិក្សាវិជ្ជាជីវៈសម្រាប់គ្រូបង្រៀន។ | ៤.៨៣ | ០.៤១ | ល្អ |
| ១៣ | គណៈគ្រប់គ្រងសាលាបានបែងចែកធនធានសមស្របសម្រាប់សហគមន៍សិក្សាវិជ្ជាជីវៈ។ | ៤.៣៣ | ០.៥២ | ល្អ |
| ១៤ | គណៈគ្រប់គ្រងសាលាបានបែងចែកពេលវេលាសមស្របសម្រាប់សហគមន៍សិក្សាវិជ្ជាជីវៈ។ | ៤.៥០ | ០.៥៥ | ល្អ |
| ១៥ | គណៈគ្រប់គ្រងសាលាដឹកនាំបង្កើតផែនការសិក្សាវិជ្ជាជីវៈ។ | ៤.៥០ | ០.៥៥ | ល្អ |
| ១៦ | គណៈគ្រប់គ្រងសាលាដឹកនាំបង្កើតកម្រងស្នាដៃវិជ្ជាជីវៈសម្រាប់អង្គភាព។ | ៤.០០ | ០.៦៣ | ល្អ |
| ១៧ | គណៈគ្រប់គ្រងសាលាដឹកនាំបង្កើតកម្រងស្នាដៃវិជ្ជាជីវៈសម្រាប់គ្រូម្នាក់ៗ។ | ៤.០០ | ០.៦៣ | ល្អ |
| ១៨ | គណៈគ្រប់គ្រងសាលារៀបចំទីកន្លែងសម្រាប់គ្រូ | ៤.០០ | ០.៦៣ | ល្អ |

| | | | | |
|---|---|---|---|---|
| | ស្វ័យសិក្សាក្នុងសាលារៀន។ | | | |
| **សរុប** | | **៣.៨០** | **០.៥៥** | **ល្អ** |

តារាងខាងលើបង្ហាញថា ទស្សនៈគណៈគ្រប់គ្រងលើអ្នកពាក់ព័ន្ធសំខាន់ៗដែលការគាំទ្រដល់សហគមន៍សិក្សាវិជ្ជាជីវៈស្ថិតនៅកម្រិត “ល្អ” (មធ្យម = ៣.៨០ គម្លាតស្តង់ដា = ០.៥៥)។ លទ្ធផលខាងលើបង្ហាញថា ទស្សនៈគណៈគ្រប់គ្រងដូចគ្នានឹងទស្សនៈគ្រូបង្រៀនដែរ។ ជារួម ឃើញថា សហគមន៍សិក្សាវិជ្ជាជីវៈបានទទួលការគាំទ្រល្អពីសំណាក់ភាគីពាក់ព័ន្ធ ជាពិសេសពីសំណាក់គណៈគ្រប់គ្រងសាលាផ្ទាល់ ដែលបង្កលក្ខណៈឱ្យសហគមន៍អាចទទួលបានធនធាន និងពេលវេលាសម្រាប់អនុវត្តសហគមន៍សិក្សាវិជ្ជាជីវៈ។

**ង- ប្រព័ន្ធលើកទឹកចិត្តដល់សហគមន៍សិក្សាវិជ្ជាជីវៈ**

**តារាងទី ១២៖ ទិន្នន័យស្តីពីទស្សនៈគ្រូបង្រៀនលើប្រព័ន្ធលើកទឹកចិត្តដល់សហគមន៍សិក្សាវិជ្ជាជីវៈ**

| ល.រ. | បរិយាយ | មធ្យម | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|---|
| ១ | សមាជិកសហគមន៍មានឱកាសចូលរួមជាវាគ្មិនក្នុងសន្និសីទ ឬសិក្ខាសាលា។ | ៣.៨៨ | ០.៦៥ | ល្អ |
| ២ | សមាជិកសហគមន៍ទទួលបានការជំរុញឱ្យបោះពុម្ពផ្សាយកិច្ចការស្រាវជ្រាវរបស់ខ្លួន។ | ៣.៧៦ | ០.៧២ | ល្អ |
| ៣ | សហគមន៍ទាំងមូលទទួលបានការផ្តល់បច្ចេកទេសពីក្រសួងអប់រំ យុវជន និងកីឡា។ | ៣.៧៧ | ០.៨០ | ល្អ |
| ៤ | សហគមន៍ទាំងមូលទទួលបានលំហូរថវិកាពីក្រសួងអប់រំ យុវជន និងកីឡា។ | ៣.៧៦ | ០.៨៤ | ល្អ |
| ៥ | សមាជិកសហគមន៍ទទួលបានការវាយតម្លៃការចូលរួមក្នុងសហគមន៍សិក្សាវិជ្ជាជីវៈជាក្រេឌីតដែលផ្សារភ្ជាប់ទៅនឹងគន្លងអាជីព។ | ៣.៨៣ | ០.៨០ | ល្អ |
| ៦ | អ្នកមានស្នាដៃល្អទទួលបានឱកាសចូលរួមក្នុងវគ្គបំប៉នកម្រិតជាតិ និងអន្តរជាតិ។ | ៣.៨០ | ០.៦៦ | ល្អ |
| ៧ | សមាជិកសហគមន៍មានឱកាសចូលរួមជាវាគ្មិន | ៣.៧៣ | ០.៧១ | ល្អ |

| | | | | |
|---|---|---|---|---|
| | ក្នុងសន្និសីទ ឬសិក្ខាសាលាប្រចាំត្រីមាស ឬឆមាសរបស់ថ្នាក់ខេត្ត ដើម្បីចែករំលែកបទពិសោធន៍។ | | | |
| ៨ | មន្ទីរអប់រំ យុវជន និងកីឡាខេត្តចុះជួយ និងពិនិត្យការអនុវត្តសហគមន៍សិក្សាវិជ្ជាជីវៈជាប្រចាំ។ | ៣.៥៦ | ០.៨៨ | ល្អ |
| ៩ | មន្ទីរអប់រំ យុវជន និងកីឡាខេត្តធ្វើបញ្ជីឈ្មោះ និងបញ្ជូនឈ្មោះសហគមន៍សិក្សាវិជ្ជាជីវៈដែលគ្រប់លក្ខខណ្ឌចូលគន្លងអាជីពមកថ្នាក់ក្រសួង។ | ៣.៦១ | ០.៩៤ | ល្អ |
| ១០ | សាលារៀនរៀបចំឱ្យមានកន្លែងសម្រាប់បុគ្គលិកត្រៀមកិច្ចការបង្រៀន និងធ្វើស្វ័យសិក្សា។ | ៣.៩២ | ០.៨៥ | ល្អ |
| ១១ | សាលារៀនបង្កើតគណៈកម្មការវាយតម្លៃលើភស្តុតាងបុគ្គលិកអប់រំ ដើម្បីចូលក្នុងគន្លងអាជីពគ្រូបង្រៀន។ | ៣.៩៥ | ០.៦៦ | ល្អ |
| ១២ | សាលារៀនរៀបចំកម្មវិធីសហគមន៍សិក្សាវិជ្ជាជីវៈទៅតាមតម្រូវការជាក់ស្តែង។ | ៤.០២ | ០.៧១ | ល្អ |
| ១៣ | សាលារៀនរក្សាទុករាល់កម្រងស្នាដៃសាលារៀន និងគ្រូបង្រៀនសម្រាប់ជាភស្តុតាងវាយតម្លៃ។ | ៣.៩៥ | ០.៧៧ | ល្អ |
| | **សរុប** | **៣.៨១** | **០.៧៧** | **ល្អ** |

តារាងខាងលើបង្ហាញថា ទស្សនៈគ្រូបង្រៀនលើប្រព័ន្ធលើកទឹកចិត្តដល់សហគមន៍សិក្សាវិជ្ជាជីវៈស្ថិតនៅកម្រិត “ល្អ” (មធ្យម = ៣.៨១ គម្លាតស្តង់ដា = ០.៧៧)។ គ្រប់សូចនាករទាំងអស់ទទួលបានលទ្ធផល “ល្អ”។ លទ្ធផលខាងលើបង្ហាញថា សហគមន៍សិក្សាវិជ្ជាជីវៈទទួលបានការលើកទឹកចិត្តតាមរយៈការផ្តល់ឱកាសក្នុងការចូលរួមអភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈ និងចែករំលែកបទពិសោធន៍របស់ខ្លួនក្នុងសន្និសីទនានា។ លើសពីនេះ ការផ្តល់លំហូរថវិកាពីក្រសួងអប់រំ យុវជន និងកីឡាទទួលបានការយល់ស្របក្នុងកម្រិត “ល្អ” ផងដែរ (មធ្យម = ៣.៧៦ គម្លាតស្តង់ដា = ០.៨៤)។ ជារួម ឃើញថា សហគមន៍សិក្សាវិជ្ជាជីវៈទទួលនបានការការលើកទឹកចិត្តតាមរយៈឱកាសអភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈ និងតាមរយៈការផ្តល់ហិរញ្ញវត្ថុ។

**តារាងទី ១៣៖ ទិន្នន័យស្ដីពីទស្សនៈគណៈគ្រប់គ្រងលើប្រព័ន្ធលើកទឹកចិត្តដល់សហគមន៍សិក្សាវិជ្ជាជីវៈ**

| ល.រ | បរិយាយ | មធ្យម | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|---|
| ១ | សមាជិកសហគមន៍មានឱកាសចូលរួមជាវាគ្មិនក្នុងសន្និសីទ ឬសិក្ខាសាលា។ | ៣.៦៧ | ០.៨២ | ល្អ |
| ២ | សមាជិកសហគមន៍ទទួលបានការជំរុញឱ្យបោះពុម្ពផ្សាយកិច្ចការស្រាវជ្រាវរបស់ខ្លួន។ | ៣.៦៧ | ០.៨២ | ល្អ |
| ៣ | សហគមន៍ទាំងមូលទទួលបានការផ្តល់បច្ចេកទេសពីក្រសួងអប់រំ យុវជន និងកីឡា។ | ៣.៦៧ | ០.៨២ | ល្អ |
| ៤ | សហគមន៍ទាំងមូលទទួលបានលំហូរថវិកាពីក្រសួងអប់រំ យុវជន និងកីឡា។ | ៤.៣៣ | ០.៥២ | ល្អណាស់ |
| ៥ | សមាជិកសហគមន៍ទទួលបានការវាយតម្លៃការចូលរួមក្នុងសហគមន៍សិក្សាវិជ្ជាជីវៈជាក្រេឌីត ដែលផ្សារភ្ជាប់ទៅនឹងគន្លងអាជីព។ | ៣.៨៣ | ០.៤១ | ល្អ |
| ៦ | អ្នកមានស្នាដៃល្អទទួលបានឱកាសចូលរួមក្នុងវគ្គបំប៉នកម្រិតជាតិ និងអន្តរជាតិ។ | ៣.៦៧ | ០.៨២ | ល្អ |
| ៧ | សមាជិកសហគមន៍មានឱកាសចូលរួមជាវាគ្មិនក្នុងសន្និសីទ ឬសិក្ខាសាលាប្រចាំត្រីមាស ឬឆមាសរបស់ថ្នាក់ខេត្ត ដើម្បីចែករំលែកបទពិសោធន៍។ | ៣.៦៧ | ០.៥២ | ល្អ |
| ៨ | មន្ទីរអប់រំ យុវជន និងកីឡាខេត្តចុះជួយ និងពិនិត្យការអនុវត្តសហគមន៍សិក្សាវិជ្ជាជីវៈជាប្រចាំ។ | ៣.៣៣ | ០.៥២ | មធ្យម |
| ៩ | មន្ទីរអប់រំ យុវជន និងកីឡាខេត្តធ្វើបញ្ជីឈ្មោះ និងបញ្ជូនឈ្មោះសហគមន៍សិក្សាវិជ្ជាជីវៈដែលគ្រប់លក្ខខណ្ឌចូលគន្លងអាជីពមកថ្នាក់ក្រសួង។ | ៣.១៧ | ០.៤១ | មធ្យម |
| ១០ | សាលារៀនរៀបចំឱ្យមានកន្លែងសម្រាប់បុគ្គលិកត្រៀមកិច្ចការបង្រៀន និងធ្វើស្វ័យសិក្សា។ | ៤.១៧ | ០.៧៥ | ល្អ |
| ១១ | សាលារៀនបង្កើតគណៈកម្មការវាយតម្លៃលើកស្ទួតាងបុគ្គលិកអប់រំ ដើម្បីចូលក្នុងគន្លងអាជីពគ្រូបង្រៀន។ | ៤.១៧ | ០.៧៥ | ល្អ |
| ១២ | សាលារៀនរៀបចំកម្មវិធីសហគមន៍សិក្សាវិជ្ជាជីវៈទៅតាមតម្រូវការជាក់ស្តែង។ | ៤.១៧ | ០.៧៥ | ល្អ |

| | | | | |
|---|---|---|---|---|
| ១៣ | សាលារៀនរក្សាទុករាល់កម្រងស្នាដៃសាលារៀន និងគ្រូបង្រៀនសម្រាប់ជាភស្តុតាងវាយតម្លៃ។ | ៤.៣៣ | ០.៥២ | ល្អណាស់ |
| **សរុប** | | **៣.៨៣** | **០.៦៤** | **ល្អ** |

តារាងខាងលើបង្ហាញពីទស្សនៈគណៈគ្រប់គ្រងលើប្រព័ន្ធលើកទឹកចិត្តសហគមន៍សិក្សាវិជ្ជាជីវៈ។ ទស្សនៈគណៈគ្រប់គ្រងស្ថិតនៅកម្រិត “ល្អ” (មធ្យម = ៣.៨៣ គម្លាតស្តង់ដា = ០.៦៤)។ សូចនាករភាគច្រើនទទួលបានលទ្ធផល “ល្អ”។ សូចនាករដែលទទួលបានការយល់ស្របក្នុងកម្រិត “ល្អណាស់” មានពីរ គឺ សូចនាករអំពីលំហូរថវិកាពីក្រសួងអប់រំ យុវជន និងកីឡា (មធ្យម = ៤.៣៣ គម្លាតស្តង់ដា = ០.៥២) និងសូចនាករអំពីការរក្សាទុកកម្រងស្នាដៃសាលារៀន និងគ្រូបង្រៀនសម្រាប់ជាភស្តុតាងវាយតម្លៃ (មធ្យម = ៤.៣៣ គម្លាតស្តង់ដា = ០.៥២)។ លទ្ធផលខាងលើបង្ហាញថា ទស្សនៈគណៈគ្រប់គ្រងមានភាពស្របគ្នានឹងទស្សនៈគ្រូបង្រៀន។ ដោយឡែក មានសូចនាករចំនួនពីរដែលទទួលបានការយល់ស្របក្នុងកម្រិត “មធ្យម” គឺ សូចនាករអំពីការចុះជួយ និងពិនិត្យការអនុវត្តសហគមន៍សិក្សាវិជ្ជាជីវៈជាប្រចាំពីសំណាក់មន្ទីរអប់រំ យុវជន និងកីឡា (មធ្យម = ៣.៣៣ គម្លាតស្តង់ដា = ០.៥២) និងសូចនាករអំពីការធ្វើបញ្ជីឈ្មោះ និងបញ្ជូនឈ្មោះសហគមន៍សិក្សាវិជ្ជាជីវៈដែលគ្រប់លក្ខខណ្ឌចូលគន្លងអាជីពមកថ្នាក់ក្រសួងរបស់មន្ទីរអប់រំ យុវជន និងកីឡាខេត្ត(មធ្យម = ៣.១៧ គម្លាតស្តង់ដា = ០.៤១)។ ប៉ុន្តែ ជារួមឃើញថា សហគមន៍សិក្សាវិជ្ជាជីវៈទទួលបានការលើកទឹកចិត្តល្អ តាមរយៈការផ្តល់ឱកាសក្នុងការចូលរួមអភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈ និងចែករំលែកបទពិសោធន៍ក្នុងសន្និសីទនានា និងតាមរយៈការផ្តល់នូវហិរញ្ញវត្ថុសម្រាប់ដំណើរការ។

**តារាងទី ១៤៖ លទ្ធផលសង្ខេបស្តីពីទស្សនៈគ្រូបង្រៀនលើការអនុវត្តសហគមន៍សិក្សាវិជ្ជាជីវៈ**

| ល.រ. | បរិយាយ | មធ្យម | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|---|
| ១ | ការសិក្សាជាក្រុម | ៣.៩១ | ០.៧៨ | ល្អ |
| ២ | ការសង្កេតថ្នាក់ និងប្រឹក្សា | ៣.៩៥ | ០.៦៩ | ល្អ |
| ៣ | ភារកិច្ចរបស់សហគមន៍សិក្សាវិជ្ជាជីវៈ | ៣.៩៧ | ០.៦៥ | ល្អ |

| | | | | |
|---|---|---|---|---|
| ៤ | អ្នកពាក់ព័ន្ធសំខាន់ៗ | ៣.៨៨ | ០.៧៧ | ល្អ |
| ៥ | ប្រព័ន្ធលើកទឹកចិត្តដល់សហគមន៍សិក្សាវិជ្ជាជីវៈ | ៣.៨១ | ០.៧៧ | ល្អ |
| | **សរុប** | **៣.៩០** | **០.៧៣** | **ល្អ** |

តារាងខាងលើបង្ហាញថា ចំពោះទស្សនៈគ្រូបង្រៀន ការអនុវត្តសហគមន៍សិក្សាវិជ្ជាជីវៈនៅកម្រិតមធ្យមសិក្សាក្នុងខេត្តកំពង់ចាមស្ថិតក្នុងកម្រិត “ល្អ” (មធ្យម = ៣.៩០ គម្លាតស្តង់ដា = ០.៧៣)។ ចំណុចអនុវត្តធំៗទាំង៥ទទួលបានលទ្ធផល “ល្អ” ដូចគ្នា។ លទ្ធផលនេះបញ្ជាក់ឱ្យឃើញថា សហគមន៍សិក្សាវិជ្ជាជីវៈ បានចូលរួមអនុវត្តការសិក្សាជាក្រុម ការសង្កេតថ្នាក់ និងប្រឹក្សា បានទៀងទាត់។ ជាមួយគ្នានេះផងដែរ ការអនុវត្តភារកិច្ចរបស់សហគមន៍ ការគាំទ្រ និងលើកទឹកចិត្តពីសំណាក់អ្នកពាក់ព័ន្ធក៏ត្រូវបានអនុវត្តបានល្អ។

**តារាងទី ១៥៖ លទ្ធផលសង្ខេបស្តីពីទស្សនៈគណៈគ្រប់គ្រងលើការអនុវត្តសហគមន៍សិក្សាវិជ្ជាជីវៈ**

| ល.រ. | បរិយាយ | មធ្យម | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|---|
| ១ | ការសិក្សាជាក្រុម | ៤.៤៤ | ០.៥៣ | ល្អណាស់ |
| ២ | ការសង្កេតថ្នាក់ និងប្រឹក្សា | ៤.១៦ | ០.៧៨ | ល្អ |
| ៣ | ភារកិច្ចរបស់សហគមន៍សិក្សាវិជ្ជាជីវៈ | ៤.០១ | ០.៦២ | ល្អ |
| ៤ | អ្នកពាក់ព័ន្ធសំខាន់ៗ | ៣.៨០ | ០.៥៥ | ល្អ |
| ៥ | ប្រព័ន្ធលើកទឹកចិត្តដល់សហគមន៍សិក្សាវិជ្ជាជីវៈ | ៣.៨៣ | ០.៦៤ | ល្អ |
| | **សរុប** | **៤.០៥** | **០.៦២** | **ល្អ** |

តារាងខាងលើបង្ហាញពីទស្សនៈគណៈគ្រប់គ្រងលើការអនុវត្តសហគមន៍សិក្សាវិជ្ជាជីវៈនៅកម្រិតមធ្យមសិក្សាក្នុងខេត្តកំពង់ចាម។ លទ្ធផលបង្ហាញថា ការយល់ឃើញរបស់គណៈគ្រប់គ្រងស្របគ្នានឹងការយល់ឃើញរបស់គ្រូបង្រៀន។ ដោយឡែក ទស្សនៈគណៈគ្រប់គ្រងលើការសិក្សាជាក្រុម ដែលស្ថិតនៅក្នុងកម្រិត "ល្អណាស់" (មធ្យម = ៤.៤៤ គម្លាតស្តង់ដា = ០.៥៣) ខ្ពស់ជាងទស្សនៈគ្រូបង្រៀន។ ចំពោះចំណុចអនុវត្តផ្សេងៗទៀតមានតម្លៃមធ្យមស្ថិតនៅក្នុងកម្រិត "ល្អ" ដូចគ្នាទៅនឹងទស្សនៈគ្រូបង្រៀនដែរ។ ជារួម ទស្សនៈគណៈគ្រប់គ្រងស្ថិតក្នុងកម្រិត "ល្អ" (មធ្យម = ៤.០៥ គម្លាតស្តង់ដា = ០.៦២)។

**តារាងទី ១៦៖ ទិន្នន័យសង្ខេបស្តីពីទស្សនៈគ្រូបង្រៀន និងគណៈគ្រប់គ្រងលើការអនុវត្តសហគមន៍សិក្សាវិជ្ជាជីវៈ**

| | | ការសិក្សាជាក្រុម | ការសង្កេតថ្នាក់ និងប្រឹក្សា | ភារកិច្ចសហគមន៍ | អ្នកពាក់ព័ន្ធសំខាន់ៗ | ប្រព័ន្ធលើកទឹកចិត្តសហគមន៍ | សរុបរួម |
|---|---|---|---|---|---|---|---|
| គ្រូបង្រៀន | មធ្យម | ៣.៩១ | ៣.៩៥ | ៣.៩៧ | ៣.៨៨ | ៣.៨១ | ៣.៩០ |
| | គម្លាតស្តង់ដា | ០.៧៨ | ០.៦៩ | ០.៦៥ | ០.៧៧ | ០.៧៧ | ០.៧៣ |
| | កម្រិតចង្អុលបង្ហាញ | ល្អ | ល្អ | ល្អ | ល្អ | ល្អ | ល្អ |
| គណៈគ្រប់គ្រង | មធ្យម | ៤.៤៤ | ៤.១៦ | ៤.០១ | ៣.៨០ | ៣.៨៣ | ៤.០៥ |
| | គម្លាតស្តង់ដា | ០.៥៣ | ០.៧៨ | ០.៦២ | ០.៥៥ | ០.៦៤ | ០.៦២ |
| | កម្រិតចង្អុលបង្ហាញ | ល្អណាស់ | ល្អ | ល្អ | ល្អ | ល្អ | ល្អ |
| សរុប | មធ្យម | ៤.១៨ | ៤.០៦ | ៣.៩៩ | ៣.៨៤ | ៣.៨២ | **៣.៩៨** |
| | គម្លាតស្តង់ដា | ០.៦៦ | ០.៧៤ | ០.៦៤ | ០.៦៦ | ០.៧១ | **០.៦៨** |
| | កម្រិតចង្អុលបង្ហាញ | ល្អ | ល្អ | ល្អ | ល្អ | ល្អ | **ល្អ** |

តារាងខាងលើបង្ហាញឱ្យឃើញថា ការអនុវត្តសហគមន៍សិក្សាវិជ្ជាជីវៈនៅកម្រិតមធ្យមសិក្សាក្នុងខេត្តកំពង់ចាមស្ថិតនៅកម្រិត "ល្អ" (មធ្យម = ៣.៩៨ គម្លាតស្តង់ដា = ០.៦៨)។ លទ្ធផលនេះអាចសរុបជារួមបានថា ការអនុវត្តសហគមន៍សិក្សាវិជ្ជាជីវៈនៅកម្រិតមធ្យមសិក្សាក្នុងខេត្តកំពង់ចាមដំណើរការបានល្អ។ គ្រូបង្រៀនយល់ដឹងពីការសិក្សាជាក្រុម និងអនុវត្តបាននូវការសង្កេតថ្នាក់ និងប្រឹក្សា។ លើសពីនេះគ្រូបង្រៀនក៏មានការយល់ដឹងពីភារកិច្ចដែលខ្លួនត្រូវអនុវត្តក្នុងសហគមន៍សិក្សាវិជ្ជាជីវៈ។ ម្យ៉ាងវិញទៀត ការអនុវត្តក្នុងសហគមន៍សិក្សាវិជ្ជាជីវៈបានល្អ ដោយសារមានការចូលរួមពីសំណាក់ភាគីពាក់ព័ន្ធ និងទទួលបានការលើកទឹកចិត្តតាមរយៈការផ្តល់ឱកាសអភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈ និងការផ្តល់ហិរញ្ញវត្ថុគ្រប់គ្រាន់។

**៤.១.២- ការវិភាគទិន្នន័យដែលបានមកពីកម្រងសំណួរស្តីពីទស្សនៈគ្រូបង្រៀនលើបញ្ហាប្រឈមក្នុងការអនុវត្តសហគមន៍សិក្សាវិជ្ជាជីវៈនៅកម្រិតមធ្យមសិក្សាក្នុងខេត្តកំពង់ចាម**

**ក- បន្ទុកការងារ និងឧបសគ្គពេលវេលា**

**តារាងទី ១៧៖ ទិន្នន័យស្តីពីទស្សនៈគ្រូបង្រៀនលើបន្ទុកការងារ និងឧបសគ្គពេលវេលា**

| ល.រ. | បរិយាយ | មធ្យម | គម្លាត ស្តង់ដា | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|---|
| ១ | មន្ទីរអប់រំ យុវជន និងកីឡាខេត្ត ដាក់កិច្ចការងាររដ្ឋបាលគ្រូបង្រៀនច្រើន។ | ៣.២៨ | ០.៩៧ | មធ្យម |
| ២ | សមាជិកសហគមន៍ត្រូវបង្រៀនច្រើនថ្នាក់។ | ៣.៣៣ | ០.៩២ | មធ្យម |
| ៣ | សមាជិកសហគមន៍ត្រូវរៀបចំសម្ភារៈបង្រៀនច្រើនថ្នាក់។ | ៣.៣៨ | ០.៨៩ | មធ្យម |
| ៤ | សមាជិកសហគមន៍ត្រូវធ្វើការវាយតម្លៃលទ្ធផលសិក្សារបស់សិស្សច្រើនថ្នាក់។ | ៣.៣៦ | ០.៩៤ | មធ្យម |
| ៥ | គណៈគ្រប់គ្រងតម្រូវឱ្យការប្រជុំមានលក្ខណៈសង្ខេបខ្លី។ | ៣.៣៦ | ០.៩៤ | មធ្យម |
| | **សរុប** | **៣.៣៤** | **០.៩៣** | មធ្យម |

តារាងខាងលើបង្ហាញឱ្យឃើញថា ទស្សនៈគ្រូបង្រៀនលើបន្ទុកការងារ និងឧបសគ្គពេលវេលា ចំពោះសហគមន៍សិក្សាវិជ្ជាជីវៈស្ថិតនៅកម្រិត “មធ្យម” (មធ្យម = ៣.៣៤ គម្លាតស្តង់ដា = ០.៩៣)។ បានន័យថា គ្រូបង្រៀនមានការយល់ស្របតិចតួចលើបន្ទុកការងារ និងឧបសគ្គពេលវេលា។ សូចនាករទាំងអស់ទទួលបានការយល់ស្របក្នុងកម្រិត “មធ្យម” ដូចគ្នា។ លទ្ធផលបង្ហាញថា បន្ទុកការងារ និងឧបសគ្គពេលវេលា ជាបញ្ហាប្រឈមតិចតួចសម្រាប់ការអនុវត្តសហគមន៍សិក្សាវិជ្ជាជីវៈ។

**តារាងទី ១៨៖ ទិន្នន័យស្តីពីទស្សនៈគណៈគ្រប់គ្រងលើបន្ទុកការងារ និងឧបសគ្គពេលវេលា**

| ល.រ. | បរិយាយ | មធ្យម | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|---|
| ១ | មន្ទីរអប់រំ យុវជន និងកីឡាខេត្ត ដាក់កិច្ចការងាររដ្ឋបាលគ្រូបង្រៀនច្រើន។ | ៣.៣៣ | ០.៨២ | មធ្យម |
| ២ | សមាជិកសហគមន៍ត្រូវបង្រៀនច្រើនថ្នាក់។ | ៣.១៦ | ០.៩៨ | មធ្យម |
| ៣ | សមាជិកសហគមន៍ត្រូវរៀបចំសម្ភារៈបង្រៀនច្រើនថ្នាក់។ | ៣.៦៧ | ០.៥១ | ល្អ |
| ៤ | សមាជិកសហគមន៍ត្រូវធ្វើការវាយតម្លៃលទ្ធផលសិក្សារបស់សិស្សច្រើនថ្នាក់។ | ៣.០០ | ០.៥៤ | មធ្យម |
| ៥ | គណៈគ្រប់គ្រងតម្រូវឱ្យការប្រជុំមានលក្ខណៈសង្ខេបខ្លី។ | ៤.០០ | ០.០០ | ល្អ |
| | **សរុប** | **៣.៤៣** | **០.៥៧** | **ល្អ** |

តារាងខាងលើបង្ហាញពីទស្សនៈគណៈគ្រប់គ្រងលើបន្ទុកការងារ និងឧបសគ្គពេលវេលាចំពោះសហគមន៍សិក្សាវិជ្ជាជីវៈ។ ទស្សនៈគណៈគ្រប់គ្រងស្ថិតនៅកម្រិត “មធ្យម” ទៅលើសូចនាករចំនួនបី គឺការដាក់កិច្ចការងាររដ្ឋបាលគ្រូបង្រៀនច្រើនពីសំណាក់មន្ទីរអប់រំ យុវជន និងកីឡាខេត្ត (មធ្យម = ៣.៣៣ គម្លាតស្តង់ដា = ០.៨២) ការដែលសមាជិកសហគមន៍ត្រូវបង្រៀនសិស្សច្រើនថ្នាក់ (មធ្យម = ៣.១៦ គម្លាតស្តង់ដា = ០.៩៨) និង ការដែលត្រូវវាយតម្លៃលទ្ធផលសិក្សារបស់សិស្សច្រើនថ្នាក់របស់សមាជិកសហគមន៍ (មធ្យម = ៣.០០ គម្លាតស្តង់ដា = ០.៥៤)។ សូចនាករពីរផ្សេងទៀតទទួលបានការយល់ស្របក្នុងកម្រិត “ល្អ” គឺ ការដែលគណៈគ្រប់គ្រងតម្រូវឱ្យការប្រជុំមានលក្ខណៈសង្ខេបខ្លី (មធ្យម = ៤.០០ គម្លាតស្តង់ដា = ០.០០) និងការដែលសមាជិកសហគមន៍ត្រូវរៀបចំសម្ភារៈបង្រៀនច្រើនថ្នាក់

(មធ្យម = ៣.៦៧ គម្លាតស្តង់ដា = ០.៥១)។ លទ្ធផលខាងលើបង្ហាញថា គណៈគ្រប់គ្រងមានការយល់ឃើញខុសគ្នាបន្តិចពីទស្សនៈគ្រូបង្រៀន។ ជារួម បន្ទុកការងារ និងឧបសគ្គពេលវេលាជាបញ្ហាប្រឈមសម្រាប់ការអនុវត្តសហគមន៍សិក្សាវិជ្ជាជីវៈនៅទីនេះ យោងតាមទស្សនៈគណៈគ្រប់គ្រង។

**ខ- ការយល់ដឹងមិនច្បាស់ពីការអនុវត្តសហគមន៍សិក្សាវិជ្ជាជីវៈ**

**តារាងទី ១៩៖ ទិន្នន័យស្តីពីទស្សនៈគ្រូបង្រៀនលើការយល់ដឹងមិនច្បាស់ពីការអនុវត្តសហគមន៍សិក្សាវិជ្ជាជីវៈ**

| ល.រ. | បរិយាយ | មធ្យម | គម្លាត ស្តង់ដា | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|---|
| ១ | សាលារៀនមានឯកសារណែនាំស្តីពីការអនុវត្ត និងរបៀបអនុវត្តឱ្យបានពិស្តារ គ្រប់គ្រាន់។ | ៣.៥៦ | ០.៧៩ | ល្អ |
| ២ | ការប្រជុំសហគមន៍សិក្សាវិជ្ជាជីវៈផ្តោតតែទៅលើតែខ្លឹមសារដែលមានក្នុងកម្មវិធីសិក្សា។ | ៣.១៧ | ០.៩០ | មធ្យម |
| ៣ | ការប្រជុំសហគមន៍សិក្សាវិជ្ជាជីវៈផ្តោតតែទៅលើលំហាត់ដែលត្រូវដាក់ឱ្យសិស្សធ្វើ។ | ២.៩៧ | ០.៩៦ | មធ្យម |
| ៤ | ការប្រជុំសហគមន៍សិក្សាវិជ្ជាជីវៈបានយកលទ្ធផលសិស្សមកពិភាក្សា។ | ៣.៦៤ | ០.៩២ | ល្អ |
| | **សរុប** | **៣.៣៤** | **០.៨៩** | **មធ្យម** |

តារាងខាងលើបង្ហាញថា ទស្សនៈគ្រូបង្រៀនលើការយល់ដឹងមិនច្បាស់ពីការអនុវត្តសហគមន៍សិក្សាវិជ្ជាជីវៈ ស្ថិតនៅក្នុងកម្រិត "មធ្យម" (មធ្យម = ៣.៣៤ គម្លាតស្តង់ដា = ០.៨៩)។ សូចនាករចំនួនពីរទទួលបានការយល់ស្របក្នុងកម្រិត "មធ្យម" ដូចគ្នា គឺ ការប្រជុំសហគមន៍សិក្សាវិជ្ជាជីវៈផ្តោតតែទៅលើខ្លឹមសារដែលមានក្នុងកម្មវិធីសិក្សា (មធ្យម = ៣.១៧ គម្លាតស្តង់ដា = ០.៩០) និង ការប្រជុំសហគមន៍សិក្សាវិជ្ជាជីវៈផ្តោតតែទៅលើលំហាត់ដែលត្រូវដាក់ឱ្យសិស្សធ្វើ (មធ្យម = ២.៩៧ គម្លាតស្តង់-ដា = ០.៩៦)។ សូចនាករចំនួនពីរផ្សេងទៀតទទួលបានការយល់ស្របក្នុងកម្រិត "ល្អ" គឺ សាលារៀនមានឯកសារណែនាំស្តីពីការអនុវត្ត និងរបៀបអនុវត្តឱ្យបានពិស្តារគ្រប់គ្រាន់(មធ្យម = ៣.៥៦ គម្លាតស្តង់

ដា = ០.៧៩) និង ការប្រជុំសហគមន៍សិក្សាវិជ្ជាជីវៈបានយកលទ្ធផលសិស្សមកពិភាក្សា (មធ្យម = ៣.៦៤ គម្លាតស្តង់ដា = ០.៩២)។ លទ្ធផលជារួមបង្ហាញថា ការយល់ដឹងមិនច្បាស់ពីការអនុវត្តសហគមន៍សិក្សាវិជ្ជាជីវៈជាបញ្ហាប្រឈមតិចតួចសម្រាប់ការអនុវត្តសហគមន៍សិក្សាវិជ្ជាជីវៈនៅទីនេះ។

**តារាងទី ២០៖ ទិន្នន័យស្តីពីទស្សនៈគណៈគ្រប់គ្រងលើការយល់ដឹងមិនច្បាស់ពីការអនុវត្តសហគមន៍សិក្សាវិជ្ជាជីវៈ**

| ល.រ. | បរិយាយ | មធ្យម | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|---|
| ១ | សាលារៀនមានឯកសារណែនាំស្តីពីការអនុវត្ត និងរបៀបអនុវត្តឱ្យបានពិស្តារ គ្រប់គ្រាន់។ | ៣.៥០ | ០.៥៤ | ល្អ |
| ២ | ការប្រជុំសហគមន៍សិក្សាវិជ្ជាជីវៈផ្តោតតែទៅលើខ្លឹមសារដែលមានក្នុងកម្មវិធីសិក្សា។ | ៣.៦៧ | ០.៨២ | ល្អ |
| ៣ | ការប្រជុំសហគមន៍សិក្សាវិជ្ជាជីវៈផ្តោតតែទៅលើលំហាត់ដែលត្រូវដាក់ឱ្យសិស្សធ្វើ។ | ២.៦៧ | ១.០៣ | មធ្យម |
| ៤ | ការប្រជុំសហគមន៍សិក្សាវិជ្ជាជីវៈបានយកលទ្ធផលសិស្សមកពិភាក្សា។ | ៣.៦៧ | ០.៨២ | មធ្យម |
| | **សរុប** | **៣.៣៨** | **០.៨០** | **មធ្យម** |

តារាងខាងលើបង្ហាញឱ្យឃើញថា ទស្សនៈគណៈគ្រប់គ្រងលើការយល់ដឹងមិនច្បាស់ពីការអនុវត្តសហគមន៍សិក្សាវិជ្ជាជីវៈស្ថិតនៅកម្រិត “មធ្យម” (មធ្យម = ៣.៣៨ គម្លាតស្តង់ដា = ០.៨០)។ លទ្ធផលជារួមស្ថិតក្នុងកម្រិតដូចគ្នាទៅនឹងទស្សនៈគ្រូបង្រៀន គឺ ការយល់ដឹងមិនច្បាស់ពីការអនុវត្តសហគមន៍សិក្សាវិជ្ជាជីវៈ ជាបញ្ហាប្រឈមតិចតួចសម្រាប់ការអនុវត្តសហគមន៍សិក្សាវិជ្ជាជីវៈនៅទីនេះឡើយ។

**គ- កង្វះវប្បធម៌ពិភាក្សា**

**តារាងទី ២១៖ ទិន្នន័យស្តីពីទស្សនៈគ្រូបង្រៀនលើកង្វះវប្បធម៌ពិភាក្សា**

| ល.រ. | បរិយាយ | មធ្យម | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|---|

| | | | | |
|---|---|---|---|---|
| ១ | សមាជិកសហគមន៍ចូលចិត្តធ្វើការតែឯង។ | ២.៥៣ | ០.៩៦ | ខ្សោយ |
| ២ | សមាជិកសហគមន៍មានអារម្មណ៍ខ្មាសអៀនក្នុងការបើកចំហបញ្ហាថ្នាក់រៀនរបស់ខ្លួនទៅកាន់អ្នកដទៃ។ | ២.៥៨ | ១.០៨ | ខ្សោយ |
| ៣ | សមាជិកសហគមន៍មានអារម្មណ៍ខ្មាសអៀនក្នុងការបង្ហាញការអនុវត្តការបង្រៀនរបស់ខ្លួនទៅកាន់អ្នកដទៃ។ | ២.៤០ | ១.០២ | ខ្សោយ |
| ៤ | សមាជិកសហគមន៍មានអារម្មណ៍ថាការចូលរួមប្រជុំសហគមន៍សិក្សាវិជ្ជាជីវៈមិនបានផ្តល់ជាប្រយោជន៍អ្វីសោះដល់ការបង្រៀនរបស់ខ្លួនសោះ។ | ២.២៧ | ០.៩៤ | ខ្សោយ |
| | **សរុប** | **២.៤៥** | **១.០០** | **ខ្សោយ** |

តារាងខាងលើបង្ហាញថា ទស្សនៈគ្រូបង្រៀនលើកង្វះវប្បធម៌សហការក្នុងសហគមន៍សិក្សាវិជ្ជាជីវៈស្ថិតនៅកម្រិត “ខ្សោយ” (មធ្យម = ២.២៧ គម្លាតស្តង់ដា = ០.៩៤)។ សូចនាករទាំងអស់ទទួលបានលទ្ធផល “ខ្សោយ” ដូចគ្នា។ លទ្ធផលនេះបង្ហាញឱ្យឃើញថា សមាជិកសហគមន៍មានស្មារតីសហការបើកទូលាយចំពោះការចែករំលែកអំពីការអនុវត្តការងារ បើកចំហបញ្ហាទៅកាន់ការពិភាក្សា និងមានការយល់ដឹងពីសារៈសំខាន់នៃការចូលរួមប្រជុំសហគមន៍សិក្សាវិជ្ជាជីវៈ។ ជារួមមក កង្វះវប្បធម៌សហការក្នុងសហគមន៍សិក្សាវិជ្ជាជីវៈ មិនមែនជាបញ្ហាប្រឈមសម្រាប់ការអនុវត្តសហគមន៍សិក្សាវិជ្ជាជីវៈឡើយ។

**តារាងទី ២២៖ ទិន្នន័យស្តីពីទស្សនៈគណៈគ្រប់គ្រងលើកង្វះវប្បធម៌ពិភាក្សា**

| ល.រ. | បរិយាយ | មធ្យម | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|---|
| ១ | សមាជិកសហគមន៍ចូលចិត្តធ្វើការតែឯង។ | ២.៦៧ | ០.៨២ | មធ្យម |
| ២ | សមាជិកសហគមន៍មានអារម្មណ៍ខ្មាសអៀនក្នុងការបើកចំហបញ្ហាថ្នាក់រៀនរបស់ខ្លួនទៅកាន់អ្នកដទៃ។ | ២.១៧ | ១.១៧ | ខ្សោយ |
| ៣ | សមាជិកសហគមន៍មានអារម្មណ៍ខ្មាសអៀនក្នុងការបង្ហាញការអនុវត្តការបង្រៀនរបស់ខ្លួនទកាន់អ្នកដទៃ។ | ២.៥០ | ០.៨៤ | ខ្សោយ |
| ៤ | សមាជិកសហគមន៍មានអារម្មណ៍ថាការចូលរួមប្រជុំសហគមន៍សិក្សាវិជ្ជាជីវៈមិនបានផ្តល់ជាប្រយោជន៍អ្វីសោះដល់ការបង្រៀនរបស់ខ្លួនសោះ។ | ២.៥០ | ០.៨៤ | ខ្សោយ |

| | | | |
|---|---|---|---|
| សរុប | ២.៤៦ | ០.៩២ | ខ្សោយ |

តារាងខាងលើបង្ហាញថា ទស្សនៈគណៈគ្រប់គ្រងលើកង្វះវប្បធម៌សហការក្នុងសហគមន៍សិក្សាវិជ្ជាជីវៈស្ថិតនៅកម្រិត "ខ្សោយ" (មធ្យម = ២.៤៦ គម្លាតស្តង់ដា = ០.៩២)។ សូចនាករទាំងអស់ទទួលបានលទ្ធផល "ខ្សោយ" លើកលែងតែសូចនាករទី១ "សមាជិកសហគមន៍ចូលចិត្តធ្វើការតែឯង" ដែលទទួលបានលទ្ធផល "មធ្យម"។ លទ្ធផលជារួម បង្ហាញថា ទាំងគណៈគ្រប់គ្រង និងគ្រូបង្រៀនយល់ឃើញស្របគ្នាថា កង្វះវប្បធម៌សហការក្នុងសហគមន៍សិក្សាវិជ្ជាជីវៈ មិនមែនជាបញ្ហាប្រឈមសម្រាប់ការអនុវត្តសហគមន៍សិក្សាវិជ្ជាជីវៈឡើយ។

**ឃ- ឥរិយាបថអសកម្មរបស់សមាជិកសហគមន៍**

**តារាងទី ២៣៖ ទិន្នន័យស្តីពីទស្សនៈគ្រូបង្រៀនលើឥរិយាបថអសកម្មរបស់សមាជិកសហគមន៍**

| ល.រ. | បរិយាយ | មធ្យម | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|---|
| ១ | សមាជិកសហគមន៍គិតថា ខ្លួនបានបំពេញការងារល្អគ្រប់គ្រាន់ ដោយមិនចាំបាច់ទទួលមតិយោបល់ពីអ្នកដទៃ។ | ២.៣៨ | ១.០៦ | ខ្សោយ |
| ២ | សមាជិកសហគមន៍ដែលមានបទពិសោធន៍មិនចែករំលែកការអនុវត្តរបស់ខ្លួនទៅកាន់អ្នកដទៃ។ | ២.៣៥ | ០.៩៥ | ខ្សោយ |
| ៣ | សមាជិកសហគមន៍ជំទាស់យោបល់អ្នកដទៃ ដោយចង់រក្សាមុខមាត់របស់ខ្លួន។ | ២.២៤ | ០.៩០ | ខ្សោយ |
| | **សរុប** | **២.៣២** | **០.៩៧** | **ខ្សោយ** |

តារាងខាងលើបង្ហាញថា ទស្សនៈគ្រូបង្រៀនលើឥរិយាបថអសកម្មរបស់សមាជិកសហគមន៍ ស្ថិតនៅកម្រិត "ខ្សោយ" (មធ្យម = ២.៣២ គម្លាតស្តង់ដា = ០.៩៧)។ សូចនាករទាំងអស់ទទួលបានលទ្ធផល "ខ្សោយ" ដូចគ្នា។ លទ្ធផលនេះបង្ហាញថា សមាជិកសហគមន៍ទទួលយកមតិយោបល់អ្នកដទៃ និងចេះចែករំលែកបទពិសោធន៍គ្នាទៅវិញទៅមក។ ជារួម ឥរិយាបថអសកម្មរបស់សមាជិកសហគមន៍ មិនមែនជាបញ្ហាប្រឈមសម្រាប់ការអនុវត្តសហគមន៍សិក្សាវិជ្ជាជីវៈឡើយ។

**តារាងទី ២៤៖ ទិន្នន័យស្ដីពីទស្សនៈគណៈគ្រប់គ្រងលើឥរិយាបថអសកម្មរបស់សមាជិកសហគមន៍**

| ល.រ. | បរិយាយ | មធ្យម | គម្លាតស្ដង់ដា | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|---|
| ១ | សមាជិកសហគមន៍គិតថា ខ្លួនបានបំពេញការងារល្អគ្រប់គ្រាន់ ដោយមិនចាំបាច់ទទួលមតិយោបល់ពីអ្នកដទៃ។ | ២.៥០ | ០.៨៤ | ខ្សោយ |
| ២ | សមាជិកសហគមន៍ដែលមានបទពិសោធន៍មិនចែករំលែកការអនុវត្តរបស់ខ្លួនទៅកាន់អ្នកដទៃ។ | ២.៥០ | ០.៨៤ | ខ្សោយ |
| ៣ | សមាជិកសហគមន៍ជំទាស់យោបល់អ្នកដទៃ ដោយចង់រក្សាមុខមាត់របស់ខ្លួន។ | ២.៥០ | ០.៨៤ | ខ្សោយ |
| | **សរុប** | **២.៥០** | **០.៨៤** | ខ្សោយ |

តារាងខាងលើបង្ហាញថា ទស្សនៈគណៈគ្រប់គ្រងលើឥរិយាបថអសកម្មរបស់សមាជិកសហគមន៍ស្ថិតនៅកម្រិត “ខ្សោយ” (មធ្យម = ២.៥០ គម្លាតស្ដង់ដា = ០.៨៤)។ សូចនាករទាំងអស់ទទួលបានលទ្ធផល “ខ្សោយ” ដូចគ្នា។ លទ្ធផលនេះបង្ហាញថា ទស្សនៈគណៈគ្រប់គ្រងដូចគ្នាទៅនឹងទស្សនៈគ្រូបង្រៀនដែរ។ ជារួមមក ឥរិយាបថអសកម្មរបស់សមាជិកសហគមន៍ មិនមែនជាបញ្ហាប្រឈមសម្រាប់ការអនុវត្តសហគមន៍សិក្សាវិជ្ជាជីវៈឡើយ។

**ង- កង្វះទំនុកចិត្តលើគ្រូបង្រៀនដទៃ**

**តារាងទី ២៥៖ ទិន្នន័យស្ដីពីទស្សនៈគ្រូបង្រៀនលើកង្វះទំនុកចិត្តលើគ្រូបង្រៀនដទៃ**

| ល.រ. | បរិយាយ | មធ្យម | គម្លាតស្ដង់ដា | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|---|
| ១ | សមាជិកសហគមន៍បញ្ឈប់ការចែករំលែក បន្ទាប់ពីទទួលបានការរិះគន់ពីសំណាក់គ្រូដទៃ។ | ២.៣៣ | ០.៩៩ | ខ្សោយ |
| | **សរុប** | **២.៣៣** | **០.៩៩** | ខ្សោយ |

តារាងខាងលើបង្ហាញថា ទស្សនៈគ្រូបង្រៀនកង្វះទំនុកចិត្តលើគ្រូបង្រៀនដទៃពីសំណាក់សមាជិកសហគមន៍ ស្ថិតនៅកម្រិត “ខ្សោយ” (មធ្យម = ២.៣៣ គម្លាតស្ដង់ដា = ០.៩៩)។ សូចនាករទាំងអស់ទទួលបានលទ្ធផល “ខ្សោយ” ដូចគ្នា។ លទ្ធផលនេះបង្ហាញថា សមាជិកសហគមន៍ចេះចែករំលែក

និងផ្តល់ការរិះគន់បែបស្ថាបនាទៅវិញទៅមក។ ជារួម កង្វះទំនុកចិត្តលើគ្រូបង្រៀនដទៃ មិនមែនជាបញ្ហាប្រឈមសម្រាប់ការអនុវត្តសហគមន៍សិក្សាវិជ្ជាជីវៈឡើយ។

**តារាងទី ២៦៖ ទិន្នន័យស្តីពីទស្សនៈគណៈគ្រប់គ្រងលើកង្វះទំនុកចិត្តលើគ្រូបង្រៀនដទៃ**

| ល.រ. | បរិយាយ | មធ្យម | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|---|
| ១ | សមាជិកសហគមន៍បញ្ឈប់ការចែករំលែក បន្ទាប់ពីទទួលបានការរិះគន់ពីសំណាក់គ្រូដទៃ។ | ២.៣៣ | ០.៥២ | ខ្សោយ |
| **សរុប** | | **២.៣៣** | **០.៥២** | **ខ្សោយ** |

តារាងខាងលើបង្ហាញថា ទស្សនៈគ្រូបង្រៀនកង្វះទំនុកចិត្តលើគ្រូបង្រៀនដទៃពីសំណាក់សមាជិកសហគមន៍ ស្ថិតនៅកម្រិត “ខ្សោយ” (មធ្យម = ២.៣៣ គម្លាតស្តង់ដា = ០.៥២)។ លទ្ធផលនេះបង្ហាញថា ទស្សនៈគណៈគ្រប់គ្រង និងទស្សនៈគ្រូបង្រៀនចំពោះកង្វះទំនុកចិត្តលើគ្រូបង្រៀនដទៃពីសំណាក់សមាជិកសហគមន៍ មានភាពស្របគ្នា។ ជារួម កង្វះទំនុកចិត្តលើគ្រូបង្រៀនដទៃ មិនមែនជាបញ្ហាប្រឈមសម្រាប់ការអនុវត្តសហគមន៍សិក្សាវិជ្ជាជីវៈឡើយ។

**តារាងទី ២៧៖ លទ្ធផលសង្ខេបស្តីពីទស្សនៈគ្រូបង្រៀនលើបញ្ហាប្រឈមក្នុងការអនុវត្តសហគមន៍សិក្សាវិជ្ជាជីវៈ**

| ល.រ. | បរិយាយ | មធ្យម | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|---|
| ១ | បន្ទុកការងារ និង ឧបសគ្គពេលវេលា | **៣.៣៤** | **០.៩៣** | **មធ្យម** |
| ២ | ការយល់ដឹងមិនច្បាស់ពីការអនុវត្តសហគមន៍សិក្សាវិជ្ជាជីវៈ | **៣.៣៤** | **០.៨៩** | **មធ្យម** |
| ៣ | កង្វះវប្បធម៌សហការ | **២.៤៥** | **១.០០** | **ខ្សោយ** |
| ៤ | ឥរិយាបថអសកម្មរបស់សមាជិកសហគមន៍សិក្សាវិជ្ជាជីវៈ | **២.៣២** | **០.៩៧** | **ខ្សោយ** |
| ៥ | កង្វះទំនុកចិត្តលើសមាជិកដទៃ | **២.៣៣** | **០.៩៩** | **ខ្សោយ** |

តារាងខាងលើបានបង្ហាញថា ចំពោះទស្សនៈគ្រូបង្រៀន មានបញ្ហាប្រឈមតិចតួចចំនួន០២ក្នុងការអនុវត្តសហគមន៍សិក្សាវិជ្ជាជីវៈ។ បញ្ហាប្រឈមទី១ គឺ បន្ទុកការងារ និងឧបសគ្គពេលវេលា ដែលស្ថិតក្នុងកម្រិត "មធ្យម" (មធ្យម = ៣.៣៤ គម្លាតស្តង់ដា = ០.៩៣)។ បញ្ហាប្រឈមទី២ គឺ ការយល់ដឹងមិនបានច្បាស់ពីការអនុវត្តសហគមន៍សិក្សាវិជ្ជាជីវៈ ដែលស្ថិតនៅក្នុងកម្រិត "មធ្យម" ផងដែរ (មធ្យម = ៣.៣៤ គម្លាតស្តង់ដា = ០.៨៩)។ រីឯបញ្ហាប្រឈម៣ផ្សេងទៀតស្ថិតក្នុងកម្រិត "ខ្សោយ"។ លទ្ធផលនេះបង្ហាញថា (១) កង្វះវប្បធម៌សហការណ៍ (២) ឥរិយាបថអសកម្មរបស់សមាជិកសហគមន៍សិក្សាវិជ្ជាជីវៈ និង (៣) កង្វះទំនុកចិត្តលើសមាជិកដទៃ មិនមែនជាបញ្ហាប្រឈមក្នុងការអនុវត្តសហគមន៍សិក្សាវិជ្ជាជីវៈនៅកម្រិតមធ្យមសិក្សាក្នុងខេត្តកំពង់ចាមឡើយ។

**តារាងទី ២៨៖ លទ្ធផលសង្ខេបស្តីពីទស្សនៈគណៈគ្រប់គ្រងលើបញ្ហាប្រឈមក្នុងការអនុវត្តសហគមន៍សិក្សាវិជ្ជាជីវៈ**

| ល.រ. | បរិយាយ | មធ្យម | គម្លាត ស្តង់ដា | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|---|
| ១ | បន្ទុកការងារ និង ឧបសគ្គពេលវេលា | **៣.៤៣** | **០.៥៧** | **ល្អ** |
| ២ | ការយល់ដឹងមិនច្បាស់ពីការអនុវត្តសហគមន៍សិក្សាវិជ្ជាជីវៈ | **៣.៣៨** | **០.៨០** | **មធ្យម** |
| ៣ | កង្វះវប្បធម៌សហការ | **២.៤៦** | **០.៩២** | **ខ្សោយ** |
| ៤ | ឥរិយាបថអសកម្មរបស់សមាជិកសហគមន៍សិក្សាវិជ្ជាជីវៈ | **២.៥០** | **០.៨៤** | **ខ្សោយ** |
| ៥ | កង្វះទំនុកចិត្តលើសមាជិកដទៃ | **២.៣៣** | **០.៥២** | **ខ្សោយ** |

តារាងខាងលើបានបង្ហាញពីទស្សនៈគណៈគ្រប់គ្រងលើបញ្ហាប្រឈមក្នុងការអនុវត្តសហគមន៍សិក្សាវិជ្ជាជីវៈនៅកម្រិតមធ្យមសិក្សាក្នុងខេត្តកំពង់ចាម។ ទស្សនៈគណៈគ្រប់គ្រងបង្ហាញថាមានបញ្ហាប្រឈមតិចតួចចំនួន០២ក្នុងការអនុវត្តសហគមន៍សិក្សាវិជ្ជាជីវៈដូចគ្នាទៅនឹងទស្សនៈគ្រូបង្រៀនដែរ។ បញ្ហាប្រឈមទី១ គឺ បន្ទុកការងារ និងឧបសគ្គពេលវេលា។ ចំណុចដែលគួរឱ្យកត់សម្គាល់ចំពោះបញ្ហាប្រឈមទី១ គឺ ទស្សនៈគណៈគ្រប់គ្រងស្ថិតក្នុងកម្រិត "ល្អ" (មធ្យម = ៣.៨៣ គម្លាតស្តង់ដា = ០.៥៧) ដែលខ្ពស់ជាងទស្សនៈគ្រូបង្រៀនបន្តិច។ បញ្ហាប្រឈមទី២ គឺ ការយល់ដឹងមិនបានច្បាស់ពីការ អនុវត្តសហគមន៍សិក្សាវិជ្ជាជីវៈ ដែលស្ថិតក្នុងកម្រិត "មធ្យម" (មធ្យម = ៣.៣៨ គម្លាតស្តង់ដា = ០.៨០)។ រីឯបញ្ហាប្រឈម៣ផ្សេងទៀតស្ថិតក្នុងកម្រិត "ខ្សោយ"។ លទ្ធផលនេះបង្ហាញថា (១) កង្វះវប្បធម៌សហការ (២) ឥរិយាបថអសកម្មរបស់សមាជិកសហគមន៍សិក្សាវិជ្ជាជីវៈ និង (៣) កង្វះទំនុកចិត្តលើសមាជិកដទៃ មិនមែនជាបញ្ហាប្រឈមក្នុងការអនុវត្តសហគមន៍សិក្សាវិជ្ជាជីវៈនៅកម្រិតមធ្យមសិក្សាក្នុងខេត្តកំពង់ចាមឡើយ។

**តារាងទី ២៩៖ តារាងសង្ខេបទិន្នន័យស្តីពីទស្សនៈគ្រូបង្រៀន និងទស្សនៈគណៈគ្រប់គ្រងលើបញ្ហាប្រឈមក្នុងការអនុវត្តសហគមន៍សិក្សាវិជ្ជាជីវៈ**

| | | បន្ទុកការងារ និង ឧបសគ្គពេលវេលា | ការយល់ដឹងមិនច្បាស់ពីសហគមន៍សិក្សាវិជ្ជាជីវៈ | កង្វះវប្បធម៌សហការ | ឥរិយាបថអសកម្មរបស់សមាជិកសហគមន៍ | កង្វះទំនុកចិត្តលើសមាជិកដទៃ |
|---|---|---|---|---|---|---|
| គ្រូបង្រៀន | មធ្យម | ៣.៣៤ | ៣.៣៤ | ២.៤៥ | ២.៣២ | ២.៣៣ |
| | គម្លាតស្តង់ដា | ០.៩៣ | ០.៨៩ | ១.០០ | ០.៩៧ | ០.៩៩ |
| | កម្រិតចង្អុលបង្ហាញ | មធ្យម | មធ្យម | ខ្សោយ | ខ្សោយ | ខ្សោយ |

| | | | | | | |
|---|---|---|---|---|---|---|
| គណៈគ្រប់គ្រង | មធ្យម | ៣.៤៣ | ៣.៣៨ | ២.៤៦ | ២.៥០ | ២.៣៣ |
| | គម្លាតស្តង់ដា | ០.៥៧ | ០.៨០ | ០.៩២ | ០.៨៤ | ០.៥២ |
| | កម្រិតចង្អុលបង្ហាញ | ល្អ | មធ្យម | ខ្សោយ | ខ្សោយ | ខ្សោយ |
| **សរុប** | មធ្យម | **៣.៣៩** | **៣.៣៦** | **២.៤៦** | **២.៤១** | **២.៣៣** |
| | គម្លាតស្តង់ដា | **០.៧៥** | **០.៨៥** | **០.៩៦** | **០.៩១** | **០.៧៦** |
| | កម្រិតចង្អុលបង្ហាញ | **មធ្យម** | **មធ្យម** | **ខ្សោយ** | **ខ្សោយ** | **ខ្សោយ** |

តារាងខាងលើបង្ហាញថា មានបញ្ហាប្រឈមតិចតួចចំនួន០២នៅក្នុងការអនុវត្តសហគមន៍សិក្សាវិជ្ជាជីវៈនៅកម្រិតមធ្យមសិក្សាក្នុងខេត្តកំពង់ចាម។ ទី១ គឺ បន្ទុកការងារ និងឧបសគ្គពេលវេលា ដែលស្ថិតនៅកម្រិតរួម “មធ្យម” (មធ្យម = ៣.៣៩ គម្លាតស្តង់ដា = ០.៧៥) និង ទី២ គឺ ការយល់ដឹងមិនច្បាស់ពីការអនុវត្តសហគមន៍សិក្សាវិជ្ជាជីវៈ ដែលស្ថិតនៅកម្រិតរួម “មធ្យម” ផងដែរ (មធ្យម = ៣.៣៦ គម្លាតស្តង់ដា = ០.៨៥)។ បញ្ហាប្រឈម ៣ ផ្សេងទៀត៖ (១) កង្វះវប្បធម៌សហការ (២) ឥរិយាបថអសកម្មរបស់សមាជិកសហគមន៍ និង (៣) កង្វះទំនុកចិត្តលើសមាជិកដទៃ សុទ្ធតែស្ថិតនៅកម្រិត “ខ្សោយ”។

ជារួម លទ្ធផលបានបង្ហាញថា មានបញ្ហាប្រឈមចំនួន ០២ ដែលកើតមានឡើងក្នុងការអនុវត្តសហគមន៍សិក្សាវិជ្ជាជីវៈនៅកម្រិតមធ្យមសិក្សាក្នុងខេត្តកំពង់ចាម គឺ (១) បន្ទុកការងារ និងឧបសគ្គពេលវេលា និង (២) ការយល់ដឹងមិនច្បាស់ពីការអនុវត្តសហគមន៍សិក្សាវិជ្ជាជីវៈ។

**តារាងទី ៣០៖ តារាងសង្ខេបទិន្នន័យស្តីពីបញ្ហាប្រឈមដោយពិនិត្យមើលតាមសាលានីមួយៗដោយឡែក**

| បញ្ហាប្រឈម | សាលា | មធ្យម | គម្លាត ស្តង់ដា | កម្រិតចង្អុល បង្ហាញ |
|---|---|---|---|---|
| បន្ទុកការងារ និងឧបសគ្គពេលវេលា | វិទ្យាល័យ ហ៊ុន សែន កំពង់ចាម | ៣.៤០ | ១.00 | មធ្យម |
| | វិទ្យាល័យ ហ៊ុន សែន ពាមជីកង | ៣.៣៣ | 0.៩០ | មធ្យម |
| ការយល់ដឹងមិនច្បាស់ពី សហគមន៍សិក្សាវិជ្ជាជីវៈ | វិទ្យាល័យ ហ៊ុន សែន កំពង់ចាម | ៣.៥៨ | 0.៨៤ | ល្អ |
| | វិទ្យាល័យ ហ៊ុន សែន ពាមជីកង | ៣.២៣ | 0.៩០ | មធ្យម |
| កង្វះវប្បធម៌សហការ | វិទ្យាល័យ ហ៊ុន សែន កំពង់ចាម | ២.៤៣ | 0.៩៨ | ខ្សោយ |
| | វិទ្យាល័យ ហ៊ុន សែន ពាមជីកង | ២.៤៥ | ១.00 | ខ្សោយ |
| ឥរិយាបថអសកម្មរបស់ សមាជិកសហគមន៍ | វិទ្យាល័យ ហ៊ុន សែន កំពង់ចាម | ២.៣៧ | 0.៨៩ | ខ្សោយ |
| | វិទ្យាល័យ ហ៊ុន សែន ពាមជីកង | ២.៣០ | ១.00 | ខ្សោយ |
| កង្វះទំនុកចិត្តលើ សមាជិកដទៃ | វិទ្យាល័យ ហ៊ុន សែន កំពង់ចាម | ២.៣៥ | 0.៩៣ | ខ្សោយ |
| | វិទ្យាល័យ ហ៊ុន សែន ពាមជីកង | ២.៣៣ | ១.00 | ខ្សោយ |

តារាងខាងលើបង្ហាញថា វិទ្យាល័យទាំងពីរមានបញ្ហាប្រឈមក្នុងការអនុវត្តសហគមន៍សិក្សាវិជ្ជាជីវៈចំនួន ២ដូចគ្នា។ ហើយចំពោះបញ្ហាប្រឈមទី១ “បន្ទុកការងារ និងឧបសគ្គពេលវេលា” ស្ថិតនៅកម្រិត “មធ្យម” ដូចគ្នា។ ចំពោះបញ្ហាប្រឈមទី២ “ការយល់ដឹងមិនច្បាស់ពីសហគមន៍សិក្សាវិជ្ជាជីវៈ” ហាក់ជាបញ្ហាប្រឈមខ្លាំងនៅវិទ្យាល័យ ហ៊ុន សែន កំពង់ចាម ដោយតម្លៃមធ្យម ៣.៥៨ ដែលស្ថិតនៅកម្រិតចង្អុលបង្ហាញ “ល្អ”។ លទ្ធផលនេះបង្ហាញឱ្យឃើញថា រវាងសាលាទាំងពីរ បញ្ហាប្រឈមនៅក្នុងការអនុវត្តសហគមន៍សិក្សាវិជ្ជាជីវៈមានលក្ខណៈប្រហាក់ប្រហែលគ្នា។

## ៤.២- ការពិភាក្សា

### ៤.២.១- ការពិភាក្សាលើការអនុវត្តសហគមន៍សិក្សាវិជ្ជាជីវៈនៅកម្រិតមធ្យមសិក្សាក្នុងខេត្តកំពង់ចាម

#### ក- ការសិក្សាជាក្រុម

គោលដៅនៃសហគមន៍សិក្សាវិជ្ជាជីវៈ គឺការបង្កើតឱ្យមានវប្បធម៌សហការរវាងគ្រូបង្រៀន និងភាគីពាក់ព័ន្ធនានា។ ការសិក្សាជាក្រុមជាយន្តការមួយដែលនឹងជួយបង្កើតឱ្យមានឧត្តមានុវត្តន៍ក្នុងវិជ្ជាជីវៈជាគ្រូបង្រៀន និងអ្នកអប់រំ។ ទស្សនៈគ្រូបង្រៀនបង្ហាញថា ការសិក្សាជាក្រុមរបស់សមាជិកសហគមន៍សិក្សាវិជ្ជាជីវៈស្ថិតនៅកម្រិត "ល្អ" ដែលតម្លៃមធ្យមទទួលបាន ៣.៩១ និងគម្លាតស្តង់ដា ០.៧៨។ ទស្សនៈគណៈគ្រប់គ្រងមានភាពស្រដៀងគ្នានេះដែរ ហើយថែមទាំងមានកម្រិតខ្ពស់ជាង ដោយស្ថិតនៅកម្រិតចង្អុលបង្ហាញ "ល្អណាស់" ដែលតម្លៃមធ្យម គឺ ៤.៤៤ និងគម្លាតស្តង់ដា ០.៥៣។ លទ្ធផលជារួមស្ថិតនៅក្នុងកម្រិត "ល្អ" (មធ្យម = ៤.១៨ គម្លាតស្តង់ដា = ០.៦៦)។

លទ្ធផលនេះបានបង្ហាញថា សមាជិកសហគមន៍បានធ្វើការសហការគ្នាបានល្អ ដែលមានការប្រជុំសហគមន៍ជារៀងរាល់សប្តាហ៍ និងមានការចងក្រងរក្សាទុកខ្លឹមសារ និងភស្តុតាងនៃការអនុវត្តក្នុងកម្រងស្នាដៃវិជ្ជាជីវៈរបស់ខ្លួន។ Donegan et al. (2000); Pollara (2012) និង Gutierez & Kim (2018) បានធ្វើការសិក្សាពីការសិក្សាជាក្រុម និងបានបញ្ជាក់ថា ការសិក្សាជាក្រុមនាំឱ្យមានការរីកចម្រើនដល់ការអភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈ តាមរយៈការបង្កើតបានទំនុកចិត្ត ការចែករំលែកបទពិសោធន៍និងចំណេះដឹង ដើម្បីឆ្លើយតបបានល្អចំពោះតម្រូវការសិក្សារបស់សិស្ស។ ជាមួយគ្នានេះដែរ Rhodes (2017) ក៏បានសិក្សាផងដែរអំពីការសិក្សាជាក្រុម និងបានលើកឡើងថា ការសហការក្នុងក្រុមនឹងជួយដល់គ្រូបង្រៀនបានច្រើន ជាពិសេសគ្រូបង្រៀនដែលទើបនឹងចេញថ្មី។

សរុបមក ទស្សនៈគ្រូបង្រៀន និងទស្សនៈគណៈគ្រប់គ្រងលើការសិក្សាក្រុមបានបង្ហាញថា សមាជិកសហគមន៍មានការយកចិត្តទុកដាក់ក្នុងការចូលរួមសហការអនុវត្តការងារ និងទទួលបានលទ្ធផលល្អ។

## ខ- ការសង្កេតថ្នាក់ និងប្រឹក្សា

ដើម្បីឆ្លុះបញ្ចាំងពីការអនុវត្តការបង្រៀនរបស់ខ្លួន គ្រូបង្រៀនទាមទារឱ្យមានការដកស្រង់បទពិសោធន៍នៃការប្រើប្រាស់វិធីសាស្ត្រពីអ្នកដទៃតាមរយៈការសង្កេតថ្នាក់ និងប្រឹក្សាយោបល់ជាមួយអ្នកដែលមានបទពិសោធន៍ច្រើនជាងខ្លួន។ ការសង្កេតថ្នាក់ និងការធ្វើការប្រឹក្សាយោបល់រិះរកវិធីសាស្ត្រល្អៗសម្រាប់យកមកអនុវត្តក្នុងការបង្រៀនឱ្យស្របតាមស្ថានភាពជាក់ស្តែងនៃថ្នាក់រៀនរបស់ខ្លួននឹងអាចជួយបង្កើនប្រសិទ្ធភាពការបង្រៀន ដើម្បីលើកកម្ពស់លទ្ធផលសិក្សារបស់សិស្ស។ ទស្សនៈគ្រូបង្រៀន និងទស្សនៈគណៈគ្រប់គ្រងបង្ហាញការយល់ឃើញដូចគ្នាចំពោះការអនុវត្តការសង្កេតថ្នាក់ និងប្រឹក្សាយោបល់នៅសហគមន៍សិក្សាវិជ្ជាជីវៈនៅកម្រិតមធ្យមសិក្សាក្នុងខេត្តកំពង់ចាម។ ការឆ្លើយតបរបស់គ្រូបង្រៀន និងគណៈគ្រប់គ្រងស្ថិតនៅកម្រិត “ល្អ” ដូចគ្នា។ ទស្សនៈគ្រូបង្រៀនទទួលបានតម្លៃមធ្យម ៣.៩៥ គម្លាតស្តង់ដា ០.៦៩ និងទស្សនៈគណៈគ្រប់គ្រងទទួលបានតម្លៃមធ្យម ៤.១៦ គម្លាតស្តង់ដា ០.៧៨។ លទ្ធផលជារួមស្ថិតនៅកម្រិត “ល្អ” (មធ្យម = ៤.០៦ គម្លាតស្តង់ដា = ០.៧៤)។

លទ្ធផលនេះបង្ហាញថា ដំណើរការសង្កេតថ្នាក់ និងការផ្តល់ប្រឹក្សាយោបល់ប្រព្រឹត្តទៅបានល្អនៅក្នុងសហគមន៍សិក្សាវិជ្ជាជីវៈ។ ប្រធានក្រុមសហគមន៍សហការជិតស្និទ្ធជាមួយនាយករងទទួលបន្ទុកបច្ចេកទេសក្នុងការគាំទ្រដល់ការអនុវត្តការងាររបស់សហគមន៍ និងការអភិវឌ្ឍវិជ្ជាជីវៈរបស់សមាជិកសហគមន៍។ សមាជិកសហគមន៍ក៏បានរៀបចំការសង្កេតថ្នាក់ដោយកត់ត្រានូវព័ត៌មានល្អៗសសម្រាប់ការឆ្លុះបញ្ចាំងពីការអនុវត្តការងាររបស់ខ្លួន។ លើសពីនេះ ការប្រឹក្សាជាមួយអ្នកមានសមត្ថភាព និងបទពិសោធន៍ខ្ពស់ក៏ទទួលបានការឆ្លើយតបក្នុងកម្រិតល្អផងដែរ។ ក្នុងការសិក្សារបស់ខ្លួន Vincent (2018) បានលើកឡើងថា ការសង្កេតថ្នាក់ផ្តល់អត្ថប្រយោជន៍ច្រើនដល់អ្នកសង្កេតផង និងអ្នកដែលត្រូវគេសង្កេត

ផង។ វាជាសកម្មភាពមួយដែលនឹងផ្តល់ឱ្យនូវព័ត៌មានច្បាស់លាស់សម្រាប់ការឆ្លុះបញ្ចាំងនៅពេលសង្កេតក្រោយៗ។ Carroll & O'Loughlin (2014) រកឃើញស្រដៀងគ្នានឹង Vincent ដែរ។ គាត់បានលើកឡើងថា ការសង្កេតថ្នាក់ជួយបង្កើតបានទំនាក់ទំនងល្អរវាងគ្រូនិងគ្រូ ដែលធ្វើឱ្យមានការប្រឹក្សាយោបល់ និងឈានដល់ការរីកចម្រើនការរៀនសូត្រ។

ជារួម ការសង្កេតថ្នាក់ និងប្រឹក្សារបស់សហគមន៍សិក្សាវិជ្ជាជីវៈនៅកម្រិតមធ្យមសិក្សាក្នុងខេត្តកំពង់ចាមដំណើរការបានល្អ ដោយសារមានការចូលរួមសហការពីគណៈគ្រប់គ្រង និងប្រធានក្រុមសហ-គមន៍ និងមានការប្រឹក្សាយោបល់គ្នា។

**គ- ភារកិច្ចរបស់សហគមន៍សិក្សាវិជ្ជាជីវៈ**

ភារកិច្ចរបស់សហគមន៍សិក្សាវិជ្ជាជីវៈតម្រូវឱ្យសមាជិកសហគមន៍ចូលរួមអនុវត្តយ៉ាងសកម្មទៅលើចំណុចនានាដែលមានជាអាទិ៍ ការសិក្សាជាក្រុម ការសិក្សាស្រាវជ្រាវមេរៀន ការសង្កេតថ្នាក់រៀន ការប្រឹក្សាចែករំលែកបទពិសោធន៍ និងការឆ្លុះបញ្ចាំងនិងវាយតម្លៃលទ្ធផលសិក្សារបស់សិស្សជាដើម។ លទ្ធផលសិក្សាបានបង្ហាញថា ការអនុវត្តភារកិច្ចរបស់សហគមន៍សិក្សាវិជ្ជាជីវៈនៅកម្រិតមធ្យមសិក្សាក្នុងខេត្តកំពង់ចាមស្ថិតនៅកម្រិត "ល្អ" (មធ្យម = ៣.៩៩ គម្លាតស្តង់ដា = ០.៦៤)។ លទ្ធផលនេះបង្ហាញថា សមាជិកសហគមន៍បានចូលរួមអនុវត្តភារកិច្ចរបស់ខ្លួនបានល្អ។

ការចូលរួមបំពេញភារកិច្ចបានល្អក្នុងសហគមន៍សិក្សាវិជ្ជាជីវៈនឹងមានផលជះវិជ្ជមានចំពោះអង្គ-ភាពទាំងមូល។ ការចូលរួមបំពេញភារកិច្ចសហគមន៍សិក្សាវិជ្ជាជីវៈជួយដល់ជីវិតការងារគ្រូបង្រៀន។ វានឹងជួយបង្កើតឱ្យមានបរិស្ថានការងារដែលមានការគាំទ្រ និងបង្កើតបានគន្លងអាជីពដែលទាក់ទាញនិងរក្សាទុកគ្រូបង្រៀន។ លើសពីនេះ វាក៏ជួយដល់ការរៀនសូត្ររបស់គ្រូបង្រៀនផងដែរ។ ការចូលរួមបំពេញភារកិច្ចសហគមន៍សិក្សាវិជ្ជាជីវៈនឹងធ្វើឱ្យការអនុវត្តការងារជាប្រចាំរបស់គ្រូមានការរីកចម្រើនជាប្រចាំ។ ជាពិសេសទៅទៀតនោះ ការចូលរួមបំពេញភារកិច្ចសហគមន៍សិក្សាវិជ្ជាជីវៈបង្កើតបាននូវវប្បធម៌សាលារៀនដែលមានឥទ្ធិពលដល់ការកំណត់ទុកមុន និងការផ្លាស់ប្តូរនៅសាលារៀន (Toole & Louis, 2002)។

### ឃ- អ្នកពាក់ព័ន្ធសំខាន់ៗក្នុងការគាំទ្រសហគមន៍សិក្សាវិជ្ជាជីវៈ

ការចូលរួមគាំទ្រពីសំណាក់អ្នកពាក់ព័ន្ធសំខាន់ៗជាការចាំបាច់សម្រាប់ដំណើរការទ្រទ្រង់ដល់ការអនុវត្តសហគមន៍សិក្សាវិជ្ជាជីវៈមួយ។ អង្គភាពថ្នាក់ក្រសួង មន្ទីរអប់រំ យុវជន និងកីឡាខេត្ត ការិយាល័យអប់រំ យុវជន និងកីឡាស្រុក គ្រឹះស្ថានបណ្តុះបណ្តាលគ្រូ នាយកសាលារៀន និងគ្រូបង្រៀន សុទ្ធតែជាចំណែកជួយឱ្យការអនុវត្តសហគមន៍សិក្សាវិជ្ជាជីវៈដំណើរការទៅប្រកបដោយប្រសិទ្ធភាព និងនិរន្តរភាព។ ការឆ្លើយតបរបស់គ្រូបង្រៀន និងគណៈគ្រប់គ្រងទៅកាន់កម្រងសំណួរបង្ហាញលទ្ធផលក្នុងកម្រិត "ល្អ"។ ចំពោះទស្សនៈគ្រូបង្រៀន តម្លៃមធ្យម គឺ ៣.៨៨ និងគម្លាតស្តង់ដា ០.៧៧។ ចំពោះទស្សនៈគណៈគ្រប់គ្រង លទ្ធផលទទួលបានតម្លៃមធ្យម ៣.៨០ និងគម្លាតស្តង់ដា ០.៥៥។ លទ្ធផលជារួមស្ថិតនៅក្នុងកម្រិត "ល្អ" (មធ្យម = ៣.៨៤ គម្លាតស្តង់ដា = ០.៦៦)។

តាមរយៈលទ្ធផលនេះ ឃើញថា អង្គភាពពាក់ព័ន្ធទាំងអស់ ជាពិសេសនាយកសាលាផ្ទាល់បានចូលរួមបង្កើតឱ្យមានសហគមន៍សិក្សាវិជ្ជាជីវៈ និងជួយជ្រោមជ្រែងលើសកម្មភាពនានារបស់សហគមន៍ដែលបានបង្កើត។ នៅក្នុងការសិក្សារបស់ Saad (2009) បានរកឃើញថា ការគាំទ្រពីសំណាក់សាលារៀនផ្ទាល់ជារឿងចាំបាច់ ដែលកើតចេញពីភាពជាអ្នកដឹកនាំរបស់នាយកសាលានោះ។ Gray & Summers (2015) ក៏បានលើកឡើងផងដែរថា ការបង្កើតឱ្យមានរចនាសម្ព័ន្ធសាលារៀនច្បាស់លាស់ ការកសាងបានទំនុកចិត្តគ្រូបង្រៀនលើគណៈគ្រប់គ្រង និងលើគ្រូបង្រៀនដទៃនាំឱ្យសហគមន៍សិក្សាវិជ្ជាជីវៈមានភាពរីកចម្រើន។ លើសពីនេះ ការគាំទ្រដល់ការអនុវត្តសហគមន៍សិក្សាវិជ្ជាជីវៈត្រូវការចាំបាច់ការគ្រប់គ្រង និងដឹកនាំសាលារៀនប្រកបដោយភាពប៉ិនប្រសប់ (Hairon & Dimmock, 2012)។ នាយកសាលាដែលបានចូលរួមសហការយ៉ាងជិតស្និទ្ធជាមួយនឹងសហគមន៍សិក្សាវិជ្ជាជីវៈកសាងបាននូវទំនុកចិត្ត ស្មារតីក្រុម និងភាពជាអ្នកដឹកនាំ ដែលបង្កើតបាននូវទំនាក់ទំនងល្អ និងរចនាសម្ព័ន្ធក្រុមរឹងមាំ (Hefner, 2011; Somprach et al., 2017; Held, 2017)។

ជារួម អ្នកស្រាវជ្រាវអាចសរុបសេចក្តីបានថា ការអនុវត្តសហគមន៍សិក្សាវិជ្ជាជីវៈនៅកម្រិតមធ្យម សិក្សាក្នុងខេត្តកំពង់ចាមទទួលបានការគាំទ្រល្អពីសំណាក់អ្នកពាក់ព័ន្ធ ជាពិសេសពីសំណាក់គណៈគ្រប់គ្រងសាលាតែម្តង។

**ង- ប្រព័ន្ធលើកទឹកចិត្តដល់សហគមន៍សិក្សាវិជ្ជាជីវៈ**

បន្ថែមពីលើការសហការពីសំណាក់អ្នកពាក់ព័ន្ធនានា ការអនុវត្តសហគមន៍សិក្សាវិជ្ជាជីវៈក៏ត្រូវការប្រព័ន្ធលើកទឹកចិត្តផងដែរ ដើម្បីជំរុញការអនុវត្តឱ្យកាន់តែប្រសើរឡើង។ ទស្សនៈគ្រូបង្រៀន និងទស្សនៈគណៈគ្រប់គ្រងស្ថិតនៅកម្រិត “ល្អ” ដូចគ្នា។ ទស្សនៈគ្រូបង្រៀនទទួលបានតម្លៃមធ្យម ៣.៨១ និងគម្លាតស្តង់ដា ០.៧៧ រីឯទស្សនៈគណៈគ្រប់គ្រងទទួលបានតម្លៃមធ្យម ៣.៨៣ គម្លាតស្តង់ដា ០.៦៤។ លទ្ធផលជារួមស្ថិតនៅក្នុងកម្រិត “ល្អ” (មធ្យម = ៣.៨២ គម្លាតស្តង់ដា = ០.៧១)។

លទ្ធផលនេះបង្ហាញថា សមាជិកសហគន៍សិក្សាវិជ្ជាជីវៈទទួលបានការលើកទឹកចិត្តគ្រប់គ្រាន់តាមរយៈការទទួលបានឱកាសចូលរួមក្នុងកម្មវិធីនានា និងទទួលបានឱកាសអភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈ។ លើសពីនេះ សាលាក៏បានគាំទ្រផ្នែកសម្ភារៈ និងស្មារតី តាមរយៈការផ្តល់ទីកន្លែងសមរម្យសម្រាប់ការធ្វើកិច្ចតែងការបង្រៀននិងស្វ័យសិក្សា។ល។ ការសិក្សារបស់ Beemt et al. (2018) បានរកឃើញថា ក្នុងការលើកទឹកចិត្ត គេអាចប្រើប្រាស់ការលើកទឹកចិត្តដោយការចូលរួមក្នុងកម្មវិធីអភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈ ការផ្តល់ពេលវេលាគ្រប់គ្រាន់ ការផ្តល់ជំនួយបច្ចេកវិទ្យា ឬការផ្តល់ជារង្វាន់ជាដើម។ ក្រៅអំពីនេះ ការលើកទឹកចិត្តក៏អាចធ្វើបានតាមរយៈការបង្កឱ្យមានភាពពេញចិត្ត ការចែករំលែក និងការយល់គ្នាទៅវិញទៅមកក្នុងសហគមន៍ផងដែរ។

ជារួម ទស្សនៈគ្រូបង្រៀនលើប្រព័ន្ធលើកទឹកចិត្តដល់សហគមន៍សិក្សាវិជ្ជាជីវៈបង្ហាញការយល់ស្របក្នុងកម្រិតល្អ។ នេះបញ្ជាក់ឱ្យឃើញពីការលើកទឹកចិត្តទាំងផ្នែកសម្ភារៈ និងស្មារតីនៅក្នុងសហគមន៍សិក្សាវិជ្ជាជីវៈ។

### ៤.២.២- ការពិភាក្សាពីបញ្ហាប្រឈមក្នុងការអនុវត្តសហគមន៍សិក្សាវិជ្ជាជីវៈនៅកម្រិតមធ្យមសិក្សាក្នុងខេត្តកំពង់ចាម

ផ្អែកលើទស្សនៈគ្រូបង្រៀន ដែលដូចគ្នាទៅនឹងទស្សនៈគណៈគ្រប់គ្រងដែរ បញ្ហាប្រឈមចំនួន២ ត្រូវបានរកឃើញក្នុងការអនុវត្តសហគមន៍សិក្សាវិជ្ជាជីវៈនៅកម្រិតមធ្យមសិក្សាក្នុងខេត្តកំពង់ចាម។ បញ្ហាទី១ គឺ បន្ទុកការងារ និងឧបសគ្គពេលវេលា ដែលជាបញ្ហាប្រឈម។ យោងតាមទស្សនៈគ្រូបង្រៀន បន្ទុកការងារ និងឧបសគ្គពេលវេលា ជាបញ្ហាប្រឈមតិចតួច (មធ្យម = ៣.៣៤ គម្លាតស្តង់ដា = ០.៩៣) រីឯទស្សនៈគណៈគ្រប់គ្រងយល់ស្រុបខ្ពស់ជាងទស្សនៈគ្រូបង្រៀន (មធ្យម = ៣.៤៣ គម្លាត ស្តង់ដា = ០.៥៧)។ លទ្ធផលជារួមស្ថិតនៅក្នុងកម្រិត “មធ្យម” (មធ្យម = ៣.៣៩ គម្លាតស្តង់ដា = ០.៧៥)។ ការរកឃើញនេះស្រដៀងគ្នានឹងការរកឃើញរបស់ Hairon & Tan (2017) ; Tayag (2020); និង Chua et al. (2020) ដែរ។ បន្ទុកការងារ និងកង្វះខាតពេលវេលាជាកត្តាដែលជះឥទ្ធិពលដល់ការប្រជុំសហគមន៍សិក្សាវិជ្ជាជីវៈ ក៏ដូចជាបំពេញការងារសហគមន៍ផ្សេងៗទៀត ដែលមានជាអាទិ៍ការសិក្សាជាក្រុម ការសង្កេតថ្នាក់ និងប្រឹក្សាជាដើម។ Hairon & Tan (2017) បានរកឃើញថា តម្រូវការការងារដែលដាក់ចេញដោយអ្នកពាក់ព័ន្ធនានា ដូចជា ថ្នាក់លើ ឬអាណាព្យាបាលជាដើម ជាកត្តារាំងស្ទះដល់ការប្តេជ្ញាចិត្តអនុវត្តសហគមន៍សិក្សាវិជ្ជាជីវៈឱ្យបានល្អ។ Tayag (2020) និង Chua et al. (2020) បានលើកឡើងថា ដោយសារតែបន្ទុកការងារច្រើន និងមិនមានពេលគ្រប់គ្រាន់ គ្រូបង្រៀនមិនបានចូលរួមក្នុងការប្រជុំសហគមន៍វិជ្ជាជីវៈ។ ពួកគាត់ត្រូវចំណាយពេលវេលាបំពេញការងាររដ្ឋបាលគ្រូ និងបំពេញការងារផ្សេងៗសម្រាប់ការបង្រៀនរបស់ខ្លួន។

បញ្ហាប្រឈមទី២ គឺ ការយល់ដឹងមិនបានច្បាស់ពីសហគមន៍សិក្សាវិជ្ជាជីវៈ។ ទស្សនៈគ្រូបង្រៀនចំពោះបញ្ហានេះមានតម្លៃមធ្យម ៣.៣៤ គម្លាតស្តង់ដា ០.៨៩។ ទស្សនៈគណៈគ្រប់គ្រងមានតម្លៃមធ្យម ៣.៣៨ គម្លាតស្តង់ដា ០.៨០។ លទ្ធផលជារួមស្ថិតនៅក្នុងកម្រិត “មធ្យម” (មធ្យម = ៣.៣៦ គម្លាតស្តង់ដា = ០.៨៥)។ យោងតាមទស្សនៈគ្រូបង្រៀន និងទស្សនៈគណៈគ្រប់គ្រង បញ្ហានេះជាបញ្ហា

ប្រឈមតិចតួច តែទោះជាយ៉ាងណា វាជាចំណុចដែលត្រូវបំពេញបន្ថែម ដើម្បីឱ្យការអនុវត្តសហគមន៍សិក្សាវិជ្ជាជីវៈកាន់តែប្រសើរឡើង។ តាមការសិក្សាស្រាវជ្រាវបង្ហាញឱ្យឃើញថា ការយល់ដឹងមិនច្បាស់ពីការអនុវត្តសហគមន៍សិក្សាវិជ្ជាជីវៈបណ្តាលមកពីកត្តាកង្វះខាតឯកសារណែនាំពិស្តារ និងបទពិសោធន៍ថ្មីថ្មោងក្នុងការអនុវត្ត។ ការសិក្សារបស់ Hairon & Tan (2017) បានរកឃើញពីកង្វះឯកសារសម្បូរបែបស្តីពីសហគមន៍សិក្សាវិជ្ជាជីវៈ និងការអនុវត្តសហគមន៍សិក្សាវិជ្ជាជីវៈនៅក្នុងបរិបទតំបន់ដែលមិនមែនជាអឺរ៉ុប ឬអាម៉េរិក។ កង្វះខាតឯកសារសម្បូរបែបនេះដោយសារតែនៅបរិបទអាស៊ី ក៏ដូចជាកម្ពុជា ការបង្កើត និងអនុវត្តសហគន៏វិជ្ជាជីវៈទើបតែកើតឡើងក្រោយតំបន់ទាំងពីរខាងលើ។ កង្វះខាតនេះនាំទៅដល់ការយល់ដឹងមិនបានច្បាស់លាស់ រួមមានការយល់ឃើញខុសចំពោះការប្រជុំសហគមន៍សិក្សាវិជ្ជាជីវៈជាដើម។ ការសិក្សារបស់ Chua et al. (2020) បានរកឃើញថា នាយកសាលាមួយចំនួនយល់ឃើញថា ការប្រជុំនេះជាការលើកយកតែមាតិកានៃកម្មវិធីសិក្សា និងការកំណត់ពីមាតិកាដែលត្រូវបង្រៀនប៉ុណ្ណោះ ហើយនាយកសាលាខ្លះគិតថា ការប្រជុំសហគមន៍សិក្សាវិជ្ជាជីវៈជាការធ្វើសកម្មភាពក្នុងថ្នាក់រៀនដូចជា Gallery Walk ទៅវិញ។

ជារួម បញ្ហាប្រឈមទាំងពីរខាងលើជាបញ្ហាប្រឈមតិចតួច តែជាបញ្ហាដែលត្រូវដោះស្រាយដោយខានមិនបាន។ ការឆ្លើយតបទៅនឹងបញ្ហាទាំងនេះនឹងធ្វើឱ្យការអនុវត្តសហគមន៍សិក្សាវិជ្ជាជីវៈមានភាពរីកចម្រើនកាន់តែប្រសើរឡើង ដែលនឹងចូលរួមចំណែកក្នុងការបង្កើនប្រសិទ្ធភាពការរៀន និងបង្រៀន។

# ជំពូក៥

# សេចក្តីសន្និដ្ឋាន និងសំណូមពរ

## ៥.១- សេចក្តីសន្និដ្ឋាន

តាមរយៈការសិក្សាស្រាវជ្រាវ លទ្ធផលដែលទទួលបានឆ្លើយតបទៅនឹងសំណួរស្រាវជ្រាវទាំងពីរ៖ (១) តើគ្រូបង្រៀនមានទស្សនៈបែបណាលើការអនុវត្តសហគមន៍សិក្សាវិជ្ជាជីវៈរបស់គ្រូបង្រៀននៅកម្រិតមធ្យមសិក្សាក្នុងខេត្តកំពង់ចាម? និង (២) តើមានបញ្ហាប្រឈមអ្វីខ្លះចំពោះការអនុវត្តសហគមន៍សិក្សាវិជ្ជាជីវៈរបស់គ្រូបង្រៀននៅកម្រិតមធ្យមសិក្សាក្នុងខេត្តកំពង់ចាម?

លទ្ធផលស្រាវជ្រាវបានបង្ហាញថា ការអនុវត្តសហគមន៍សិក្សាវិជ្ជាជីវៈនៅកម្រិតមធ្យមសិក្សាក្នុងខេត្តកំពង់ចាមស្ថិតក្នុងកម្រិត "ល្អ" ដោយយោងទៅលើទស្សនៈគ្រូបង្រៀន ដែលធ្វើការផ្ទៀងផ្ទាត់គ្នាជាមួយទស្សនៈគណៈគ្រប់គ្រង។ តាមទស្សនៈគ្រូបង្រៀន តម្លៃមធ្យមដែលទទួលបាន គឺ ៣.៩០ និងគម្លាតស្តង់ដា ០.៧៣។ ទស្សនៈគណៈគ្រប់គ្រងមានតម្លៃមធ្យម ៤.០៥ និងគម្លាតស្តង់ដា ០.៦២។ លទ្ធផលជារួមស្ថិតនៅក្នុងកម្រិត "ល្អ" (មធ្យម = ៣.៩៨ គម្លាតសស្តង់ដា = ០.៦៨)។ តាមរយៈលទ្ធផលនេះ អ្នកស្រាវជ្រាវអាចសន្និដ្ឋានបានថា ការសិក្សាជាក្រុម ការសង្កេតថ្នាក់និងប្រឹក្សា ការចូលរួមបំពេញភារកិច្ចរបស់សមាជិកសហគមន៍ និងការគាំទ្រនិងលើកទឹកចិត្តដល់សហគមន៍សិក្សាវិជ្ជាជីវៈត្រូវបានយកចិត្តទុកដាក់។ តាមរយៈការវិភាគទិន្នន័យ អ្នកស្រាវជ្រាវសង្កេតឃើញថា ការចូលរួមបំពេញភារកិច្ចរបស់សសមាជិកសហគមន៍សិក្សាវិជ្ជាជីវៈមានតម្លៃមធ្យមខ្ពស់ជាងគេ។ វាបានបញ្ជាក់ឱ្យឃើញថា សមាជិកសហគមន៍សិក្សាវិជ្ជាជីវៈមានការប្តេជ្ញាចិត្តក្នុងការបំពេញការងាររបស់ខ្លួន។ ជាមួយគ្នានេះផងដែរ ចំពោះការចូលរួមពីសំណាក់អ្នកពាក់ព័ន្ធក៏ទទួលបានតម្លៃមធ្យមខ្ពស់ផងដែរ។ តាមរយៈទិន្នន័យនេះ អ្នកស្រាវជ្រាវអាចសន្និដ្ឋានបានថា សហគមន៍សិក្សាវិជ្ជាជីវៈទទួលបានការគាំទ្រពីសំណាក់ថ្នាក់លើចំពោះការអនុវត្តការងាររបស់ខ្លួន។ ទិន្នន័យក៏បានបង្ហាញផងដែរពីការចូលរួមគាំទ្រយ៉ាងល្អពីសំណាក់គណៈគ្រប់គ្រងសាលា។

ទន្ទឹមនឹងលទ្ធផលស្តីពីការអនុវត្តសហគមន៍សិក្សាវិជ្ជាជីវៈនេះ អ្នកស្រាវជ្រាវក៏បានរកឃើញនូវបញ្ហាប្រឈមចំនួន ០២ ផងដែរ ដែលកើតមានក្នុងការអនុវត្តសហគមន៍សិក្សាវិជ្ជាជីវៈនៅទីនេះ។ បញ្ហាទី១ គឺ បន្ទុកការងារ និងឧបសគ្គពេលវេលា ដែលស្ថិតក្នុងកម្រិត “មធ្យម” (មធ្យម = ៣.៣៤ គម្លាតស្តង់ដា = ០.៩៣) យោងតាមទស្សនៈគ្រូបង្រៀន និងស្ថិតក្នុងកម្រិត “ល្អ” (មធ្យម = ៣.៤៣ គម្លាតស្តង់ដា = ០.៥៧) យោងតាមទស្សនៈគណៈគ្រប់គ្រង។ លទ្ធផលជារួមស្ថិតនៅក្នុងកម្រិត “មធ្យម” (មធ្យម = ៣.៣៩ គម្លាតស្តង់ដា = ០.៧៥)។ លទ្ធផលនេះបានបង្ហាញថា បន្ទុកការងារ និងឧបសគ្គពេលវេលា ជាបញ្ហាប្រឈមតិចតួច តែទោះជាយ៉ាងណាវាជាចំណុចដែលត្រូវដោះស្រាយជាចាំបាច់។ លទ្ធផលនេះបង្ហាញថា គ្រូបង្រៀនមានកិច្ចការច្រើនដែលត្រូវបំពេញ នាំឱ្យជះឥទ្ធិពលដល់ការអនុវត្តសហគមន៍សិក្សាវិជ្ជាជីវៈមួយឱ្យបានប្រសើរ។ បញ្ហាប្រឈមទី២ ដែលបានរកឃើញ គឺ ការយល់ដឹងមិនបានច្បាស់ពីការអនុវត្តសហគមន៍សិក្សាវិជ្ជាជីវៈ។ ទិន្នន័យដែលបានវិភាគបង្ហាញថា ទស្សនៈគ្រូបង្រៀន (មធ្យម = ៣.៣៤ គម្លាតស្តង់ដា = ០.៨៩) និង ទស្សនៈគណៈគ្រប់គ្រង (មធ្យម = ៣.៣៨ គម្លាតស្តង់ដា = ០.៨០) ស្ថិតនៅកម្រិត “យល់ស្របតិចតួច” ដូចគ្នា។ លទ្ធផលជារួមស្ថិតនៅក្នុងកម្រិត “មធ្យម” (មធ្យម = ៣.៣៦ គម្លាតស្តង់ដា = ០.៨៥)។ លទ្ធផលនេះបង្ហាញថា ការយល់ដឹងមិនបានច្បាស់ពីការអនុវត្តសហគមន៍សិក្សាវិជ្ជាជីវៈ ជាបញ្ហាប្រឈមតិចតួចនៅក្នុងការអនុវត្តសហគមន៍សិក្សាវិជ្ជាជីវៈ។ តាមរយៈលទ្ធផលនេះ អ្នកស្រាវជ្រាវសន្និដ្ឋានបានថា ការយល់ដឹងអំពីការអនុវត្តសហគមន៍សិក្សាវិជ្ជាជីវៈក្នុងចំណោមសមាជិកសហគមន៍នៅមានចំណុចត្រូវបំពេញបន្ថែមពីសំណាក់អ្នកពាក់ព័ន្ធនានា ដែលមានដូចជា ក្រសួងអប់រំ យុវជន និងកីឡា មន្ទីរ/ការិយាល័យអប់រំ យុវជន និងកីឡា និងគណៈគ្រប់គ្រងសាលាជាដើម។

## ៥.២- សំណូមពរ

ផ្អែកលើការសិក្សាស្រាវជ្រាវខាងលើ អ្នកស្រាវជ្រាវសូមលើកជាសំណូមពរមួយចំនួនទៅកាន់ភាគីពាក់ព័ន្ធដូចតទៅ៖

### ១- ក្រសួងអប់រំ យុវជន និងកីឡា

- តាមរយៈលទ្ធផលអំពីបញ្ហាប្រឈមស្តីពី បន្ទុកការងារ និងឧបសគ្គពេលវេលា ក្រសួងអប់រំ យុវជន និងកីឡា គួរតែបង្កើនចំនួនគ្រូបង្រៀនទៅកាន់វិទ្យាល័យខាងលើ។
- តាមរយៈលទ្ធផលអំពីបញ្ហាប្រឈមស្តីពី ការយល់ដឹងមិនច្បាស់ពីការអនុវត្តសហគមន៍សិក្សាវិជ្ជាជីវៈ ក្រសួងអប់រំ យុវជន និងកីឡា គួរតែបង្កើតឱ្យមានវគ្គវិក្រឹតការ ឬសិក្ខាសាលាស្តីពីសហគមន៍សិក្សាវិជ្ជាជីវៈឱ្យបានជាប្រចាំ។

### ២- មន្ទីរអប់រំ យុវជន និងកីឡា

- គួរតែចុះពិនិត្យជាក់ស្តែងពីស្ថានភាពលើស-ខ្វះគ្រូ នៅវិទ្យាល័យខាងលើ។
- គួរតែបង្កើតក្រុមការងារដើម្បីដំណើរការវគ្គវិក្រឹតការ ឬសិក្ខាសាលាស្តីពីសហគមន៍សិក្សាវិជ្ជាជីវៈឱ្យបានជាប្រចាំ។
- គួរតែបង្កើតកម្មវិធីគាំទ្រ និងលើកទឹកចិត្តដល់សហគមន៍សិក្សាវិជ្ជាជីវៈ តាមរយៈការពិនិត្យ និងវាយតម្លៃការអនុវត្តសហគមន៍សិក្សាវិជ្ជាជីវៈជាប្រចាំ។

### ៣- គណៈគ្រប់គ្រងសាលារៀន

- គួរតែកៀរគររកជំនួយពីសំណាក់ដៃគូសហការនានា ដើម្បីបង្កើតមូលនិធិគាំទ្រនិងលើកទឹកចិត្តដល់សហគមន៍សិក្សាវិជ្ជាជីវៈនៅសាលារៀនរបស់ខ្លួន។
- គួរតែរាយការណ៍ជាប្រចាំ និងធ្វើសំណូមពរជាក់ស្តែងអំពីការអនុវត្ត និងបញ្ហាប្រឈមក្នុងការអនុវត្តសហគមន៍សិក្សាវិជ្ជាជីវៈទៅកាន់ភាគីពាក់ព័ន្ធនានា។

៤- គ្រូបង្រៀន

- គួរតែបែងចែកពេលវេលាឱ្យបានច្បាស់លាស់ និងចូលរួមអនុវត្តភារកិច្ចក្នុងសហគមន៍សិក្សាវិជ្ជាជីវៈឱ្យបានទៀងទាត់។
- គួរតែចំណាយពេលវេលាសិក្សាឈ្វេងយល់បន្ថែមពីបញ្ញត្តិសហគមន៍សិក្សាវិជ្ជាជីវៈ និងការអនុវត្តសហគមន៍សិក្សាវិជ្ជាជីវៈ តាមរយៈការអានឯកសារ និងពិភាក្សាឆ្លុះបញ្ចាំង។

## ៥- សំណូមពរចំពោះការស្រាវជ្រាវទៅថ្ងៃអនាគត

ការសិក្សាស្រាវជ្រាវនេះធ្វើឡើងនៅសាលារៀនជំនាន់ថ្មីកម្រិតមធ្យមសិក្សានៅក្នុងខេត្តកំពង់ចាមតែប៉ុណ្ណោះ។ លទ្ធផលដែលទទួលបានពីការសិក្សានេះមិនបានឆ្លុះបញ្ចាំងជាទូទៅក្នុងក្របខណ្ឌទូទាំងប្រទេសបានឡើយ។ អ្នកស្រាវជ្រាវសំណូមពរដល់ការស្រាវជ្រាវបន្តគួរតែធ្វើឡើងក្នុងក្របខណ្ឌសាលារៀនជំនាន់ថ្មីនៅកម្រិតមធ្យមសិក្សាទូទាំងប្រទេស ដើម្បីធ្វើឱ្យលទ្ធផលនៃការសិក្សាកាន់តែមានភាពទូលំទូលាយ។ ក្រៅពីនេះ ការសិក្សាស្រាវជ្រាវនៅកម្រិតបឋមសិក្សាក៏អាចធ្វើឡើងបានដែរ។ មួយវិញទៀត អ្នកសិក្សាស្រាវជ្រាវជំរុញឱ្យមានការសិក្សាតាមបែបគុណវិស័យ ដើម្បីសិក្សាឱ្យបានកាន់តែស៊ីជម្រៅលើប្រធានបទទាក់ទងនឹងសហគមន៍សិក្សាវិជ្ជាជីវៈនេះ។

# ឯកសារយោង

ក្រសួងអប់រំ យុវជន និងកីឡា (២០២០) បច្ចេកទេសគន្លឹះនៃការស្រាវជ្រាវប្រតិបត្តិ៖ *ការណែនាំសម្រាប់ស្វ័យស្រាវជ្រាវ*។ ភ្នំពេញ ប្រទេសកម្ពុជា។

ក្រសួងអប់រំ យុវជន និងកីឡា (២០២១) *សៀវភៅណែនាំស្តីពីការបង្កើតសហគមន៍សិក្សាវិជ្ជាជីវៈ (Professional Learning Community (PLC)) នៅតាមគ្រឹះស្ថានសិក្សាសាធារណៈ*។ ភ្នំពេញ ប្រទេសកម្ពុជា។

រាជរដ្ឋាភិបាលកម្ពុជា (២០២១) *ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា ២០២១-២០៣៥*។ ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ។

ហង់ជួន ណារ៉ុន (២០២០) *កំណែទម្រង់សាលារៀននៅកម្ពុជា*។ ភ្នំពេញ ប្រទេសកម្ពុជា។

Ary, D., Jacobs, L. C., Irvine, C. K. S., & Walker, D. (2018). *Introduction to research in education*. Cengage Learning.

Bailey, K. T. (2016). *The perceived impact of professional learning communities on collective teacher efficacy in two rural western North Carolina school districts*. Gardner-Webb University.

Beemt, A., Ketelaar, E., Diepstraten, I., & de Laat, M. (2018). Teachers' motives for learning in networks: costs, rewards and community interest. *Educational research*, *60*(1), 31-46.

Bolam, R., McMahon, A., Stoll, L., Thomas, S., Wallace, M., Greenwood, A., Hawkey, K., Ingram, M., Atkinson, A., & Smith, M. (2005). *Creating and sustaining effective professional learning communities*.

Carpenter, D. (2015). School culture and leadership of professional learning communities. *International Journal of Educational Management*.

Carroll, C., & O'Loughlin, D. (2014). Peer observation of teaching: enhancing academic engagement for new participants. *Innovations in Education and Teaching International, 51*(4), 446-456.

Chua, W. C., Thien, L. M., Lim, S. Y., Tan, C. S., & Guan, T. E. (2020). Unveiling the practices and challenges of professional learning community in a Malaysian Chinese secondary school. *Sage Open*, *10*(2), 2158244020925516.

Denscombe, M. (2017). *EBOOK: The good research guide: For small-scale social research projects*. McGraw-Hill Education (UK).

Donegan, M. M., Ostrosky, M. M., & Fowler, S. A. (2000). Peer coaching: Teachers supporting teachers. *Young Exceptional Children, 3*(3), 9-16.

DuFour, R. (2004). What is a" professional learning community"? *Educational Leadership, 61*(8), 6-11.

East, K. A. (2015). A study of professional learning communities: Characteristics of implementation and perceived effectiveness in improvement schools in West Virginia.

Eyanagho, V. E. (2019). Teachers' perceptions of professional learning communities.

Finlay, L. (2008). Reflecting on 'Reflective practice'.

Gray, J. A., & Summers, R. (2015). International professional learning communities: The role of enabling school structures, trust, and collective efficacy. *International Education Journal: Comparative Perspectives, 14*(3), 61-75.

Gutierez, S. B., & Kim, H.-B. (2018). Peer coaching in a research-based teachers' professional learning method for lifelong learning: A perspective. *Alberta Journal of Educational Research, 64*(2), 214-221.

Hairon, S., & Dimmock, C. (2012). Singapore schools and professional learning communities: Teacher professional development and school leadership in an Asian hierarchical system. *Educational review*, *64*(4), 405-424.

Hairon, S., & Tan, C. (2017). Professional learning communities in Singapore and Shanghai: Implications for teacher collaboration. *Compare: A Journal of Comparative and International Education*, *47*(1), 91-104. https://doi.org/https://doi.org/10.1080/03057925.2016.1153408

Harris, A., & Jones, M. (2010). Professional learning communities and system improvement. *Improving schools*, *13*(2), 172-181. https://doi.org/https://doi.org/10.1177%2F1365480210376487

Hefner, J. F. (2011). A case study of a professional learning community: An investigation of sustainability within a rural elementary school. *Unpublished Doctoral dissertation. Appalachian State University*.

Held, P. (2017). An examination of teachers' perceptions regarding the implementation of professional learning communities in central Minnesota public elementary schools.

Henderson, D. (2018). Staff collaboration for student success: Implementation challenges of professional learning communities and response to intervention. *BU Journal of Graduate Studies in Education*, *10*(2), 39-44. http://files.eric.ed.gov/fulltext/EJ1230351.pdf

Kaminski, S. A. (2011). Implementing a professional learning community: a case study.

Mills, G. E., & Gay, L. R. (2019). *Educational research: Competencies for analysis and applications*. ERIC.

Mullen, C. (2009). *The handbook of leadership and professional learning communities*. Springer.

Park, M., & So, K. (2014). Opportunities and challenges for teacher professional development: a case of collaborative learning community in South Korea. *International education studies*, *7*(7), 96-108. http://files.eric.ed.gov/fulltext/EJ1070426.pdf

Pollara, J. (2012). *Peer coaching: Teachers as leaders, teachers as learners*. College of Saint Elizabeth.

Rhodes, R. (2017). Supporting novice teachers: Peer coaching and collaborative inquiry as support.

Ronfeldt, M., Farmer, S. O., McQueen, K., & Grissom, J. A. (2015). Teacher collaboration in instructional teams and student achievement. *American educational research journal*, *52*(3), 475-514.

Saad, K. A. (2019). *Peer Coaching in Malaysia: Exploring the Implementation of a Professional Learning Communities Programme for Arabic Language Secondary School Teachers*. Liverpool John Moores University (United Kingdom).

Salkind, N. J. (1997). *Exploring research*. Pearson Educación.

Somprach, K., Tang, K. N., & Popoonsak, P. (2017). The relationship between school leadership and professional learning communities in Thai basic education schools. *Educational research for policy and practice*, *16*(2), 157-175.

Stewart, C. S. (2017). *Secondary teachers' perceptions of the effectiveness of a professional learning community* Walden University].

Stoll, L., & Louis, K. S. (2007). *Professional learning communities*. McGraw-Hill Education (UK).

Tayag, J. R. (2020). Professional learning communities in schools: Challenges and opportunities. *Universal Journal of Educational Research*, *8*(4), 1529-1534.

Toole, J. C., & Louis, K. S. (2002). The role of professional learning communities in international education. In *Second international handbook of educational leadership and administration* (pp. 245-279). Springer.

Vincent, A. K. (2018). *Collaborating With Teachers To Create Peer Observations As A Means Of Effective Professional Development* University of South Carolina].

Voelkel Jr, R. H., & Chrispeels, J. H. (2017). Understanding the link between professional learning communities and teacher collective efficacy. *School effectiveness and school improvement*, *28*(4), 505-526.

# ឧបសម្ព័ន្ធ

## ឧបសម្ព័ន្ធ "ក"

## កម្រងសំណួរសម្រាប់គណៈគ្រប់គ្រង

ខ្ញុំបាទឈ្មោះ **ស៊ិន ភារ័ក្ស** ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៩ នៅវិទ្យាស្ថានជាតិអប់រំ កំពុងសរសេរនិក្ខេបបទស្តីពី **"ទស្សនៈគ្រូបង្រៀនលើការអនុវត្តសហគមន៍សិក្សាវិជ្ជាជីវៈនៅកម្រិតមធ្យមសិក្សាក្នុងខេត្តកំពង់ចាម"** ដើម្បីបញ្ចប់ការសិក្សា។

គោលបំណងនៃការប្រមូលទិន្នន័យនេះ គឺដើម្បីសិក្សាពីការអនុវត្ត និងបញ្ហាប្រឈមក្នុងការអនុវត្តសហគមន៍សិក្សាវិជ្ជាជីវៈនៅកម្រិតមធ្យមសិក្សានៅសាលារៀនជំនាន់ថ្មីក្នុងខេត្តកំពង់ចាម (វិទ្យាល័យ ហ៊ុន សែន កំពង់ចាម និងវិទ្យាល័យ ហ៊ុន សែន ពាមជីកង)។ ទិន្នន័យដែលទទួលបានពីលោកនាយក លោកនាយករង នឹងត្រូវបានយកទៅធ្វើការសិក្សាវិភាគ ឆ្លើយតបទៅនឹងប្រធានបទខាងលើ។

ទិន្នន័យនេះប្រើប្រាស់ក្នុងគោលបំណងសិក្សាស្រាវជ្រាវតែប៉ុណ្ណោះ។ ក្នុងន័យនេះ ខ្ញុំបាទសូមការសហការពីសំណាក់លោកនាយក លោកនាយករង មេត្តាជួយផ្តល់ព័ត៌មានពិតជាក់ស្តែង ដើម្បីឱ្យខ្ញុំបាទអាចមានទិន្នន័យពិតជាក់ស្តែងតាមបែបវិទ្យាសាស្ត្រក្នុងការសរសេរនិក្ខេបបទស្រាវជ្រាវនេះ។

ខ្ញុំបាទសូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះការចូលរួមរបស់លោកនាយក និងលោកនាយករង ។

### ផ្នែកទី១ ៖ ព័ត៌មានប្រជាសាស្ត្រ

**ការណែនាំ ៖** សូមលោកនាយក លោកនាយករង បំពេញព័ត៌មាន និងគូសសញ្ញា (✓) ក្នុងប្រអប់នីមួយៗខាងក្រោម ទៅតាមស្ថានភាពជាក់ស្តែង។

១- តំណែង ៖ ☐នាយក ☐នាយករង

២- អង្គភាព ៖ .................................................................

៣- ភេទ ៖ ☐ប្រុស ☐ស្រី

៤- អាយុ ៖ ☐២០-២៥ឆ្នាំ ☐២៦-៣០ឆ្នាំ ☐៣១-៣៥ឆ្នាំ ☐៣៦-៤០ឆ្នាំ ☐លើស៤០ឆ្នាំ

៥- កម្រិតវប្បធម៌ ៖ ☐ចប់ទី១២ ☐បរិញ្ញាបត្រ ☐បរិញ្ញាបត្រជាន់ខ្ពស់ ☐បណ្ឌិត

៦- បទពិសោធន៍ការងារ ៖ ☐១-៥ឆ្នាំ ☐៦-១០ឆ្នាំ ☐១១-១៥ឆ្នាំ ☐លើសពី១៥ឆ្នាំ

**ផ្នែកទី២ ៖ ទស្សនៈគ្រូបង្រៀនស្តីពីការអនុវត្តសហគមន៍សិក្សាវិជ្ជាជីវៈ**

**ការណែនាំ ៖** សហគមន៍សិក្សាវិជ្ជាជីវៈត្រូវបានអនុវត្តជាផ្នែកមួយគាំទ្រដល់ការអភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈគ្រូបង្រៀន ក្នុងគោលបំណងលើកកម្ពស់លទ្ធផលសិក្សារបស់សិស្ស។ ក្នុងន័យនេះ តើការអនុវត្តសហគមន៍សិក្សាវិជ្ជាជីវៈនៅសាលារៀនជំនាន់ថ្មីក្នុងខេត្តកំពង់ចាមមានលក្ខណៈបែបណា? សូមលោកនាយក លោកនាយករង អានចំណុចនីមួយៗឱ្យបានច្បាស់លាស់ បន្ទាប់មក សូមគូសសញ្ញា (✓) ទៅតាមកម្រិតនៃការយល់ស្របរបស់លោកនាយក លោកនាយករង ។

**កម្រិតចង្អុលបង្ហាញ ៖**

១ = មិនយល់ស្របទាល់តែសោះ ២ = មិនយល់ស្រប ៣ = ពុំមានយោបល់

៤ = យល់ស្រប ៥ = យល់ស្របខ្លាំង

| ល.រ | បរិយាយ | កម្រិតចង្អុលបង្ហាញ | | | | |
|---|---|---|---|---|---|---|
| | | ១ | ២ | ៣ | ៤ | ៥ |
| **១- របៀបរបបអនុវត្តការងារ** | | | | | | |
| **១.១- ការសិក្សាជាក្រុម** | | | | | | |
| ១ | សមាជិកនៃសហគមន៍សិក្សាវិជ្ជាជីវៈជួបជុំគ្នារៀងរាល់សប្តាហ៍។ | | | | | |
| ២ | សហគមន៍ទាំងមូលជួបជុំគ្នាធ្វើឡើងតាមរយៈការប្រជុំផ្ទាល់។ | | | | | |
| ៣ | សហគមន៍ទាំងមូលជួបជុំគ្នាធ្វើឡើង តាមប្រព័ន្ធអេឡិចត្រូនិច ដូចជា ZOOM ឬ Google Meet ជាដើម។ | | | | | |
| ៤ | រាល់ការប្រជុំមានរបាយការណ៍ ឬកំណត់ហេតុ ដើម្បីរក្សាទុកជាឯកសារ ឬភស្តុតាងក្នុងអង្គភាព។ | | | | | |
| ៥ | សមាជិកម្នាក់ៗចងក្រងខ្លឹមសារ និងរក្សាទុកខ្លឹមសារទាំងឡាយក្នុងកម្រងស្នាដៃវិជ្ជាជីវៈរបស់ខ្លួន (Teacher Portfolio)។ | | | | | |
| **១.២- ការសង្កេតថ្នាក់ និងប្រឹក្សា** | | | | | | |
| ៦ | ប្រធានក្រុមសហគមន៍សិក្សាវិជ្ជាជីវៈសហការជាមួយនាយករងទទួលបន្ទុកបច្ចេកទេស ដើម្បីផ្តល់ដំបូន្មានលើការបង្រៀននិងរៀន។ | | | | | |
| ៧ | ប្រធានក្រុមសហគមន៍សិក្សាវិជ្ជាជីវៈសហការជាមួយនាយករងទទួលបន្ទុកបច្ចេកទេស គាំទ្រដល់គ្រូបង្រៀនធ្វើការអភិវឌ្ឍវិជ្ជាជីវៈ និងធានាប្រសិទ្ធភាពនៃការបង្រៀននិងរៀន។ | | | | | |
| ៨ | សមាជិកសហគមន៍មានឧបករណ៍សង្កេតច្បាស់លាស់ក្នុងការចុះសង្កេតថ្នាក់ ដោយផ្អែកលើកាលវិភាគបង្រៀនជាក់ស្តែង។ | | | | | |
| ៩ | សមាជិកសហគមន៍មានផែនការច្បាស់លាស់ក្នុងការចុះសង្កេតថ្នាក់ ដោយផ្អែក | | | | | |

| | | | | | | |
|---|---|---|---|---|---|---|
| | លើកាលវិភាគបង្រៀនជាក់ស្តែង។ | | | | | |
| ១០ | ព័ត៌មានដែលទទួលបានពីការសង្កេតថ្នាក់ត្រូវបានប្រើសម្រាប់ការឆ្លុះបញ្ចាំងការសង្កេតលើកក្រោយៗទៀត។ | | | | | |
| ១១ | ព័ត៌មានដែលទទួលបានពីការសង្កេតថ្នាក់ត្រូវបានដាក់ចូលក្នុងរបៀបវារៈប្រជុំក្នុងខែនីមួយៗ។ | | | | | |
| ១២ | សមាជិកសហគមន៍ម្នាក់ៗចូលសង្កេតការបង្រៀនរបស់គ្រូដែលមានបច្ចេកទេសខ្ពស់ក្នុងសាលា ដើម្បីរៀនសូត្រ និងច្នៃប្រឌិតវិធីសាស្ត្រឱ្យសមស្របតាមមេរៀននីមួយៗ និងលទ្ធភាពជាក់ស្តែងនៃថ្នាក់នីមួយៗ។ | | | | | |
| ១៣ | ព្រឹត្តិបត្តិសង្កេតថ្នាក់ទទួលបានការឯកភាពពីគ្រូបង្រៀនដែលត្រូវបានអង្កេតត្រូវបានរក្សាទុក ដើម្បីជាភស្តុតាងក្នុងកម្រងស្នាដៃវិជ្ជាជីវៈ (Teacher Portfolio)។ | | | | | |
| **១.៣- ភារកិច្ចរបស់សហគមន៍សិក្សាវិជ្ជាជីវៈ** | | | | | | |
| ១៤ | សមាជិកសហគមន៍ធ្វើការសិក្សាស្រាវជ្រាវទាក់ទងការបង្រៀន និងរៀន។ | | | | | |
| ១៥ | សមាជិកសហគមន៍បានអនុវត្តការសិក្សាស្រាវជ្រាវមេរៀន ដើម្បីចាប់យកនូវទេពកោសល្យទៅអនុវត្តក្នុងការងារបង្រៀន និងរៀនឱ្យមានការឯកភាពគ្នា។ | | | | | |
| ១៦ | សមាជិកសហគមន៍បានធ្វើថ្នាក់និទស្សន៍ ដើម្បីចាប់យកនូវទេពកោសល្យទៅអនុវត្តក្នុងការងារបង្រៀន និងរៀនឱ្យមានការឯកភាពគ្នា។ | | | | | |
